ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- គ្រួងព្រះសីហនុ ការចងចាំចម្រូងចម្រាសនៅក្នុងទេសភាពដ៏ស្រស់ត្រកាលបំផុតមួយ
- សារមន្ទីរសម្ដេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងសារមន្ទីរព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
- អនុប្រធានអង្គការសហប្រជាជាតិ ពិភាក្សាអំពីសន្តិភាព សិទ្ធិមនុស្ស និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងនៅក្នុងប្រទេសដទៃទៀត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៣ ខែវិច្ឆិកា ឆ្នាំ២០២១

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៣ ខែវិច្ឆិកា ឆ្នាំ២០២១

## មាតិកា

### សំបុត្រ

◆ ក្រុងព្រះសីហនុ ការបង្ហាំចម្រូងចម្រាស ..១

◆ សារមន្ទីរសម្ដេចព្រះបរមរតនកោដ្ឋ....... ១០

### ផ្នែកឯកសារ

◆ សុខវរៈ ហៅ យិន យុទ្ធនារី............... ១២

### ផ្នែកឯកសារ

◆ ការងាររនៅតាមសហករណ៍ក្នុងរបប ..... ១៤

◆ ដោយសារតែភាពក្រិន ប្រធានកងឲ្យខ្ញុំ..១៧

◆ យឹង យុយ ៖ ខ្មែរក្រហមយកខ្ញុំទៅ ...... ២០

◆ គំនុំសងសឹកដែលមិនអាចរំលត់បាន..... ២៣

◆ ហិន អ៊ិក ៖ រត់គេចពីការតាមចាប់....... ២៥

◆ ពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធ...... ២៧

◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅភូមិសាទុំ...៣១

### ផ្នែកច្បាប់

◆ សាលក្រមសំណុំរឿង០០២/០២ ......... ៤០

### ផ្នែកវេទិកាសាធារណៈ

◆ អនុប្រធានអង្គការសហប្រជាជាតិ ពិភាក្សា អំពីសន្តិភាព សិទ្ធិមនុស្ស .................. ៤៩

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ «ទួលពិឃាដ»

១. មីគ្នោត មេគោអង្គការ (ត) ........... ៥២

២. ជីវិតក្នុងជំរំក្អែកខ្មៅបដិវត្តន៍ ............៥៣

៣. វិញ្ញាណព្រលឹងក្រមាប៉ា់ជាយ........... ៦១



ឡុង សាម៉េត ត្រូវជាប្អូនរបស់ ឡុង វង្សសមិទ្ធ អ្នកនិពន្ធសៀវភៅ ទួលពិឃាដ
(សៀវភៅ ទួលពិឃាដ / ឡុង វង្សសមិទ្ធ)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដារ៉ារដ្ឋ មេត្តា, ង៉ាន់ វីន, ឡុង ដានី, រី លក្ខិណា, គាត ស្រីឡែន, កាន់ សុភាព, ហួត ស៊ីណាត, សុភ័ក្ត្រ ភាណា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** លឹម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ក្រុងព្រះសីហនុ ការចងចាំចម្រូងចម្រាស
## នៅក្នុងទេសភាពដ៏ស្រស់ត្រកាលបំផុតមួយ

**ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**




លោក ឆាំង យុ បំពាក់គ្រឿងការពារសុវត្ថិភាពពេលធ្វើដំណើរ ក្នុងអំឡុងពេលបំពេញតួនាទីជាបុគ្គលិកត្រួតពិនិត្យការបោះឆ្នោតរបស់ អ៊ុនតាក់ បានលើកឡើងថា ការធ្វើដំណើរនៅតាមដងផ្លូវក្នុងប្រទេសកម្ពុជា នៅមុនការបោះឆ្នោតជាតិក្នុងឆ្នាំ១៩៩៣ គឺប្រកបដោយគ្រោះថ្នាក់។ (វុត្ថា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការចងចាំដ៏ស្រស់ត្រកាលបំផុតមួយរបស់ខ្ញុំចំពោះប្រទេសកម្ពុជា កើតមាននៅពេលដែលខ្ញុំត្រឡប់មកកាន់មាតុប្រទេសនេះនៅក្នុងឆ្នាំ១៩៩២ ដើម្បីបំពេញការងារជាមួយអ៊ុនតាក់ គឺនៅពេលនោះហើយ ដែលខ្ញុំបានមើលឃើញទិដ្ឋភាពសមុទ្រ និងឆ្នេរខ្សាច់លាតសន្ធឹងដាច់កន្ទុយភ្នែកនៅក្រុងព្រះសីហនុ។

ពេលនោះគឺជាដំណើរដំបូងរបស់ខ្ញុំមកកាន់ទីក្រុងមួយនេះ ដែលស្ថិតនៅបណ្តោយឈូងសមុទ្រថៃដោយត្រូវបានដាក់ឈ្មោះតាមព្រះនាមរបស់សម្តេចព្រះនរោត្តម សីហនុ ក្នុងឆ្នាំ១៩៥៨។ ដោយសារតែវត្តមាននៃសង្គ្រាមស៊ីវិល និងរបបខ្មែរក្រហមក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ខ្ញុំមិនមានឱកាសមកកាន់ទីក្រុងមួយនេះទេ។

ជាក្មេងម្នាក់ដែលធំធាត់ឡើងនៅក្នុងទីក្រុងភ្នំពេញនាអំឡុងទសវត្សរ៍ទី៦០ ការធ្វើដំណើរឆ្ងាយបំផុតរបស់ខ្ញុំគឺការទៅសួរសុខទុក្ខជីដូនរបស់ខ្ញុំដែលរស់នៅឯក្រុងបាត់ដំបង។ ខ្ញុំបានធ្វើដំណើរតាមរថភ្លើង



លោក ឆាំង យុ កំពុងរៀបឡើងឧទ្ធម្ភាគចក្ររបស់អ៊ុនតាក់ក្នុងឆ្នាំ១៩៩២ នៅប្រទេសកម្ពុជា នាពេលបំពេញការងារជាបុគ្គលិកត្រួតពិនិត្យការបោះឆ្នោតអន្តរជាតិរៀបចំដោយអ៊ុនតាក់។ (ព្រីជីត ហ្វ្រង់កូ / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីទៅសួរសុខទុក្ខជីដូនស៊ីវីល័យរូបនេះ។ ជីដូនខ្ញុំបានតែងកាយឆើតឆាយ និងទទួលក្រុមគ្រួសារខ្ញុំជាមួយនឹងបង្អែមសាច់ដូងអប់ក្លិនក្រអូបនឹងលាបល័ខ ដែលមានពណ៌ខៀវខ្ចី និងពណ៌ផ្កាឈូក។

បន្ទាប់មកទៀត គឺការធ្វើដំណើរភៀសខ្លួនចេញពីប្រទេសរបស់ខ្ញុំនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ក្រោយពីនោះ គឺទៅកាន់ជំរំជនភៀសខ្លួនក្នុងប្រទេសថៃ តមកគឺប្រទេសហ្វីលីពីន និងចុងបញ្ចប់អន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិក។

បន្ទាប់ពីរដ្ឋាភិបាលកម្ពុជា និងក្រុមភាគីនយោបាយ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្នុងឆ្នាំ១៩៩១ ខ្ញុំបានបំពេញតួនាទីជាបុគ្គលិកត្រួតពិនិត្យការបោះឆ្នោតអន្តរជាតិរៀបចំដោយអាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់។ ខ្ញុំបានធ្វើដំណើរមកកាន់ទីក្រុងព្រះសីហនុតាមឧទ្ធម្ភាគចក្រ និងបានគយគន់ទេសភាពស្រស់ត្រកាលនៃឆ្នេរតាមបណ្តោយឈូងសមុទ្រ ដែលខ្ញុំមិនធ្លាប់បានដឹងទាល់តែសោះថាមានទេសភាពល្អឆើតយ៉ាងដូច្នេះនៅក្នុងប្រទេសរបស់ខ្ញុំ។

ជាច្រើនឆ្នាំបន្ទាប់មកទៀត ខ្ញុំបានធ្វើដំណើរជាច្រើនលើកច្រើនសាទៅកាន់ក្រុងព្រះសីហនុដែលប្រជាជនកម្ពុជាទូទៅនៅតែនិយមហៅថា កំពង់សោម។ ដូចទៅនឹងក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដែរ ខ្ញុំបាននាំបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ទៅកាន់ទីនោះ នាចុងសប្តាហ៍ កាលពីអំឡុងទសវត្សរ៍ឆ្នាំ២០០០ និងឆ្នាំ២០១០។

ដោយសារកត្តាជាច្រើនជាពិសេសដោយសារតែជំងឺរាតត្បាតកូវីដ-១៩ផងនោះ ខ្ញុំមិនបានទៅកាន់ក្រុងព្រះសីហនុអស់រយៈកាលជាងពីរឆ្នាំ។ ហេតុនេះដើម្បីអបអរពិធីចម្រើនព្រះជន្មរបស់អតីតព្រះមហាក្សត្រ សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលទ្រង់ប្រសូតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ ដែលគឺជាទិវាបុណ្យជាតិដែរនោះ ខ្ញុំបានធ្វើដំណើរទៅកាន់ក្រុងព្រះសីហនុ ដែលមានចម្ងាយប្រមាណជាង២២៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ។

ក្រុងព្រះសីហនុដែលខ្ញុំបានឃើញនាពេលនេះ គឺមិនមែនជាទីក្រុងមួយដែលខ្ញុំធ្លាប់ស្គាល់នោះទេ។ តាមបណ្តោយផ្លូវនានានៅក្នុងក្រុង ពោរពេញទៅដោយអគារខ្ពស់ៗឈរបញ្ជ្រង ដែលភាគច្រើនជាសណ្ឋាគារ និងកាស៊ីណូ ឯអគារខ្លះទៀតស្ថិតនៅទទេ ឬកំពុងសាងសង់។

ទោះបីជាយ៉ាងណាក្តី ភ្នំដែលខ្ញុំដើរឡើងនាពេលដំបូងបំផុត កាលពីរយៈកាលច្រើនឆ្នាំកន្លងមក ដើម្បីគយគន់ទេសភាពឆ្នេរនិងសមុទ្រ មិនទាន់មានការកែប្រែនៅឡើយ។

ប៉ុន្តែជាដំបូង ខ្ញុំសូមរំឭកអំពីក្រុងព្រះសីហនុដែលខ្ញុំបានឃើញកាលពី២៩ឆ្នាំមុន។

## គយគន់ទីក្រុងដ៏មនោរម្យតាមបណ្តោយសមុទ្រ

ទស្សនកិច្ចដំបូងបំផុតទៅកាន់ក្រុងព្រះសីហនុគឺជាបទពិសោធន៍ដ៏អស្ចារ្យ ខ្ញុំអាចនិយាយបានថាពិតជាមហស្ចារ្យ ដោយអាកាសយានិកជនជាតិរុស្ស៊ី ដែល

ប្រកបដោយក្តីរំភើប បានបើកបន្ទប់ខទ្វាមក្តាកចក្រប៉ះនឹងផ្ទៃសមុទ្រ ធ្វើឲ្យសាចខ្ទាតទឹកឡើងគួរឲ្យគយគន់។

ប្រជាជនក្នុងក្រុងនេះមានចំនួនប្រមាណជាង១ម៉ឺន៥ពាន់នាក់ប៉ុណ្ណោះ កាលពីទសវត្សរ៍ឆ្នាំ១៩៦០។ នៅថ្ងៃមួយក្នុងខែកញ្ញា ឆ្នាំ១៩៩២ អ្វីដែលខ្ញុំមើលឃើញ គឺទីក្រុងតូចមួយអមមកនូវសមុទ្រលាតសន្ធឹងដ៏វែងអន្លាយ។ ផ្ទៃសមុទ្រពណ៌ខៀវស្ថិតនៅជាប់ឮផ្ទៃអាកាសខៀវស្រងាត់។ ទិដ្ឋភាពនេះប្រៀបបានដូចជាឋានសួគ៌។ ធ្វើដំណើរឡើងទៅលើភ្នំនិងមើលឃើញនូវទេសភាពសែនល្អឆើតនេះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំស្ថិតនៅត្រង់ចំណុចខ្ពស់បំផុតនៃពិភពលោក។ គ្មាននរណាម្នាក់បានទៅដល់ទីនោះទេ។

បន្ទាប់ពីទស្សនកិច្ចដំបូងនេះ ខ្ញុំបានធ្វើដំណើរដោយរថយន្ត។ ក្នុងនាមជាបុគ្គលិកត្រួតពិនិត្យការបោះឆ្នោត ខ្ញុំត្រូវបានចាត់តាំងឲ្យបំពេញការងារនៅក្នុងខេត្តកំពង់ស្ពឺ។ ខ្ញុំបានបម្រើការងារជាមួយអ៊ុនតាក់រហូតដល់បេសកកម្មរបស់អង្គការសហប្រជាជាតិបានបញ្ចប់នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៣។ ខ្ញុំបានផ្សាំខ្លួនជាមួយនឹងការធ្វើដំណើរតាមដងផ្លូវ។

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហានានា គឺខ្មែរក្រហមតែងតែប៉ុនប៉ងបង្អាក់ចរាចរណ៍ និងកាត់ផ្តាច់វិទ្យុទាក់ទង។

បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងខែតុលា ឆ្នាំ១៩៩១មក មេដឹកនាំខ្មែរក្រហមបានបំពានលើកិច្ចព្រមព្រៀងនេះ ហើយព្យាយាមបង្អាក់ដល់ការបោះឆ្នោត។ ហេតុនេះក្រុមខ្មែរក្រហមបានព្យាយាមបំភ័យប្រជាជនបិទផ្លូវ និងធ្វើសកម្មភាពផ្សេងៗជាច្រើន ដើម្បីរារាំងការប្រព្រឹត្តទៅនៃការបោះឆ្នោត។ ក៏ប៉ុន្តែ ក្រុមខ្មែរក្រហមបានទទួលបរាជ័យយ៉ាងដំណំ។ នៅក្នុងខែឧសភា ឆ្នាំ១៩៩៣ ស្ទើរតែ៩០ភាគរយនៃប្រជាជនមានសិទ្ធិបោះឆ្នោត បានអនុវត្តសិទ្ធិរបស់ខ្លួន។

នៅពេលដែលខ្ញុំធ្វើដំណើរដើម្បីបំពេញការងារឲ្យអ៊ុនតាក់ ខ្ញុំធ្វើដំណើរក្នុងកាលវិភាគជាក់លាក់ ដើម្បីឲ្យអង្គភាពសន្តិសុខអាចរក្សាសុវត្ថិភាព និងត្រួសត្រាយផ្លូវសម្រាប់ខ្ញុំទុកជាមុន។ ក៏ប៉ុន្តែ ប្រជាជនសាមញ្ញមិនទទួលបានការការពារពិសេសយ៉ាងដូច្នេះទេ។

ទោះបីជាយ៉ាងណាក្តី នាពេលចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកខ្លះ បន្ទាប់ពីទស្សនកិច្ចលើកដំបូងរបស់ខ្ញុំ ខ្ញុំបានសម្រេចចិត្តធ្វើដំណើរទៅកាន់ក្រុងព្រះសីហនុតាមរយៈរថយន្ត។ ដូចការរំពឹងទុក ខ្ញុំត្រូវបានបង្អាក់ដំណើរដោយក្រុមខ្មែរក្រហម។ នៅពេលនោះមានទាហានស្លៀកពាក់ឯកសណ្ឋានដើម្បីគំរាមដល់បុគ្គលិករបស់អ៊ុនតាក់។ ជួនកាល អ្នកទាំងនោះមើលទៅហាក់ដូចជាក្រុមខ្មាំងខ្មែរក្រហម ឯជួនកាលដូចជាទាហានរបស់រដ្ឋាភិបាល។ មិនខ្វល់ថាអ្នកទាំងនោះជាក្រុមណាទេ អ្នកទាំងនោះតែងជំរិតទារប្រាក់ពីអ្នកឆ្លងកាត់ផ្លូវជាតិ។ ដោយសារខ្ញុំអាចនិយាយភាសាខ្មែរបាន ខ្ញុំអាចចរចា និងបន្តដំណើរទៅមុខទៀត។

ជាក្មេងម្នាក់ដែលធំដឹងក្តីឡើងនៅក្នុងទីក្រុងភ្នំពេញ ខ្ញុំបានគ្រាន់តែបានស្គាល់អំពីក្រុងព្រះសីហនុតាមរយៈសៀវភៅសិក្សាអំពីភូមិវិទ្យានៅថ្នាក់បឋមសិក្សា។ ក្រៅពីការធ្វើដំណើរតាមរថភ្លើងគួរជាទីរីករាយទៅកាន់ក្រុងបាត់ដំបងនោះ ខ្ញុំបានត្រឹមតែធ្វើដំណើរទៅកាន់ខេត្តតាកែវ ដើម្បីទៅសួរសុខទុក្ខជីដូនម្នាក់ទៀតខាងម្តាយរបស់ខ្ញុំ។

បន្ថែមលើសពីនេះ កំណាត់ផ្លូវពីភ្នំពេញទៅកាន់ក្រុងព្រះសីហនុ ស្ថិតក្រោមការស្តាបនាជាច្រើនឆ្នាំក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។ បន្ទាប់ពីនោះមក សង្គ្រាមក៏បានឆាបឆេះឡើង នៅចុងទសវត្សរ៍ទី៦០និងដើមទសវត្សរ៍ទី៧០។

នារយៈកាលជាង៣០ឆ្នាំក្រោយមក ទើបខ្ញុំដឹងថា ខ្ញុំបានស្គាល់ប្រទេសរបស់ខ្លួនបានតិចតួចណាស់។ នាពេលកន្លងទៅ ខ្ញុំគិតថាប្រជាជនកម្ពុជាមិនធ្វើដំណើរទេសចរណ៍នៅក្នុងមាតុប្រទេសរបស់ខ្លួនទេ។ ដោយសារតែកត្តាជាច្រើនរួមមាន សេដ្ឋកិច្ច ជីវភាពមធ្យោបាយធ្វើដំណើរជាដើម ប្រជាជនកម្ពុជាមិនអាចធ្វើដំណើរស្វែងយល់អំពីប្រទេសរបស់ខ្លួន។ ហេតុនេះយើងមិនបានដឹងច្រើនអំពីប្រាសាទអង្គរវត្ត ឬតំបន់ឆ្នេរដ៏ល្បីល្បាញនោះទេ។

នៅពេលដែលខ្ញុំធំដឹងក្តី ឪពុករបស់ខ្ញុំធ្វើការផ្សារពីព្រឹកទល់ល្ងាចៗ ខ្ញុំមានបងប្អូនជាច្រើន ដោយមានម្តាយខ្ញុំជាអ្នកដាំស្លឲ្យបរិភោគជារៀងរាល់ថ្ងៃៗ នៅរៀងរាល់ថ្ងៃអាទិត្យ យើងបានត្រឹមតែខ្វាយខ្វល់អំពីជីវិតប្រចាំថ្ងៃប៉ុណ្ណោះៗ ខ្ញុំមិនដែលស្គាល់ពាក្យថាវិស្សមកាលនោះទេៗ នៅរាប់ទសវត្សរ៍ក្រោយមកទើបខ្ញុំយល់អំពីអត្ថន័យនៃពាក្យវិស្សមកាលនេះៗ

ដូចគ្នានៅនឹងប្រជាជនកម្ពុជាដទៃទៀតដែរ ខ្ញុំបានត្រឹមតែឮអំពីក្រុងព្រះសីហនុ តាមរយៈ ទំនុកភ្លេង និងបទចម្រៀងៗ ដូច្នេះ ខ្ញុំមិនបានដឹងសោះថាយើងមានទីក្រុងតាមបណ្តោយមាត់សមុទ្រ នៅពេលដែលខ្ញុំបានឃើញក្រុងព្រះសីហនុដំបូងបង្អស់ៗ

ក្រៅពីទេសភាពដ៏ស្រស់ល្អឯក មូលហេតុមួយផ្សេងទៀតដែលខ្ញុំចង់ទៅកាន់ក្រុងព្រះសីហនុ គឺដោយសារតែលោកជីទាវ ចាកឃ្លីន កេណឌីៗ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ព្រះអង្គម្ចាស់ នរោត្តម សីហនុបានដាក់ឈ្មោះផ្លូវថ្មីមួយតាមឈ្មោះស្វាមីរបស់លោកជីទាវ គឺលោកប្រធានាធិបតីសហរដ្ឋអាមេរិក ចន កេណឌី ដែលត្រូវបានធ្វើឃាតនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៣ៗ

នៅពេលដែលលោកជីទាវធ្វើទស្សនកិច្ចឯកជនមកកាន់ប្រទេសកម្ពុជា ដែលមិនមែនក្នុងផ្លូវការទូត នៅខែវិច្ឆិកា ឆ្នាំ១៩៦៧ ព្រះអង្គម្ចាស់ នរោត្តម សីហនុ បានអញ្ជើញលោកជីទាវឲ្យសម្ពោធវិថីនោះៗ នៅវ័យក្មេងខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំងចំពោះប្រធានាធិបតី ចន កេណឌី និងលោកជីទាវ ចាកឃ្លីន កេណឌីៗ អ្នកទាំងពីរគឺជាជនគំរូ ដែលជាកម្លាំងជំរុញចិត្តឲ្យខ្ញុំសម្រេចក្តីស្រមៃ គឺទៅកាន់សហរដ្ឋអាមេរិកៗ នេះក៏អាចនិយាយបានថា គឺជាអ្វីដែលជួយស្រោចស្រង់ជីវិតខ្ញុំពីរបបខ្មែរក្រហមៗ




នៅចុងទសវត្សរ៍ឆ្នាំ២០០០ និងនៅទសវត្សរ៍ឆ្នាំ២០១០ ប្រជាជនកម្ពុជាមានការពេញនិយមក្នុងការលេងកីឡានិងសកម្មភាពនានានៅលើផ្ទៃទឹកនៅតាមមាត់សមុទ្រៗ រូបថតឆ្នាំ ២០១៨ ៗ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ការរំឭកដ៏គ្រោតគ្រាតពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនៅក្នុងដែនសមុទ្រដ៏ស្រស់ត្រកាលមួយ

នាប៉ុន្មានទសវត្សរ៍ក្រោយៗមក ខ្ញុំតែងត្រឡប់ទៅកាន់ក្រុងព្រះសីហនុវិញជាច្រើនលើកច្រើនសា ជាការសម្រាកកម្សាន្តចុងសប្តាហ៍ ឬជាដំណើរកម្សាន្តជាក្រុមជាមួយនឹងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជារបស់ខ្ញុំ។

ក៏ប៉ុន្តែ ទស្សនកិច្ចមួយរបស់ខ្ញុំនៅក្នុងឆ្នាំ១៩៩៧ បានក្រើនរំឭកខ្ញុំអំពីភាពព្រឺព្រួចនៃរបបខ្មែរក្រហម ដែលបន្តដិតដាមនៅក្នុងប្រទេសកម្ពុជារហូតមកទល់ពេលបច្ចុប្បន្ន។

ដំណើរកម្សាន្តនាចុងសប្តាហ៍មួយ ចំថ្ងៃទី៣១ ខែតុលា ដែលជាការអបអរដល់ពិធីចម្រើនព្រះជន្មរបស់ព្រះមហាក្សត្រ សម្តេច នរោត្តម សីហនុ ខ្ញុំបានសម្រេចចិត្តធ្វើដំណើរជាមួយក្រុមគ្រួសាររបស់ខ្ញុំទៅកាន់ក្រុងព្រះសីហនុ។ នៅពេលដែលខ្ញុំបានមកដល់ក្រុងព្រះសីហនុ នៅទីនេះគ្មានមនុស្សសោះ។ នៅឯសណ្ឋាគារ អ្នកគ្រប់គ្រងបានប្រាប់យើងថា មន្ត្រីរដ្ឋាភិបាលនឹងមកកាន់ទីនេះ។ ទាហាននិងមន្ត្រីប៉ូលិស នឹងបិទក្រុងដើម្បីទទួលស្វាគមន៍មន្ត្រីរដ្ឋាភិបាលរូបនោះ។

អ្នកគ្រប់គ្រងសណ្ឋាគារបានប្រាប់ខ្ញុំទៀតថា ខ្ញុំមិនអាចស្នាក់នៅក្នុងបន្ទប់សណ្ឋាគារដែលខ្ញុំបានកក់រួចនោះទេ ទោះបីជាខ្ញុំបានទូទាត់ប្រាក់ជាមុនហើយក្តី។ សណ្ឋាគារនេះ គឺជាសណ្ឋាគារល្អគួរសមនាពេលនោះ ហើយអ្នកគ្រប់គ្រងសណ្ឋាគារមិនអាចបដិសេធចំពោះមន្ត្រីរដ្ឋាភិបាលរូបនោះទេ។ សណ្ឋាគារនេះ មានប្រមាណ១០បន្ទប់ ហើយមន្ត្រីរដ្ឋាភិបាលរូបនោះ បានកក់យកទាំងអស់។ ហេតុនេះ អ្នកគ្រប់គ្រងសណ្ឋាគារបានស្នើឲ្យខ្ញុំស្នាក់នៅជាមួយបុគ្គលិកសណ្ឋាគារ នៅក្នុងបន្ទប់តូចមួយជាបណ្តោះអាសន្នសិន។

ខ្ញុំទុកឲ្យបងស្រី និងម្តាយរបស់ខ្ញុំស្នាក់នៅសណ្ឋាគារ ចំណែកឯខ្ញុំបានចេញទៅស្រូបយកខ្យល់អាកាសនៅតាមឆ្នេរសមុទ្រ។ "នៅពេលដែលខ្ញុំទូរសព្ទទៅកាន់បងស្រីខ្ញុំនាពេលបន្ទាប់មក គាត់មានការភិតភ័យ និយាយមិនចង់ចេញ។ គាត់ភ័យញញ័រនៅពេលនិយាយទូរសព្ទ។ ខ្ញុំបានសួរគាត់ថាមានរឿងអ្វីកើតឡើង?" គាត់បានប្រាប់ថា៖ "ខ្មែរក្រហមនៅទីនេះ។ ខ្មែរក្រហមនៅសណ្ឋាគារនេះ។"

នោះគឺ អៀង សារី អតីតមេដឹកនាំខ្មែរក្រហម ដែលបានផ្តាច់ខ្លួន និងចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៦។ បងស្រីរបស់ខ្ញុំមានការបារម្ភចំពោះខ្ញុំ ពីព្រោះថា ខ្ញុំធ្វើការស៊ើបអង្កេតអំពីខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ចំពោះខ្ញុំ ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាអ្នកទាំងនោះនៅតែរំខានដល់បងស្រីខ្ញុំ? ហេតុអ្វីបានជាអ្នកទាំងនោះនៅតែជាការគំរាមកំហែងចំពោះបងស្រីខ្ញុំនិងម្តាយខ្ញុំ ដែលជាជនរងគ្រោះដោយសារអ្នកទាំងនោះ?

នៅពេលដែលខ្ញុំត្រឡប់មកសណ្ឋាគារវិញ មានកងអង្គរក្សនៅពាសពេញ ក៏ប៉ុន្តែដោយសារតែភាគច្រើនបានដឹងថា ខ្ញុំជានរណា អ្នកទាំងនោះអនុញ្ញាតឲ្យខ្ញុំចូលទៅក្នុងសណ្ឋាគារ។ ខ្ញុំបានទៅនិយាយជាមួយបងស្រីនិងម្តាយរបស់ខ្ញុំ។ យើងជាប់នៅក្នុងគុករបស់ខ្មែរក្រហមទៀតហើយ។

នាពេលបន្ទាប់ក្នុងថ្ងៃដដែល ខ្ញុំបានផ្ញើសំបុត្រមួយទៅកាន់ អៀង សារី ដោយស្នើសុំសួរនាំគាត់ទាក់ទងនឹងឯកសារមួយចំនួននៃរបបខ្មែរក្រហម។ នៅម៉ោង១០យប់ ជំនួយការរបស់ អៀង សារី ឈ្មោះ ឡុង នរិន្ទ បានប្រាប់ខ្ញុំឲ្យទូរសព្ទទៅកាន់បន្ទប់របស់គាត់។ ខ្ញុំក៏បានធ្វើតាម។ យើងបានជជែកគ្នាអស់មួយស្របក់។ គាត់បានប្រាប់ខ្ញុំថា ឯកសារទាំងនោះដូចជាត្រឹមត្រូវ ហើយបានអញ្ជើញខ្ញុំទៅកាន់ប៉ៃលិន គឺជាតំបន់មួយស្ថិតនៅឯភាគបស្ចិមនៃប្រទេសកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អៀង សារី។

នៅយប់នោះ ខ្ញុំដេកមិនលក់សោះ។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា នឹងគ្មាននរណាមកគោះទ្វារបន្ទប់របស់ខ្ញុំ។ អារម្មណ៍របស់ខ្ញុំនៅពេលនោះហាក់បីដូចជា "ត្រៀមខ្លួនរួចជាស្រេចដើម្បីតតាំងនិងប្រយុទ្ធ" ដែលបន្សល់ទុកពីរបបខ្មែរក្រហម។ ខ្ញុំប្រាប់ខ្លួនឯងថា ខ្ញុំនឹងមិនឲ្យអ្វីកើតឡើងលើខ្លួនខ្ញុំម្តងទៀតទេ។ ខ្ញុំនឹងមិនឲ្យខ្មែរក្រហមប៉ះពាល់ខ្ញុំ និងក្រុមគ្រួសារទាល់តែសោះ។ ខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីតដៃ ប្រសិនបើមានរឿងអ្វីកើតឡើង។

នៅពេលនោះ ខ្ញុំសរសេរព័ត៌មានលម្អិតអំពីអ្វីដែលខ្ញុំបានជួបប្រទះ ហើយផ្ញើទៅកាន់កាសែត ខេមបូឌា ដេលី ដែលខ្ញុំស្គាល់អ្នកនិពន្ធនៅទីនោះ។ ខ្ញុំគ្រាន់តែចង់ឲ្យគាត់ដឹងអំពីអ្វីដែលបានកើតឡើង ដើម្បីជ្រាបជាដំណឹងទុកជាមុន។

ខ្ញុំភ្ញាក់ឡើងនៅម៉ោង៩ព្រឹក និងចុះទៅជាន់ក្រោមនៃសណ្ឋាគារ តាមការណាត់ជួបរបស់ អៀង សារី ក៏ប៉ុន្តែកន្លែងទទួលភ្ញៀវនៅជាន់នោះទទេស្អាត។ ខ្ញុំបានទទួលនិងរក្សាទុកចំណារមួយ ដែលក្រោយមកខ្ញុំបានប្រគល់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានស្គាល់ថាជា សាលាក្តីខ្មែរក្រហម។

នៅក្នុងចំណារនោះ អៀង សារី និយាយថានឹងរៀបចំពេលជួបខ្ញុំនៅពេលក្រោយ។ គ្រាន់តែជាបុគ្គលវ័យក្មេងម្នាក់ ហេតុអ្វី ខ្ញុំហ៊ានទម្លើះក្នុងការស្រាវជ្រាវអំពីរបបខ្មែរក្រហមរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែបើខ្ញុំចង់ស្រាវជ្រាវពិតមែន ខ្ញុំត្រូវតែទៅកាន់ប៉ៃលិន ដែលជាតំបន់មួយស្ថិតនៅប៉ែកបស្ចិមប្រទេសកម្ពុជា ស្ថិតក្រោមការគ្រប់គ្រងរបស់ អៀង សារី។ ចំណារនោះមានសេចក្តីត្រឹមតែពីរទៅបីបន្ទាត់ប៉ុណ្ណោះ។ ខ្ញុំបានអានចំណារនោះសាចុះឡើងជាងដប់ដង។ តើចំណារនេះគឺជា លិខិតអញ្ជើញ ឬជា លិខិតគំរាម? ពីព្រោះថានៅក្នុងភាសាខ្មែរ នៅពេលដែលអ្នកប្រើប្រាស់គុណនាមចំនួនបីដង នេះសបញ្ជាក់អំពីការគំរាម។ ខ្ញុំមានអារម្មណ៍ក្តៅក្រហាយយ៉ាងខ្លាំង។

នៅពេលដែលក្រុមខ្មែរក្រហមនោះចាកចេញទៅ យើងហាក់បីដូចជាបានចាកផុតពីរបបខ្មែរក្រហមម្តងទៀតអ៊ីចឹង។ មនុស្សម្នានៅក្នុងសណ្ឋាគារញញឹមញញែម និងធូរទ្រូងនៅពេលដែលក្រុមខ្មែរក្រហមចាកចេញទៅបាត់។

នៅតាមផ្លូវត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ ខ្ញុំបានទទួលទូរស័ព្ទពីអ្នកយកព័ត៌មានជាច្រើនរូប។ អ្នកទាំងនោះចង់ទទួលព័ត៌មានពិស្តារអំពីការពើបប្រទះរបស់ខ្ញុំជាមួយនឹង អៀង សារី។ កាសែត ខេមបូឌា ដេលី ពិតជាបានចុះផ្សាយ លិខិតដែលខ្ញុំបានផ្ញើជូនជាដំណឹងនោះមែន។

បន្ទាប់មក ខ្ញុំបានទទួលទូរស័ព្ទពីជនជាតិខ្មែរម្នាក់រស់នៅឯសហរដ្ឋអាមេរិក ដែលគាត់បាននិយាយមកកាន់ខ្ញុំថា “កំសាក ហេតុអ្វីបានជាអ្នកមិនសម្លាប់ អៀង សារី ចោល? អ្នកគួរតែបាញ់សម្លាប់វា”។ បុរសម្នាក់នោះប្រាប់ខ្ញុំថា គាត់បានបាត់បង់ម្តាយ និងសមាជិកគ្រួសារជាច្រើនក្រោមរបបខ្មែរក្រហម។ ខ្ញុំបានតបទៅគាត់វិញថា ដំបូងបង្អស់ ខ្ញុំគ្មានកាំភ្លើងនៅក្នុងដៃទេ ហើយបន្ថែមពីនេះ ខ្ញុំប្តេជ្ញាចំពោះដំណើរការស្វែងរកយុត្តិធម៌។ ខ្ញុំមិនចង់ធ្វើអ្វីដែល អៀង សារី បានធ្វើមកកាន់យើងទាំងអស់គ្នាទេ។

បន្ទាប់ពីខ្ញុំមកដល់ទីក្រុងភ្នំពេញវិញ ខ្ញុំបានឃើញសារព័ត៌មានទាំងអស់បានចុះផ្សាយអំពីការពើបប្រទះរបស់ខ្ញុំជាមួយនឹង អៀង សារី។ ក្រោយមក អៀង សារី ត្រូវបានកាត់ទោសនៅឯសាលាក្តី ខ្មែរក្រហម ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អៀង សារី បានស្លាប់ក្នុងអំឡុងពេលជាប់ឃុំខ្លួនក្នុងឆ្នាំ២០១៣ នៅមុនពេលការចេញសាលក្រមសម្រេចទោស។

នៅក្នុងទសវត្សរ៍ឆ្នាំ២០០០ និងដើមទសវត្សរ៍ឆ្នាំ២០១០ ខ្ញុំឧស្សាហ៍ទៅកាន់ក្រុងព្រះសីហនុ។

ដូចទៅនឹងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនដទៃទៀតដែរ ខ្ញុំនាំបុគ្គលិករបស់ខ្ញុំទៅកាន់ក្រុងព្រះសីហនុក្នុងអំឡុងថ្ងៃឈប់សម្រាក ដើម្បីប្រជុំប្រចាំឆ្នាំ។ ខ្ញុំជួលទូកធំមួយសម្រាប់បុគ្គលិកទាំងអស់ទៅលេងកោះ ដើម្បីធ្វើដំណើរកម្សាន្តផ្សងព្រេង។ យើងហែលទឹកនៅកណ្តាលសមុទ្រ។ បន្ទាប់មកយើងគយគន់ថ្ងៃលិចពាសនឹងផ្ទៃសមុទ្រ។

យើងទាំងអស់គ្នាជានិច្ចកាលតែងស្នាក់នៅទីនោះយ៉ាងតិចចំនួនពីរយប់។ ទីនេះពិតជាស្រស់ស្អាតណាស់ ខ្ញុំចង់ឲ្យបុគ្គលិករបស់ខ្ញុំមើលឃើញទេសភាពនេះ។ នៅពេលនោះ មានកន្លែងស្នាក់នៅដែលធូរថ្លៃជាច្រើន។

ប្រជាជនកម្ពុជាមិនចូលចិត្តស្នាក់នៅក្នុងបន្ទប់តែម្នាក់ឯងនោះទេ។ ខ្ញុំបានជួលបន្ទប់ចំនួនពីរសម្រាប់មនុស្សបួននាក់ ដោយទុកបន្ទប់មួយឲ្យនៅទំនេរចោល។ ប្រជាជនកម្ពុជាចូលចិត្តស្នាក់នៅជុំគ្នា ដើរ

លេងជុំគ្នា, ញ៉ាំរួមគ្នា និងមើលបាល់ទាត់ជាក្រុមៗ ខ្ញុំគិតថាប្រជាជនកម្ពុជានៅតែរួបរួមគ្នាណាស់ ហើយនៅតែជាប់ភ្ជាប់ទៅនឹងដើមកំណើតរបស់ខ្លួន។

ស្របពេលដែលប្រជាជនកម្ពុជាចាប់ផ្តើមធ្វើដំណើរទៅលេងកម្សាន្តក្រុងព្រះសីហនុ យើងសង្កេតឃើញមានគ្រូទាយនៅតាមមាត់សមុទ្រ ក្មេងៗត្រាច់ចរលក់ល្ហុងបុកម្ចាស់ និងមនុស្សធំដើរលក់គ្រឿងសិប្បកម្ម។

ប្រជាជនកម្ពុជាបានស្គាល់ឈុតហែលទឹក និងដើរកម្សាន្តលើ ឆ្នេរខ្សាច់ ពោលគឺ សកម្មភាពដែលត្រូវបានរារាំងដោយសង្គ្រាម និងជម្លោះអស់ជាងពីរទសវត្សរ៍កន្លងមក នៅរវាងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០។

ឆ្នេរខ្សាច់ដ៏អស្ចារ្យនេះ គឺជាកម្មសិទ្ធិរបស់ប្រជាជនកម្ពុជាទាំងអស់។ យើងអាចឃើញការផ្លាស់ប្តូរ។ អ្នកលក់ចាប់ផ្តើមដាក់ព្យួរសម្លៀកបំពាក់សម្រាប់លេងលើឆ្នេរសមុទ្រ និងរបស់របរនានាដែលទាក់ទាញអតិថិជនជាជនជាតិខ្មែរ ជាជាងភ្ញៀវទេសចរ។

ក្រោយមកទៀត អាជ្ញាធរចាប់ផ្តើមចាត់វិធានការរក្សាអនាម័យឆ្នេរសមុទ្រ ដោយតម្រូវឲ្យតូបលក់អាហាររក្សាគម្លាតពីផ្ទៃទឹក។ បន្ទាប់មកទៀត សេវាកម្ម ឡានក្រុងក៏ចាប់ដំណើរការ។

ខ្ញុំតែងតែរំពៃថា បុគ្គលិករបស់ខ្ញុំអាចធ្វើដំណើរទៅកាន់ក្រុងព្រះសីហនុតាមរយៈយន្តហោះពីព្រោះខ្ញុំជឿជាក់ថា ប្រសិនបើប្រជាជនកម្ពុជាអាចមើលឃើញ និងស្វែងយល់ប្រទេសរបស់ខ្លួនតាមដែនសមុទ្រ និងតាមលំហអាកាស អ្នកទាំងនោះនឹងថែទាំ រួមទាំងការពារប្រទេសរបស់ខ្លួន។

ដូច្នេះ ខ្ញុំតែងតែលើកទឹកចិត្តឲ្យបុគ្គលិករបស់ខ្ញុំស្គាល់ពីប្រទេសខ្លួន ដែលជំរុញឲ្យអ្នកទាំងនេះមានស្មារតីការពារប្រទេសជាតិថ្វីត្បិតតែអាចប្រឈមនឹងបញ្ហាខ្លះ ពីព្រោះថាប្រទេសនេះពិតជាស្រស់ត្រកាលជាពន់ពេកណាស់។

សូម្បីនាពេលសព្វថ្ងៃ ខណៈដែលការរឹតបន្តឹងការធ្វើដំណើរក្នុងអំឡុងជំងឺរាតត្បាត កូវីដ-១៩ ត្រូវបានបន្ធូរបន្ថយភ្លាម មនុស្សម្នាអាចធ្វើដំណើរឡើងវិញ ខ្ញុំចាប់ផ្តើមបញ្ជូនបុគ្គលិករបស់ខ្ញុំទៅកាន់ទីតាំងផ្សេងៗជាច្រើនកន្លែង។ ខ្ញុំចង់ប្រាប់ដល់បុគ្គលិកទាំងនេះថា អ្នកត្រូវតែទៅមើលប្រទេសខ្លួន ព្រោះថាប្រទេសនេះ គឺជាប្រទេសរបស់យើងម្នាក់ៗ។

កាលពីប៉ុន្មានសប្តាហ៍មុន គឺនៅក្នុងខែតុលា ឆ្នាំ២០២១ ខ្ញុំសម្រេចចិត្តទៅកាន់ក្រុងព្រះសីហនុជាមួយបុគ្គលិករបស់ខ្ញុំ ដើម្បីមើលឲ្យបានជាក់នូវការផ្លាស់ប្តូរដែលខ្ញុំធ្លាប់បានឮថាកើតមានឡើងនៅក្នុងនិងជុំវិញក្រុង។ ដោយសារតែជំងឺរាតត្បាត កូវីដ-១៩ ខ្ញុំមិនដែលទៅកាន់ទីនេះតាំងពីឆ្នាំ២០១៩មកម៉្លេះ។

នៅពេលខ្ញុំមកដល់ ខ្ញុំមានអារម្មណ៍ទទេស្អាត គឺទទេស្អាតតែម្តង។ ខ្ញុំថប់ដង្ហើម។ អ្វីដែលខ្ញុំធ្លាប់បានស្គាល់អំពីក្រុងព្រះសីហនុ គឺ លែងមានវត្តមានទៀតហើយ។ ខ្ញុំលែងមានអារម្មណ៍ស្រស់ស្រាយទៀតហើយ។

បន្ទាប់មក ខ្ញុំចោទសួរខ្លួនឯងថាតើខ្ញុំកើតអ្វី។ ដំបូងខ្ញុំមិនបានដឹងទេថាមានរឿងអ្វីកើតឡើង។ ពេលដែលរថយន្តបោះពួយទៅមុខ បេះដូងរបស់ខ្ញុំស្ទើរតែលោតចេញក្រៅទ្រូងទៅហើយ។ ខ្ញុំកាន់កាំងដោយព្យាយាមមើលថាតើផ្លូវបំបែកនេះស្ថិតត្រង់កន្លែងណា ហើយផ្លូវនេះឆ្ពោះទៅកាន់ទីណា។ រាល់ទង្វើទាំងអស់សុទ្ធតែចោទជាសំណួរមកកាន់រូបខ្ញុំ។

បន្ទាប់មក ខ្ញុំធុញទ្រាន់នឹងខ្លួនឯង ហេតុអ្វីបានជាខ្ញុំសួរសំណួរច្រើនយ៉ាងនេះ ទីនេះគឺជាក្រុងព្រះសីហនុ។

អគារភាគច្រើនដែលខ្ញុំបានឃើញ មិនទាន់បញ្ចប់ការសាងសង់ និងនៅទំនេរ។ មនុស្សម្នាប្រាប់ខ្ញុំថា ដោយសារតែជំងឺឆ្លង កូវីដ-១៩ វិនិយោគិនដែលភាគច្រើនជាជនជាតិចិនបានចាកចេញ ក៏ប៉ុន្តែកំពុងត្រឡប់មកវិញបណ្តើរៗហើយ។

អគារដែលបានបញ្ចប់ការសាងសង់ជាស្ថាពរ ភាគច្រើនគឺជាសណ្ឋាគារ និងកាស៊ីណូ។ ខ្ញុំដូចជាមិនឃើញមានធនាគារ អគារអន្តរជាតិ និងអគារពាណិជ្ជកម្មទេ។

ខ្ញុំមានអារម្មណ៍ទទេស្អាតទោះបីអគារទាំងនេះស្ថិតនៅត្រៀបត្រាយ៉ាងណាក្តី។ អារម្មណ៍ទទេស្អាតនេះកើតមានដោយសារតែខ្ញុំមានអារម្មណ៍ថា ក្រុងនេះមិនមែនជាក្រុងរបស់ខ្ញុំទៀតឡើយ។ ទីនេះដូចជាទីកន្លែង

មួយផ្សេង មិនមែនស្ថិតនៅក្នុងប្រទេសកម្ពុជា។ ផ្លូវនេះមិនមែនជាអ្វីដែលខ្ញុំធ្លាប់ស្គាល់នោះទេ។

ទោះបីជាយ៉ាងណាក្តី ទីក្រុងនេះ ហាក់ដូចជាប្រើប្រាស់សណ្ឋាននៃប្លង់ហេដ្ឋារចនាសម្ព័ន្ធទីក្រុងចាស់កាលពីអំឡុងទសវត្សរ៍ទី៦០ ដោយគ្រាន់តែពង្រីកទំហំផ្លូវឲ្យទូលាយជាងមុន ដោយវិវឌ្ឍន៍ទៅជាមហាវិថីតែប៉ុណ្ណោះ។

នៅភោជនីយដ្ឋានក្នុងសណ្ឋាគារមួយកន្លែង ជនជាតិចិនហាក់ដូចជានៅប្រមូលផ្តុំតែគ្នាឯង។ បុគ្គលិករបស់ខ្ញុំម្នាក់ដែលចេះភាសាចិន ត្រូវបានរៀបចំឲ្យអង្គុយជាមួយក្រុមជនជាតិចិន ឯយើងវិញបែរជាត្រូវរៀបចំឲ្យអង្គុយនៅកន្លែងមួយផ្សេង។ សូម្បីតែឈើចាក់ធ្មេញនិងក្រដាសអនាម័យ គឺសុទ្ធតែជាទំនិញនាំចូលមកពីប្រទេសចិន។ ជនជាតិចិនទាំងនោះប្រើប្រាស់តែផលិតផលរបស់ខ្លួនប៉ុណ្ណោះ។

គ្មានម្រេចកំពតឬផលិតផលរបស់កម្ពុជា។ អាចនិយាយបានថា នេះកើតមាននៅរយៈកាលដំបូង ហើយអ្នកទាំងនោះអាចនឹងប្រើផលិតផលរបស់កម្ពុជានៅពេលក្រោយៗមក ក៏ប៉ុន្តែកត្តានេះគឺជាអ្វីដែលគួរលើកឡើង។

ចំពោះឆ្នេរសមុទ្រសាធារណៈវិញ នៅមានឆ្នេរសមុទ្រមួយដែលមនុស្សម្នាអាចទៅហែលទឹកបាន តែស្ថិតនៅឆ្ងាយ។ មានមិត្តភក្តិប្រាប់ខ្ញុំថា ឆ្នេរសមុទ្រសាធារណៈត្រូវបានលក់ ហើយក្រុមហ៊ុនដែលទិញយក នឹងអភិវឌ្ឍទៅជាឆ្នេរសមុទ្រឯកជន។

ព័ត៌មានទាំងនេះ គឺជាពាក្យចចាមអារ៉ាម ខ្ញុំរំពឹងថា រាជរដ្ឋាភិបាលកម្ពុជាធានាថានឹងមានឆ្នេរសមុទ្រសាធារណៈនៅក្នុងក្រុងព្រះសីហនុ។ ប្រជាជនកម្ពុជាអាចមានឱកាសកម្សាន្តលេងនៅទីនោះ។

នៅឯសណ្ឋាគារដែលខ្ញុំស្នាក់នៅ បុគ្គលិកជាច្រើនមកពីបណ្តាខេត្តផ្សេងៗក្នុងប្រទេសកម្ពុជា ដើម្បីមកបំពេញការងារ ពីព្រោះថាអ្នកទាំងនេះបានបាត់បង់ការងារធ្វើ ដោយសារតែជំងឺរាតត្បាតកូវីដ-១៩។ អ្វីដែលជាក្តីសង្ឃឹមរបស់អ្នកទាំងនេះ គឺត្រឹមតែអាចបន្តរស់តែប៉ុណ្ណោះ។

តាមអ្វីដែលយើងបានឮ ស្ទើរតែមិនមានបុគ្គលិកការហ៊ឹកហ៊ឺនការងារទាល់តែសោះនៅសណ្ឋាគារ ពីព្រោះភ្ញៀវភាគច្រើនដែលមកលេងល្បែងនៅទីនេះ ត្រូវការតែសេវាកម្មសាមញ្ញប៉ុណ្ណោះ។

អ្នករត់តុម្នាក់តែងឈរសម្លឹងមើលទៅសមុទ្រអណ្តែតអណ្តូង។ នៅពេលដែលខ្ញុំសួរនាំគាត់ គាត់ប្រាប់ខ្ញុំថា គាត់មកពីខេត្តពោធិ៍សាត់ ហើយមិនដែលឃើញសមុទ្រពីមុនមកទេ។

### តើអនាគតរបស់ក្រុងព្រះសីហនុនឹងប្រែទៅជាយ៉ាងណា?

នៅពេលដែលខ្ញុំបំពេញការងារជាបុគ្គលិកត្រួតពិនិត្យការបោះឆ្នោតម្នាក់របស់អ៊ុនតាក់ ខ្ញុំបានជួបជាមួយនឹង គេក ង៉ុយ ដែលបានបង្កើតគណបក្សសាធារណរដ្ឋអភិវឌ្ឍន៍សេរី។ គាត់គឺជាជនជាតិខ្មែរដែលបានរស់នៅឆ្លងកាត់របបខ្មែរក្រហម មកកាន់សហរដ្ឋអាមេរិកក្នុងនាមជាជនភៀសខ្លួននៅក្នុងឆ្នាំ១៩៨៥ រកចំណូលបានកាក់កបពីអាជីវកម្មលក់នំដូណាត់ ចាញ់ល្បែងអស់ពីខ្លួន និងធ្លាប់បានឧបត្ថម្ភដល់ក្រុមគ្រួសារជនភៀសខ្លួនកម្ពុជាជាង១០០គ្រួសារនៅឯសហរដ្ឋអាមេរិក ក្នុងចុងទសវត្សរ៍ឆ្នាំ១៩៨០។ ខ្សែភាពយន្តឯកសារមួយបានថតអំពីខ្សែជីវិតរបស់គាត់មានចំណងជើងថា "ស្តេចនំដូណាត់៖ ដំណើរជីវិតពីគោកយាកទៅជាមានទ្រព្យធនរបស់ជនភៀសខ្លួនក្រីក្រម្នាក់ដែលផ្លាស់ប្តូរពិភពលោក" ត្រូវបានចេញផ្សាយនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ២០២០ និងអាចរកបាននៅតាមប្រព័ន្ធអ៊ីនធឺណែត។

នៅក្នុងអំឡុងយុទ្ធនាការបោះឆ្នោតឆ្នាំ១៩៩៣ គេក ង៉ុយ តែងតែនិយាយថា ប្រសិនបើគាត់ជាប់ឆ្នោត គាត់នឹងអភិវឌ្ឍក្រុងព្រះសីហនុឲ្យដូចជាទីក្រុងហុងកុងមួយទៀត ដែលជាទីក្រុងមួយក្នុងចំណោមទីក្រុងធំៗ ពោរពេញទៅដោយកំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ីអាគ្នេយ៍។

ដោយសារតែ គេក ង៉ុយ និងក្តីស្រមៃរបស់គាត់, ដោយសារតែ អៀង សារី និងភាពភ័យខ្លាចដែល អៀង សារី នាំយកមកវិញ និងដោយសារតែសម្រស់

ដ៏ត្រកាលដែលធ្វើឲ្យខ្ញុំភ្លឹកស្មារតី នៅពេលមើលឃើញឆ្នេរសមុទ្រនៃទីក្រុងនេះដំបូងក្នុងឆ្នាំ១៩៩២ ក្រុងព្រះសីហនុ គឺជាបណ្តុំនៃការចងចាំ និងអារម្មណ៍ដ៏ចម្រូងចម្រាសសម្រាប់រូបខ្ញុំ។

នៅពេលដែលខ្ញុំបានឃើញទិដ្ឋភាពនាពេលថ្មីៗ ក្រុងនេះបានក្លាយជាពិភពលោកថ្មីមួយ ទាំងស្រុង។ ហេតុនេះហើយបានជា ទីក្រុងមួយនេះអន្ទ្រងចិត្តខ្ញុំ នៅពេលដែលខ្ញុំបានទៅដល់នាពេលថ្មីៗកន្លងទៅ។ ទីនេះ គឺជាពិភពលោកថ្មីមួយ ក៏ប៉ុន្តែមិនទាន់អាចកំណត់រូបរាងបាននៅឡើយ។

ទោះបីជាយ៉ាងណាក្តី ខ្ញុំនៅតែអាចរកឃើញផ្លូវទៅកាន់ភ្នំមួយ ដែលខ្ញុំបានឡើងទៅក្នុងពេលទស្សនកិច្ចដំបូងមកកាន់ទីនេះក្នុងនាមជាបុគ្គលិកត្រួតពិនិត្យការបោះឆ្នោតរបស់អ៊ុនតាក់ដដែល។ ភ្នំនេះមិនទាន់ត្រូវបានកែច្នៃនៅឡើយ។ ភ្នំនេះស្ថិតនៅចំកណ្តាលទីក្រុង ក៏ប៉ុន្តែមិនទាន់បានកែច្នៃ។

ប្រសិនបើសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ទ្រង់គង់នៅមានព្រះជន្ម ខ្ញុំឆ្ងល់ថាតើទ្រង់នឹងមានព្រះតម្រិះយ៉ាងដូចម្តេចចំពោះទីក្រុងនេះ។

សម្គាល់៖ ព័ត៌មានស្តីអំពីក្រុងព្រះសីហនុ ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ មានតម្កល់នៅបណ្ណាល័យសម្តេចម៉ែ ដែលបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០២០ ក្រោមជំនួយគាំទ្រពីស្ថានទូតអាមេរិក និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិប្រចាំនៅកម្ពុជា។ ស្ថិតនៅលើផ្លូវលេខ១១៩ ក្នុងចម្ងាយកៀកបង្គើយទៅនឹងវិមានឯករាជ្យ បណ្ណាល័យសម្តេចម៉ែមានតម្កល់ឯកសារជាច្រើនទាក់ទងនឹងសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុជាច្រើនទសវត្សរ៍។

ក្រុងព្រះសីហនុសព្វថ្ងៃ៖ ទិដ្ឋភាពនៃសណ្ឋាគារ និងកាស៊ីណូខ្ពស់ត្រដែតៗ រូបថតដោយ ឆាំង យុ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១។



# សារមន្ទីរសម្តេចព្រះបរមរតនកោដ្ឋ
## នរោត្តម សីហនុ និងសារមន្ទីរព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

*ឆាំង យុ*





*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសារមន្ទីរសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងសារមន្ទីរព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី នៅព្រះបរមរាជវាំង ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។ (ឆាង សុខា ព្រះបរមរាជវាំង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ទូលព្រះបង្គំ សូមសរសេរថ្វាយនូវខ្លឹមសារនេះ ក្នុងគោលបំណងថ្លែងអំណរព្រះគុណដល់ព្រះមហាក្សត្រិយ៍ព្រះវររាជមាតាជាតិខ្មែរ ដែលទ្រង់សព្វព្រះហឫទ័យប្រទានឱកាសដ៏វិសេសវិសាលដល់ទូលបង្គំ ក្នុងការចូលទស្សនាសារមន្ទីរសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងសារមន្ទីរព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ស្ថិតនៅក្នុងបរិវេណនៃព្រះបរមរាជវាំង។ ទស្សនកិច្ចនេះគឺជាបទពិសោធន៍ដ៏ថ្លៃថ្លាសម្រាប់ទូលបង្គំ។ ទូលបង្គំបានឃើញសមុច្ច័យដែលសម្តេចព្រះបរមរតនកោដ្ឋទ្រង់ព្រះលិខិតផ្ទាល់ ដែលពិតជាគួរឲ្យចាប់អារម្មណ៍ចំពោះទូលបង្គំ នៅក្នុងនោះក៏មានភ្ជាប់មកជាមួយនូវលិខិតសរសេរដោយដៃរបស់លោកជំទាវ ចាកឃ្លីន កេណឺឌី នៅក្នុងឆ្នាំ១៩៦៧ មានសេចក្តីថា៖ ថ្វាយជូនព្រះករុណា ព្រះបាទសម្តេចនរោត្តម សីហនុ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំម្ចាស់ ចាកឃ្លីន កេណឺឌី ខែវិច្ឆិកា ឆ្នាំ១៩៦៧។ លោកជំទាវ ចាកឃ្លីន កេណឺឌី គឺជាភរិយារបស់ប្រធានាធិបតីសហរដ្ឋអាមេរិក ចន អេហ្វ. កេណឺឌី និងជាស្ត្រីទីមួយរបស់សហរដ្ឋអាមេរិក នៅរវាងឆ្នាំ១៩៦១ដល់ឆ្នាំ១៩៦៣។*

**ឆាំង យុ**
**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**







*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសារមន្ទីរសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងសារមន្ទីរព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី នៅព្រះបរមរាជវាំង ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។ (ឆាង សុខា ព្រះបរមរាជវាំង/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សុខវរៈ ហៅ យិន យុទ្ធនារីនៅសាធារណៈការដឹកជញ្ជូនថ្ម

ដារ៉ារដ្ឋ មេត្តា



កសិករសហករណ៍នៅស្រុកភ្នំសំពៅ ដឹកជញ្ជូនបាយអយកទៅចាក់គ្រឹះទំនប់ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុខវរៈ ហៅ យិន អាយុ២០ (នៅឆ្នាំ១៩៧៧)។ ខ្ញុំមានស្រុកកំណើតនៅភូមិកណ្តាល ឃុំគោកឃ្មុំ ស្រុកសង្កែ (បច្ចុប្បន្នស្រុកថ្មគោល) ខេត្តបាត់ដំបង។ ពេលខ្ញុំមានអាយុ៧ឆ្នាំ ខ្ញុំចូលរៀននៅសាលាគោកឃ្មុំ រហូតដល់ថ្នាក់ទី៨។ នៅក្នុងឆ្នាំ១៩៧០ ខ្ញុំឈប់រៀនមកជួយលក់អីវ៉ាន់ម្តាយ និងឪពុកចុងនៅផ្សារគោកឃ្មុំ។ ខ្ញុំជួយលក់អីវ៉ាន់ម្តាយខ្ញុំរហូតដល់ឆ្នាំ១៩៧២។ បន្ទាប់ពីម្តាយរបស់ខ្ញុំស្លាប់ទៅ ខ្ញុំនៅរស់នៅជាមួយឪពុកចុងឈ្មោះ ជុំ ហ៊ុំ គឺជាគ្រូបង្រៀននៅសាលាគោកឃ្មុំ។ ក្រោយមកនៅក្នុងឆ្នាំ១៩៧៤ ខ្ញុំសុំឪពុកចុងមករស់នៅជាមួយឪពុកបង្កើត ឈ្មោះ សុក ឌី គឺជាអ្នកបើកឡាននៅរដ្ឋសភាពាក់ស័ក្តិ៣។ ឪពុកបង្កើតរបស់ខ្ញុំបើកឡានឲ្យឈ្មោះ អ៊ុង ប៊ុនហោ គឺជាប្រធានរដ្ឋសភា។ ពេលខ្ញុំមករស់នៅជាមួយឪពុកបង្កើត ខ្ញុំទទួលបានការអប់រំពីគាត់គឺឲ្យខ្ញុំប្រឆាំងជាមួយបដិវត្តន៍។ ឪពុកបង្កើតរបស់ខ្ញុំបានលើកឡើងកុំឲ្យខ្ញុំចូលរួមជាមួយរណសិរ្ស ព្រោះក្រុមនេះរស់នៅគ្មានសិទ្ធិ សេរីភាព មានតែរដ្ឋាភិបាល

*លន់ នល់ តែប៉ុណ្ណោះដែលរស់នៅមានសេរីភាព អាចស៊ីចាយសប្បាយ ហ៊ឺហារ។ ឪពុកបង្កើតរបស់ខ្ញុំបានដាក់ភារកិច្ចឲ្យខ្ញុំយាមការពារ ឡានមិនឲ្យនរណាចូលមកជិតឡើយ ព្រោះខ្លាចក្រុមរណសិរ្សយកគ្រាប់បែកមកដាក់ក្នុងឡានដើម្បីបំផ្ទុះ។*

*ក្រោយរំដោះបានទីក្រុងភ្នំពេញឆ្នាំ១៩៧៥ ខ្ញុំត្រូវបានជម្លៀសទៅតាខ្មៅជាមួយឪពុកបង្កើតរបស់ខ្ញុំ។ ខ្ញុំបានចុះឈ្មោះចូលធ្វើជាកម្មករនៅរោងចក្រកៅស៊ូកង់ឡាន។ ក្រោយមកអង្គការបញ្ជូនខ្ញុំមកនៅមន្ទីរនារីនៅតាខ្មៅដដែល។ នៅខែកញ្ញា ឆ្នាំ១៩៧៥ ដដែល អង្គការចាប់ឪពុករបស់ខ្ញុំ ចំណែកខ្ញុំអង្គការបានចាត់តាំងឲ្យមកធ្វើការនៅរោងចក្រទឹកនៅជ្រោយចង្វារវិញ។*

*នៅខែមករា ឆ្នាំ១៩៧៦ ខ្ញុំទទួលបានការអប់រំពីឈ្មោះ អឿន គឺជាអនុប្រធានរោងចក្រទឹក។ អឿនលើកឡើងថា «ឥឡូវមិត្តឃើញហើយអ្នកបដិវត្តន៍ស្អប់យើងណាស់ យើងខិតខំធ្វើការយ៉ាងណា គេនៅតែមិននិយាយស្តីមករកយើង ដូច្នេះមិត្តត្រូវតែមានការឈឺចាប់»។ បន្ទាប់មក ខ្ញុំបានចូលរួមធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ជាមួយឈ្មោះ គង់, ផល្លា, ហៀក ដោយបានយកថ្នាំអង់គ្រីនទៅដាក់ក្នុងបាយសម្លឲ្យកម្មាភិបាលហូប។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំរួមជាមួយមិត្តនារីដែលជាខ្សែក្បត់បានបំផ្លាញមាន់អស់ចំនួន២០ក្បាល, ទា២០ក្បាល និងជ្រូក៥ក្បាល។ នៅខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំរួមជាមួយធី, ផល្លា, គង់, ហៀក បានយកទឹកទៅចាក់លាយសាំង។ នៅខែកក្កដា ឆ្នាំ១៩៧៦ ខ្ញុំរួមជាមួយនារី៤នាក់ទៀតបំផ្លាញម៉ាស៊ីនកាណូតអស់ចំនួន១គ្រឿង។ បន្ទាប់មកខ្ញុំនិងនារីបួននាក់បានយកថ្នាំពុលទៅលាយទឹកឲ្យគោផឹកងាប់គោអស់ចំនួន៥ក្បាល គឺគោញីពីរក្បាល និងឈ្មោលបីក្បាល។*

*នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំចូលរួមជាមួយឈ្មោះ ឌី, គង់ និង ធី ដុតផ្ទះនៅជិតរោងចក្រទឹកជ្រោយចង្វារ ឆេះអស់ចំនួនមួយខ្នង។ នៅខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានផ្លាស់ខ្ញុំឲ្យទៅ រុញថ្មនៅត្រពាំងក្រឡឹងក្នុងស្រុកខដុង្គ។ នៅទីនោះ ខ្ញុំកសាងកម្លាំងបាន ៥នាក់ ដែលសុទ្ធតែនារីកម្មករចាស់ មានឈ្មោះ ធា, ដា, ខន, ហេង និង ខា។ ពេលដែលខ្ញុំទៅធ្វើការនៅទីនោះខ្ញុំដាច់ការទាក់ទងជាមួយឈ្មោះ អឿន ដែលជាកម្លាំងចាស់។ នៅខែសីហា ឆ្នាំ១៩៧៧ ខ្ញុំបានរើសគ្រាប់បែកពីរគ្រាប់យកទុកដាក់នៅគំនរសំរាមក្បែរថ្នល់ ដើម្បីឲ្យមិត្តយើងដើរបុកបាប់ចំផ្ទុះ។ ខ្ញុំបានធ្វើសកម្មភាពនេះជាមួយឈ្មោះ ដា, ហេង, ធា, ធី និង មោង។ ដល់ថ្ងៃទី២៣ ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំតែម្តង។*



*កសិករសហករណ៍ នៅស្រុកភ្នំមន្ត្រលបូរីក្នុងភូមិភាគពាយ័ព្យកំពុងធ្វើប្រព័ន្ធសំណង់ចាត់ចែងទឹក (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*កំណត់ចំណាំ៖ ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD៥៩៦៥៦។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ សុខវរៈ ហៅ យិន ពិតប៉ុណ្ណាណានោះទេ។*

# ការងារនៅតាមសហករណ៍ក្នុងរបបខ្មែរក្រហម

ងីម សុខគា



យួន ឃីមម៉ន ហៅ យួន ថុន អាយុ៦៧ឆ្នាំ រស់នៅក្នុងភូមិត្រាច ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខែតុលា ឆ្នាំ២០២១។
(ងីម សុខគា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យួន ឃីមម៉ន មានឈ្មោះក្រៅហៅថា យួន ថុន អាយុ៦៧ឆ្នាំ កើតនៅឆ្នាំ១៩៥៤ នៅក្នុងភូមិត្រាច ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ។ ឪពុករបស់ខ្ញុំឈ្មោះ យួន ខែម និងម្តាយឈ្មោះ ម៉ម សែត។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន៦នាក់ ក្នុងនោះមានស្រី៤នាក់ និងប្រុស២នាក់។ បច្ចុប្បន្នខ្ញុំមានកូន៦នាក់ ស្រី៤នាក់និងប្រុស២នាក់ រស់នៅក្នុងភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ដែលជាស្រុកកំណើតរបស់ប្រពន្ធខ្ញុំ។

កាលពីសង្គមចាស់ ខ្ញុំបានរៀននៅសាលាបឋមសិក្សាហើយប្រឡងជាប់ឌីប្លូមនៅសាលាស្វាយព្រៃកៅ ឌិន។ ក្រោយមកដោយសារស្ថានភាពនៅក្នុងភូមិចលាចល ខ្ញុំលែងបានទៅសាលារៀនទៀត។ នៅដើមឆ្នាំ១៩៧០ មានការធ្វើបាតុកម្មនៅព្រៃស្លែកដែលបណ្តាលឲ្យស្លាប់មនុស្សអស់ជាច្រើននាក់ ព្រោះពេលនោះកងទ័ពរំដោះខ្មែរក្រហម និងកងទ័ព លន់ នល់ កំពុងមានជម្លោះនឹងគ្នា និងដណ្តើមគ្រប់គ្រងលើប្រជាជន។ ខ្ញុំកាលនោះត្រូវបានខ្មែរក្រហមជម្លៀសចេញពីឃុំស្រែរនោងរហូតមកដល់ស្តុក, សម្ពាញ, អង្គរជ័យ ហើយក្រោយមកខ្មែរក្រហមឲ្យមកនៅម្តុំវត្តជ្រៃ។ ព្រឹត្តិការណ៍ពេលនោះគឺគួរឲ្យភ័យខ្លាចណាស់ ព្រោះ មានការបាញ់រះ និងទម្លាក់គ្រាប់បែកដើម្បីឲ្យប្រជាជនជម្លៀសពីស្រុកភូមិទៅកន្លែងផ្សេងៗ ។

នៅក្នុងកំឡុងឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាច ប្រជាជននៅភូមិឃុំត្រូវបានប្រមូលផ្តុំជាសមូហភាពដោយខ្មែរក្រហមឲ្យហូបបាយរួម, រស់នៅរួម និងធ្វើការងាររួម។ របស់របររបស់ប្រជាជន ដូចជាស្រូវ អង្ករ រួមទាំងទ្រព្យសម្បត្តិទាំងអស់ត្រូវបានខ្មែរក្រហមយកទៅដាក់នៅសហករណ៍ធ្វើជាកម្មសិទ្ធិរួម។ កាលនោះខ្មែរក្រហមជម្លៀសប្រជាជនពីទីក្រុងមករស់នៅតាមទីជនបទវិញ។ ប្រជាជនជម្លៀសជាច្រើនបាន

ចូលមករស់នៅក្នុងភូមិរបស់ខ្ញុំ រួមមានទាំងបងថ្លៃរបស់ខ្ញុំឈ្មោះ ណៃ សាមិត្ត។ បងថ្លៃរបស់ខ្ញុំគឺជានិស្សិតពេទ្យនៅភ្នំពេញ និងមិនទាន់បានប្រឡងចូលក្របខណ្ឌឡើយ។ ប្រជាជនដែលជម្លៀសមករស់នៅក្នុងភូមិមួយចំនួនត្រូវបានខ្មែរក្រហមជម្លៀសបន្តឲ្យទៅរស់នៅកន្លែងផ្សេងៗពីគ្នា។ ការជម្លៀសនេះគឺខ្មែរក្រហមបែងចែកទៅតាមសហករណ៍ប្រភេទទី១ ទី២ និងទី៣។ សហករណ៍ប្រភេទទី១ គឺសម្រាប់ប្រជាជនពេញសិទ្ធិ ឬប្រជាជនមូលដ្ឋានដោយសារប្រជាជនទាំងនេះមិនជាប់ពាក់ព័ន្ធជាមួយ ទាហាន លន់ នល់ និងជាកសិករក្រីក្រ ធ្វើស្រែចម្ការ គ្មានប្រវត្តិសិក្សាបានច្រើន។ ប្រជាជននៅសហករណ៍ទី១នេះ មិនសូវលំបាកទេ អ្នកទាំងនេះមានសិទ្ធិតាមដាន និងចាប់កំហុសប្រជាជននៅសហករណ៍ទី២ និង ទី៣។ ប្រជាជននៅសហករណ៍ទី២ និងទី៣ គឺជាប្រជាជនមិនពេញសិទ្ធិ ឬហៅថា ប្រជាជនថ្មីដោយសារអ្នកទាំងនេះធ្លាប់ជាប់ពាក់ព័ន្ធជាមួយ ទាហាន លន់ នល់ និងមានតួនាទីការងារធំ រស់នៅភ្នំពេញ ព្រមទាំងជាអ្នកមានការសិក្សាបានខ្ពង់ខ្ពស់។ អ្នកទាំងនេះ គឺខ្មែរក្រហមចាត់តាំងឲ្យធ្វើការងារហួសកម្លាំង មិនឲ្យអាហារហូបគ្រប់គ្រាន់ និងទទួលការរើសអើងពីប្រជាជនមូលដ្ឋាន។ ប្រសិនបើប្រជាជនថ្មីមានកំហុស ខ្មែរក្រហមនឹងយកទៅធ្វើទារុណកម្ម ឬយកទៅសម្លាប់ចោលតែម្តង។ ចំពោះកន្លែងដែលខ្មែរក្រហមយកទៅឃុំ គឺនៅគុកក្រាំងតាចាន់ដែលជាកន្លែងធ្វើទារុណកម្មបង្អត់អាហារ និងជាកន្លែងសម្លាប់មនុស្ស។

ខ្ញុំត្រូវបានខ្មែរក្រហមបែងចែកឲ្យទៅនៅសហករណ៍ទី២ ដោយសារតែខ្ញុំជាប់ពាក់ព័ន្ធជាមួយបង ណៃ សាមិត្ត ដែលជានិស្សិតពេទ្យនៅភ្នំពេញ។ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅរស់នៅភូមិមហាសេនា ដោយមិនឲ្យរស់នៅក្នុងភូមិត្រពាំងស្វាយឡើយ។ ប្រធានសហករណ៍របស់ខ្ញុំឈ្មោះ សុខ។ គាត់មិនសូវកាចទេ ប្រសិនបើគាត់កាចនោះ ខ្ញុំ និងបងថ្លៃរបស់ខ្ញុំក៏គ្មានជីវិតអាចរស់បានដល់សព្វថ្ងៃនេះដែរ។ ខ្ញុំមិនបានរស់នៅជួបជុំជាមួយគ្រួសារនោះទេ ដោយសារប្រធានសហករណ៍ប្រើខ្ញុំធ្វើការងារគ្មានពេលសម្រាកឡើយ គឺនៅរដូវវស្សា ខ្ញុំត្រូវទៅភ្ជួរស្រែ និងកាប់កាស់ដីដាំដំណាំ។ ដូនកាលខ្ញុំទៅធ្វើការនៅស្រុកក្រោម ឬវាលទំនាប ហើយដូនកាលទៅធ្វើការនៅព្រៃលើភ្នំ។ នៅខែស្ពួង ប្រធានកងដាស់ខ្ញុំឲ្យងើបទៅភ្ជួរដីតាំងពីម៉ោង១១យប់ គឺប្រើឲ្យធ្វើការគ្មានពេលសម្រាកឡើយ។ កាលនោះមានមិត្តភក្តិរួមកងរបស់ខ្ញុំមួយចំនួនបានដួលសន្លប់នៅកន្លែងធ្វើការតែម្តង ព្រោះតែធ្វើការងារហួសកម្លាំង ហើយអាហារក៏មិនបានហូបគ្រប់គ្រាន់។ ចំណែករដូវប្រាំងប្រធានកងឲ្យខ្ញុំជីកប្រឡាយ រែកដី នៅតាមការដ្ឋានផ្សេងៗ។

នៅពេលមានការប្រជុំធំៗម្តងៗ ខ្មែរក្រហមមិនដែលឲ្យយើងចូលរួមប្រជុំទេ ព្រោះការងាររបស់ខ្មែរក្រហមផ្ទាក់លើសុទ្ធតែលាក់ការណ៍ទាំងអស់។ ខ្ញុំត្រឹមតែទទួលការងារបន្តពីប្រធានកងប៉ុណ្ណោះ។ ប្រសិនបើប្រធានកងដាក់ផែនការជីកប្រឡាយ ខ្ញុំត្រូវតែជីកប្រឡាយ បើធ្វើស្រែត្រូវទៅធ្វើស្រែ និងធ្វើការកាប់កាស់ដីដាំដំណាំ ពោត ដំឡូង និងដំណាំផ្សេងៗទៀត។ នៅពេលមានប្រជុំជាក្រុមតូចៗ ជាប្រធានក្រុមតែងតែប្រាប់ដល់សមាជិកក្នុងកងឲ្យខិតខំធ្វើការយ៉ាងណាឲ្យបានល្អ។ ចំពោះការងារគឺខ្ញុំត្រូវធ្វើតាមផែនការ ប៉ុន្តែអាហារ ចុងភៅមិនដែលឲ្យយើងហូបគ្រប់គ្រាន់ទេ។ ខ្ញុំទទួលបានរបបអាហារតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ គឺពេលថ្ងៃ និងពេលល្ងាច ចំណែកឯពេលព្រឹកគឺគ្មានបាយសូម្បីតែមួយគ្រាប់។ ខ្ញុំមើលអង្ករឃើញមានពេញៗឃ្លាំង ប៉ុន្តែខ្មែរក្រហមមិនឲ្យយើងហូបឆ្អែតទេ គឺឲ្យហូបបបរខាប់លាយជាមួយសម្លព្រលឹតប៉ុណ្ណោះ។ ប្រសិនបើយើងឈឺ ខ្មែរក្រហមឲ្យយើងទៅសម្រាកនៅពេទ្យ ហើយពេទ្យនឹងផ្តល់អាហារឲ្យយើងហូប។ កាលនោះខ្ញុំធ្លាប់ឈឺម្តង ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅសម្រាកនៅពេទ្យ។ នៅពេលដែលខ្ញុំក្រោកពីដេក គឺមានតែ

បបរប្រមាណ៣ ទៅ ៤ស្លាបព្រាដែលពេទ្យទុកឲ្យខ្ញុំហូប។ ទោះខ្ញុំហូបឬមិនហូប ក៏ពេទ្យមិនខ្វល់ពីខ្ញុំដែរ។ ពេលនោះខ្ញុំខំប្រឹងហូបបបរដើម្បីមានកម្លាំងបន្តជីវិតទៅទៀត ព្រោះខ្ញុំគិតថាបើខ្ញុំមិនហូបទេច្បាស់ជាស្លាប់ដោយសារអត់ឃ្លានមិនខាន។

នៅអំឡុងឆ្នាំ១៩៧៦ ខ្ញុំឃើញប្រជាជនមួយចំនួនភៀសខ្លួនទៅប្រទេសវៀតណាមដោយសារអ្នកទាំងនោះដឹងថា នឹងត្រូវស្លាប់បើបន្តរស់នៅប្រទេសកម្ពុជាទៀត។ អ្នកទាំងនោះភាគច្រើនគឺជាអ្នកដែលចេះដឹង ជាមន្ត្រីនៅក្នុងសង្គមចាស់ និងអ្នកជាប់ពាក់ព័ន្ធជាមួយទាហាន លន់ នល់។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៩ មានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាមជាមួយនឹងកងទ័ពខ្មែរក្រហម។ នៅពេលនោះខ្ញុំធ្វើការនៅកំពង់យោល។ ខ្ញុំឃើញមានការទម្លាក់គ្រាប់បែក និងបាញ់ផ្លោងដាក់គ្នាទៅវិញទៅមកបង្កឲ្យមានមនុស្សស្លាប់អស់ជាច្រើននាក់។ អ្នកដែលស្លាប់ទាំងនោះត្រូវបានខ្មែរក្រហមដឹកយកទៅកប់ទាំងយប់។ អ្នកដែលស្លាប់សុទ្ធតែជាបងប្អូនខ្មែរដែលខ្មែរក្រហមចាប់យកទៅធ្វើកងទ័ព។ ខ្ញុំបានបាត់បង់បងប្រុសបង្កើតម្នាក់ និងបងថ្លៃម្នាក់ឈ្មោះ ណៃ វ៉ាន់ណា ដែលខ្មែរក្រហមចាប់យកទៅធ្វើកងទ័ព។ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំនិងប្រជាជនបានមករស់នៅក្នុងភូមិឃុំរៀងៗខ្លួន។



ជឹម សុខគា និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ ប្រគល់កញ្ចប់អនុស្សាវរីយ៍ជូន ឃួន ឃឹមម៉ឺន រស់នៅក្នុងភូមិត្រាច ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខែតុលា ឆ្នាំ២០២១។ (ជឹម សុខគា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដោយសារតែភាពក្រិន ប្រធានកងឱ្យខ្ញុំនៅកងកុមាររហូតដល់អាយុ១៧ឆ្នាំ

ហួ ស៊ីណាត



ហួ ស៊ី ណាត (ខាងឆ្វេង) និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្ភាសន៍ យិន អឿន ភេទប្រុស អាយុ៦១ឆ្នាំ រស់នៅភូមិព្រៃតាខាប ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម។ ខែតុលា ឆ្នាំ២០២១។ (ហួ ស៊ីណាត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យិន អឿន ភេទប្រុស អាយុ៦១ឆ្នាំ កើតនៅភូមិព្រៃតាខាប ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ព្រំ អៀម ស្លាប់តាំងតែពីខ្ញុំកើតបាន៣ខែ និងមានម្តាយឈ្មោះ ប្រៀប សឿង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ (ប្រុស២នាក់ និងស្រី២នាក់) ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ប៉ែន ខន អាយុ៦១ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នា ហើយយើងមានកូនចំនួន៤នាក់ (ប្រុស១នាក់ និងស្រី៣នាក់)។

កាលពីនៅកុមារ ខ្ញុំរៀនដល់ថ្នាក់ទី១០សង្គមចាស់។ នៅសម័យនោះមិនសូវមានសាលាសម្រាប់ក្មេងៗចូលរៀនទេគឺសិស្សត្រូវរៀននៅសាលាវត្តលោក។ ខ្ញុំបានចូលរៀននៅវត្តនិគ្រោធារាម ដែលស្ថិតនៅក្នុងភូមិត្រពាំងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ នៅសម័យនោះ ប្រជាជននៅក្នុងភូមិឃុំរបស់ខ្ញុំរស់នៅសុខសប្បាយដោយមិនមានសង្គ្រាមឡើយ។ បន្ទាប់មក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់

សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែងបណ្ដាលឲ្យប្រជាពលរដ្ឋរត់ចូលព្រៃតស៊ូជាមួយខ្មែរក្រហម ប្រជាជនខ្លះទៀតចូលធ្វើជាឈ្លបការពារភូមិ ខ្លះទៀតកាន់អាវុធដើម្បីប្រឆាំងនឹង លន់ នល់។ នៅពេលនោះ ខ្ញុំនៅកុមារនៅឡើយ។

នៅក្នុងភូមិឃុំរបស់ខ្ញុំ ខ្មែរក្រហមចាប់ផ្ដើមបង្កើតឲ្យមានរចនាសម្ព័ន្ធដឹកនាំតាមមូលដ្ឋានរំដោះចាប់តាំងពីឆ្នាំ១៩៧៣មក រួមមាន រចនាសម្ព័ន្ធបក្ស ការរៀបចំកិច្ចការសម្ងាត់ និងស៊ើបការណ៍ជាដើម។ ខ្មែរក្រហមយកទីតាំងមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ បច្ចុប្បន្នធ្វើជាកន្លែងសម្រាប់ប្រជុំកិច្ចការសំខាន់ៗ ប៉ុន្តែមិនទាន់មានការឃុំឃាំង និងសម្លាប់មនុស្សនៅឡើយ។ ចាប់តាំងពីឆ្នាំ១៩៧៥ ខ្មែរក្រហមចូលគ្រប់គ្រង និងជម្លៀសប្រជាជនចេញពីទីក្រុងមកកាន់ទីជនបទដើម្បីធ្វើស្រែចម្ការ នៅពេលនោះមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់បានប្រែក្លាយទៅជាកន្លែងសម្រាប់ឃុំឃាំង កន្លែងសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់មនុស្ស។ ខ្មែរក្រហមបែងចែកប្រជាជនឲ្យរស់នៅក្នុងសហករណ៍ ហើយ បុរស ស្ត្រី ក្មេង ចាស់ ប្រុស ស្រី រួមជាមួយប្រជាជនថ្មី (ប្រជាជន១៧ មេសា) ធ្វើការងារផ្សេងៗគ្នា។ កាលនោះ ខ្ញុំមានអាយុ១៧ឆ្នាំ ប៉ុន្តែដោយសារតែខ្ញុំមានរូបរាងតូចល្អិត (ក្រិន) ទើបប្រធានកងខ្មែរក្រហមចាត់តាំងឲ្យខ្ញុំរស់នៅ និងធ្វើការនៅក្នុងកងកុមារ។ នៅសម័យនោះ ប្រជាជនថ្មី (ប្រជាជន១៧ មេសា) ធ្វើការងារលំបាកជាងប្រជាជនចាស់ (ប្រជាជនមូលដ្ឋាន)។ ក្នុងចំណោមប្រជាជនដែលខ្មែរក្រហមបានជម្លៀសមកពីទីក្រុង ខ្ញុំឃើញ ណុប ណែម និង គីម ណូវ៉ា គឺជាតួកុនរួមទាំងប្រជាជនជាច្រើននាក់ទៀត។ ខ្មែរក្រហមចងអ្នកទាំងនោះជាខ្សែដែលមានបណ្ដោយប្រមាណ២០០ម៉ែត្រ បណ្ដើរមកកាន់គុកក្រាំងតាចាន់។

ចេញពីកងកុមារ ខ្ញុំទៅរស់នៅកងយុវជន។ ខ្មែរក្រហមប្រើឲ្យខ្ញុំធ្វើការងាររែកដី ធ្វើស្រែគ្មានពេលសម្រាក និងផ្ដល់អាហារឲ្យខ្ញុំហូបមិនសាកសមនឹង



ផ្ទះរបស់ ឃិន អឿន នៅភូមិព្រៃតាខាប ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ខែតុលា ឆ្នាំ២០២១។ (ហួ ស៊ីណាត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពលកម្មឡើយ។ បបរមួយខ្ទះធំ ចុងភៅដាក់អង្ករតែពាកំប៉ុងប៉ុណ្ណោះ។ ចុងភៅចែកបបរឲ្យខ្ញុំមួយពេលតែមួយវែកប៉ុណ្ណោះ បណ្តាលឲ្យខ្ញុំបាក់កម្លាំងរហូតដល់ខ្ញុំគិតថាខ្ញុំមិនមានជីវិតរស់នៅតទៅទៀតឡើយ ព្រោះការងារធ្ងន់ពេក និងធ្វើឲ្យខ្ញុំមានជំងឺញ័ររហូតមកដល់សព្វថ្ងៃ។ មូលហេតុដែលខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការងារធ្ងន់ធ្ងរ ព្រោះតែបងប្អូនរបស់ខ្ញុំពីរនាក់ម្នាក់ឈ្មោះ យោកគ្រីត និងម្នាក់ទៀតឈ្មោះ ព្រំគ្រីរត់ទៅប្រទេសវៀតណាម ហើយត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួនបាននៅភូមិតាលាក់ រួចហើយសម្លាប់អ្នកទាំងពីរចោល។ មេកងរបស់ខ្ញុំគឺជាមនុស្សដែលមានចរិកកាចសាហាវ។ នៅពេលដែលប្រជាជនប្រព្រឹត្តកំហុស មេកងនាំយកទៅសម្លាប់ដោយមិនត្រាប្រណីឡើយ។ ប្រជាជនមិនអាចលួចហូបអាហារបានទេ សូម្បីតែហូបបាយហើយធ្វើឲ្យបាក់ស្លាបព្រាមួយក៏មានទោសដែរ។ ប្រសិនបើប្រជាជនហ៊ានលួចអាហារហូប ឈ្លបនឹងចាប់ខ្លួននាំយកមកកុកក្រាំងតាចាន់ ដើម្បីធ្វើទារុណកម្ម និងសម្លាប់ចោលមិនខាន។ ក្រោយពីសម្រាកពីការងារ មេកងហៅប្រជាជនមកប្រជុំដើម្បីនិយាយពីការខិតខំធ្វើការងារឲ្យបានល្អ និងឲ្យអង្គការពេញចិត្ត។ ម៉ោង១១យប់ទើបខ្ញុំបានសម្រាក ហើយត្រូវក្រោកម៉ោង៣ទៀបភ្លឺដើម្បីធ្វើការងារបន្តទៀត។ នៅក្នុងឃុំដែលខ្ញុំរស់នៅគឺមានការដ្ឋានចំនួនពីរ។

ក្រោយមក ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំចូលធ្វើជានីរសារ ដោយសារតែខ្ញុំចេះជិះសេះ។ ខ្ញុំយកសំបុត្រពីគុកក្រាំងតាចាន់ទៅកាន់ភូមិត្រពាំងព្រីងខាងលិច ដែលជាកន្លែងស្នាក់ការ។ ខ្ញុំធ្វើការងាររត់សំបុត្រនេះតែម្នាក់ឯងប៉ុណ្ណោះ។ ខ្ញុំឃើញខ្មែរក្រហមធ្វើទារុណកម្ម សួរចម្លើយប្រជាជន និងសម្លាប់ចោល។ ខ្មែរក្រហមយកដែកឃ្នាបមកៀបដៃអ្នកទោសដើម្បីសួរចម្លើយ យកត្បូងចបមកវាយ យកខ្សែរឹតក និងយកចំពុះទុងមកចាក់អ្នកទោស។ ប្រធានគុកក្រាំងតាចាន់មានឈ្មោះ អោម អាន។ ខ្ញុំមើលឃើញពីការធ្វើទារុណកម្ម ការសួរចម្លើយ និងសម្លាប់មនុស្សរយៈពេលមួយឆ្នាំ។ អ្នកសួរចម្លើយនិងសម្លាប់មនុស្ស មានគ្នាចំនួនបីនាក់ ដែលក្នុងចំណោមនោះខ្ញុំបានស្គាល់ឈ្មោះ មឿន។ មឿន និងបក្ខពួករស់នៅក្នុងភូមិព្រៃតាខាប ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ក្រោយមកទៀតប្រធានគុកខ្មែរក្រហមជ្រើសយកមនុស្សដែលជាប់ទោសនៅទីនោះ ដើម្បីជួយធ្វើទារុណកម្មអ្នកទោសផ្សេងទៀត។ អ្នកសួរចម្លើយ និងសម្លាប់អ្នកទោសទាំងអស់នោះ បានស្លាប់នៅពេលរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩។

ខ្ញុំ និង តាឆេន អនុប្រធានគុកក្រាំងតាចាន់ សម្រេចចិត្តឈប់ធ្វើការងារ ព្រោះតែមិនអាចទ្រាំឃើញការធ្វើបាបប្រជាជន ការធ្វើទារុណកម្ម និងការសម្លាប់មនុស្សទៀត ហើយម្យ៉ាងទៀតខ្មែរក្រហមលែងទុកចិត្តយើងទាំងពីរនាក់។ សព្វថ្ងៃ ឆេនប្តូរទៅរស់នៅស្រុកអន្លង់វែង។ ក្រោយមក ខ្ញុំបានចូលធ្វើជាកងទ័ពឈរជើងនៅភ្នំដិន ក្នុងស្រុកគិរីវង្ស។ នៅទីនោះមានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ កងទ័ពខ្មែរក្រហមមានបីកងពល កងពលទី១០ កងពលទី៣០ និងកងពលទី៥០ ដោយមានមេបញ្ជាការរបស់ខ្ញុំឈ្មោះ តាមុត។ នៅចុងឆ្នាំ១៩៧៨ មានការប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាមនៅស្ពានស្វាគូបណ្តាលឲ្យស្លាប់កងទ័ពខ្មែរក្រហមអស់ជាច្រើននាក់។ ខ្មែរក្រហមបានរត់ចូលព្រៃអស់ ចំណែកខ្ញុំវិលត្រឡប់មកភូមិកំណើតវិញ។ ស្ថានភាពគ្រួសាររបស់ខ្ញុំក្រោយឆ្នាំ១៩៧៩ មានការលំបាកព្រោះតែនៅធ្វើស្រែរួម ហើយនៅពេលបានផលយើងត្រូវចែកគ្នា។ ខ្ញុំហូបមិនបានគ្រប់គ្រាន់ក៏ដើររកអាហារតាមស្រុកផ្សេងៗ។ រំលងបានពីរឆ្នាំក្រោយមកទើបខ្ញុំមានស្រែ និងធ្វើស្រែបានហូបគ្រប់គ្រាន់វិញ ហើយខ្ញុំរស់នៅជុំគ្រួសារសុខសាន្តចាប់តាំងពីពេលនោះមក។

# យឹង យុយ ៖ ខ្មែរក្រហមយកខ្ញុំទៅអប់រំច្រើនដង ប៉ុន្តែសំណាងល្អនៅរស់ជីវិត

*កាន់ សុខភាព*




កាន់ សុខភាព (ខាងឆ្វេង) និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ ប្រគល់កញ្ចប់អនុស្សាវរីយ៍ជូន យឹង យុយ (ខាងស្តាំ) រស់នៅភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ ខែតុលា ឆ្នាំ២០២១។
(ញ៉ាញ់ ធីប/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យឹង យុយ កើតនៅឆ្នាំ១៩៤៦។ សព្វថ្ងៃខ្ញុំរស់នៅភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ឡាង យឹង ម្តាយឈ្មោះ ណើ អង់។ ខ្ញុំមានបងប្អូន៨នាក់ ប្រុស៥នាក់ និងស្រី៣នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ម៉ី លៀង មានអាយុ៧៤ឆ្នាំ។ ក្រោយពេលរៀបការយើងមានកូន៥នាក់ កូនម្នាក់បានស្លាប់ និងកូនម្នាក់ទៀតមានសតិមិនល្អ និងពិការភ្នែក។

កាលខ្ញុំនៅវ័យកុមារ ម្តាយឪពុករបស់ខ្ញុំមានជីវភាពខ្វះខាតយ៉ាងខ្លាំង។ ឪពុកម្តាយរបស់ខ្ញុំប្រកបរបរធ្វើស្ករត្នោត និងកាប់ស្លឹកត្នោត តាំងពីខ្ញុំនៅក្មេង។ កាលនោះខ្ញុំមិនសូវពិបាកក្នុងការរកម្ហូបទេ។ ខ្ញុំរកត្រី ក្តាម ខ្យង តាមត្រពាំង ហើយចែកតាមគ្រួសារ១០ទៅ២០គ្រួសារដើម្បីហូប។ ខ្ញុំរៀនត្រឹមថ្នាក់ទី៩ នៅសាលាអង្គជុំ បន្ទាប់មកខ្ញុំបានចូលបួសរៀននៅវត្តអង្គជុំ។ កាលសម័យនោះ មេភូមិរបស់ខ្ញុំមានឈ្មោះ ណុប បន្ទាប់មកឈ្មោះ ទល់ សុខ, អែល សឿ, គួនតែម និង ចាន់ ជឹម។

ក្រោយមកខ្ញុំសឹក ហើយរៀបការប្រពន្ធ។ ខ្មែរក្រហមចោទប្រកាន់ប្រពន្ធរបស់ខ្ញុំថា បានលួចស្វាម្ចូប បន្ទាប់ពីប្រពន្ធរបស់ខ្ញុំសម្រាលកូនបាន១០ថ្ងៃ។ ខ្មែរក្រហមយកប្រពន្ធរបស់ខ្ញុំទៅរៀនសូត្រ និងយកខ្ញុំទៅអប់រំជាច្រើនលើក។ លើកទីមួយ ខ្មែរក្រហមយកខ្ញុំទៅដល់សាលាឃុំនៅប្រហែលម៉ោង១២យប់ ក៏បានដោះលែងខ្ញុំឲ្យរួចខ្លួន។ ពីរថ្ងៃក្រោយមក អ្នកដែលធ្វើការជាមួយខ្ញុំបានប្រាប់ខ្ញុំថា មិត្តឯងល្អហើយដែលបានត្រឡប់មកវិញ ប្រសិនបើមិត្តឯងទៅដល់ក្រាំងតាចាន់ ដែលស្ថិតនៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ គឺច្បាស់ជាស្លាប់ហើយ។ លើកទី២ ខ្មែរក្រហមមកហៅខ្ញុំម្តងទៀតដោយប្រាប់ថាទៅចូលរួមមីទីញ ដែលគ្រាន់តែជាល្បិចកុហករបស់ខ្មែរក្រហមដើម្បីចាប់ខ្ញុំនិងលើកទី៣ ខ្មែរក្រហមប្រាប់ខ្ញុំថាទៅមីទីញដដែល។

មួយរយៈក្រោយមក ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅធ្វើការងារខាងផ្នែកសេដ្ឋកិច្ច។ ខ្ញុំដឹកអង្ករចេញពីសាលាឃុំតាភេម ទៅចែកតាមសហករណ៍នៅភូមិត្រពាំងស្វាយ ភូមិបាខុងខាងលិច និងភូមិបាខុងខាងកើត។ កាលនោះមេកងរបស់ខ្ញុំបាននិយាយថា ប្រសិនបើមានអ្នកមូលដ្ឋានចូលមកថ្មី សូមឲ្យខ្ញុំរាយការណ៍មកខាងសហករណ៍ដើម្បីទទួលបានចំណែកអង្ករបន្ថែមទៀត។ ពុដូច្នេះ ខ្ញុំតែងតែរាយការណ៍ប្រាប់មេកងថា មានអ្នកថ្មីចូលមកបន្តបន្ទាប់ ទោះបីជាមិនមានអ្នកថ្មីចូលមកក៏ដោយ ព្រោះខ្ញុំគិតថាអង្ករដែលទទួលបាននោះមានចំនួនតិចតួចពេក និងបរិភោគមិនបានឆ្អែតឡើយ។ ខ្ញុំបានលួចបន្ថែមចំនួនមនុស្សដើម្បីទទួលបានអង្ករច្រើនឲ្យអ្នកដែលធ្វើការងារហត់នឿយបានហូបប្រសើរជាងមុនបន្តិច។ ស្រាប់តែក្រោយមក ខ្មែរក្រហមបញ្ឈប់ខ្ញុំលែងឲ្យដឹកអង្ករចេញពីឃ្លាំងទៀត។ ខ្មែរក្រហមរកឃើញថា នៅសល់អង្ករច្រើននៅតាមភូមិដែលមិនសមនឹងចំនួនមនុស្សដែលខ្ញុំបានរាយការណ៍ ទើបខ្មែរក្រហមមកតាមចាប់ខ្ញុំយកទៅសួរចម្លើយ។ ខ្មែរក្រហមបានចោទខ្ញុំថា ខ្ញុំចង់បានអង្ករច្រើនក្បត់គោលការណ៍របស់អង្គការ។ ខ្មែរក្រហមយកខ្ញុំទៅឃុំឃាំង និងអប់រំខ្ញុំ ហើយក៏ដោះលែងខ្ញុំឲ្យមកភូមិវិញ។

ក្រោយមកទៀត ខ្មែរក្រហមចោទប្រកាន់ខ្ញុំថាធ្វើខុសសីលធម៌ព្រោះខ្ញុំប៉ះពាល់នារីនៅក្នុងរោងបាយ។ ខណៈពេលនោះ មាននារី២នាក់ដែលជាអ្នកស្គាល់គ្នាជាមួយខ្ញុំ និងរស់នៅក្នុងស្រុកភូមិជាមួយគ្នាបានពឹងពាក់ខ្ញុំឲ្យជួយរែកសក់ឲ្យគាត់បន្តិចព្រោះគាត់កំពុងធ្វើត្រី ហើយដៃរបស់គាត់ប្រឡាក់ស្រកាត្រី។ សក់របស់គាត់បានគ្របភ្នែករបស់គាត់ ហើយពេលនោះខ្ញុំក៏មិនដឹងថាមានឈ្លបមកស៊ើបការណ៍នៅក្បែរនោះដែរ។ នៅពេលយប់ ខ្មែរក្រហមហៅខ្ញុំទៅចូលរួមមីទីញ និងបញ្ជាឲ្យខ្ញុំរើសម្ភារប្រើប្រាស់ចេញឲ្យអស់ពីអង្គភាពដោយបាននិយាយថា អ្នកសេដ្ឋកិច្ចជាមនុស្សប្រុស ហើយអ្នកដាំបាយជានារីនៅកន្លែងជាមួយគ្នាគឺជារឿងមួយដែលមិនសមរម្យ។ ខ្មែរក្រហមយកខ្ញុំទៅដាក់គុក និងព្រមានខ្ញុំ រួចហើយក៏ដោះលែងខ្ញុំមកវិញ។

ខ្ញុំជួបការលំបាកយ៉ាងខ្លាំង ព្រោះខ្មែរក្រហមចាត់ខ្ញុំឲ្យហូបបាយរួមក្នុងសហករណ៍ និងធ្វើការងារលើកទំនប់ប្រឡាយ។ ចំណែកប្រពន្ធរបស់ខ្ញុំដែលទើបសម្រាលកូនបាន១ខែ ខ្មែរក្រហមប្រើឲ្យទៅសែងដីធ្វើឲ្យប្រពន្ធរបស់ខ្ញុំមានជំងឺស្បូន និងទាស់សរសៃ។ សំណាងល្អម្តាយក្មេកខ្ញុំចេះក្បួនថ្នាំបុរាណ ហើយរកថ្នាំមកដាំទឹកឲ្យប្រពន្ធខ្ញុំផឹកទើបបានធូរស្បើយ។ នៅសម័យនោះ ប្រសិនបើយើងធ្វើការងារមិនបានល្អ និងគ្មានការខិតខំប្រឹងប្រែង ខ្មែរក្រហមមិនឲ្យហូបបាយឡើយ។ ពេលស្ទូងស្រូវម្តងៗប្រពន្ធរបស់ខ្ញុំត្រូវរក្សាទុកចំណែកកណ្តាប់ ព្រោះពេលប្រធានកងឃើញអ្នកស្ទូងមានចំណែកកណ្តាប់ច្រើនគឺមេកងតែងតែកោតសរសើរ។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកដីដោយកំណត់ចំនួន២ទៅ៣ម៉ែត្រគីបក្នុង១ថ្ងៃ។ ខ្ញុំធ្វើការគ្មានពេលសម្រាកឡើយ គឺខំប្រឹងឲ្យបានគ្រប់ចំនួន។ នៅម៉ោង១២ពេលចេញពីធ្វើការខ្ញុំមកហូបបាយ រួចហើយត្រូវចូលធ្វើការវិញ។ នៅពេលយប់មេកងបានហៅទៅប្រជុំទៀត។ រាល់ពេលដែលប្រជុំម្តងៗ ខ្មែរក្រហមឲ្យ

យើងប្ដេជ្ញាថា យើងត្រូវស្ម័គ្រស្មោះ តស៊ូ និងសាមគ្គីគ្នាក្នុងម៉ោងធ្វើការដោយគោរពតាមគោលការណ៍មហាលោតផ្លោះ មហាអស្ចារ្យ ដោយមិនឲ្យយកកូនចៅធ្វើជាបង្អែក ព្រោះខ្មែរក្រហមយល់ថាគឺរឿងដើម្បីដោះសារសម្រាប់អ្នកដែលខ្ជិលធ្វើការ។ នៅសម័យខ្មែរក្រហមមានការប្រជុំធំក្នុង១ទៅ២ខែម្ដង។

ការហូបចុកនៅសម័យនោះ មិនបានគ្រប់គ្រាន់ទេ ខ្ញុំហូបតែបបរលាយជាមួយសម្លរប្រលិត។ ការបរិភោគគឺមិនសាកសមជាមួយការប្រើកម្លាំងពលកម្មទេ។ យើងហូបតិចតួច តែធ្វើការងារច្រើន និងគ្មានសិទ្ធិតវ៉ាឡើយ។ ពេលយើងហូបល្ងាចរួចហើយ ប្រធានសហករណ៍ដើរសួរថា ឆ្ងាញ់ឬអត់? ឬឆ្អែតទេ? ប្រសិនបើយើងឆ្លើយថា មិនឆ្ងាញ់ មិនឆ្អែត ល្ងាចឡើងអង្គការមកយកយើងទៅរៀនសូត្រ ហើយពាក្យថារៀនសូត្រដែលអង្គការប្រើនោះគឺជាការយកមនុស្សទៅវាយធ្វើបាប ឬសម្លាប់ចោល។

នៅក្នុងស្រុកភូមិរបស់ខ្ញុំ មានការធ្វើទារុណកម្មចំពោះមិត្តណាដែលលួចបេះផ្លែដូង ឬលួចដំឡូង។ អង្គការចាប់យកអ្នកលួចទាំងនោះទៅអប់រំលើកទី១ និងធ្វើការណែនាំ ប៉ុន្តែប្រសិនបើមានលើកទី២ គឺអង្គការនឹងយកអ្នកទាំងនោះទៅសម្លាប់នៅក្រាំងតាចាន់មិនខាន។ នៅសម័យនោះប្រជាជននិយាយតៗគ្នាថា ដៃព័ទ្ធពីក្រោយ បណ្ដោយទៅលិច ព្រោះវាជាប្រយោគដែលអង្គការនិយាយដើម្បីគំរាមប្រជាជន។ ខ្ញុំធ្លាប់ឃើញមនុស្សពីរ ឬបីនាក់ ដែលឈ្លបចាប់យកទៅវាយសម្លាប់នៅគុកក្រាំងតាចាន់។

ក្រោយពេល ថ្ងៃ៧មករា ឆ្នាំ១៩៧៩ កូនរបស់ខ្ញុំម្នាក់ឈ្មោះ ឡាង ជីន ហៅ រឿង គឺជាឈ្មោះដែលអង្គការដាក់ឲ្យពេលចូលកងនារីបានស្លាប់។ កូនស្រីរបស់ខ្ញុំបានដើរធ្វើការងារចល័តតាមកង ហើយបាត់ខ្លួនតាំងពីពេលនោះមក។ ខ្ញុំទទួលដំណឹងមកថា កូនរបស់ខ្ញុំស្លាប់នៅលើភ្នំ ហើយអ្នកខ្លះនិយាយថា កូនខ្ញុំស្លាប់ព្រោះត្រូវគេយកទៅសម្លាប់។ សព្វថ្ងៃខ្ញុំនៅសល់កូន៤នាក់ ប៉ុន្តែមានតែ៣នាក់ទេ ដែលពឹងពាក់បានព្រោះកូនម្នាក់ទៀតមានជំងឺសរសៃប្រសាទរួមទាំងងងឹតភ្នែក។ ខ្ញុំនិងប្រពន្ធនៅមើលថែកូនពិការដែលជាការងារលំបាកសម្រាប់យើង។



វាលនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។
(លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# គំនុំសងសឹកដែលមិនអាចរំលត់បាន

*ផេង ពង្សរ៉ាស៊ី*



សុខ សុផល ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ភូមិក្រាំងវែង ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ខែតុលា ឆ្នាំ ២០២១។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មិនខុសពីប្រជាជនមូលដ្ឋានឯទៀតក្នុងភូមិក្រាំងវែង និងភូមិដទៃទៀតក្នុងឃុំជាងដែកឡើយ សុផល ត្រូវបានដកហូតសិទ្ធិពីប្រជាជនមូលដ្ឋានមកជាប្រជាជនបញ្ញើ បន្ទាប់ពីគាត់បានជាប់ក្នុងមន្ទីរឃុំឃាំងនៅ ទួលម្រេញអស់រយៈពេលមួយឆ្នាំគត់ គឺពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៤ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥។ ទោសកំហុសនៃការចាប់ខ្លួន គឺ «សន្តិសម្ព័ន្ធ» ដែលសំដៅលើកំហុសឆ្គងសីលធម៌ និងភ្នាក់ងាររបារកម្មខ្លាំង (សេ.អ៊ី.អា) របស់អាមេរិក។

រហូតមកដល់ពេលនេះ សុផល នៅតែចាំមិនភ្លេចឡើយពីបទពិសោធន៍ជីវិតក្នុងមន្ទីរឃុំឃាំង និងនៅតែមានចិត្តខឹងសម្បារជាមួយ ម៉ែន ពុត ជាកងសន្តិសុខស្រុកកំពង់ត្របែក ដែលបានធ្វើទារុណកម្មគាត់ធ្ងន់ធ្ងររហូតបន្សល់ទុកស្លាកស្នាមដល់ពេលបច្ចុប្បន្ន។ ស្ទើរតែគ្រប់ពាក្យដែល សុផល បាននិយាយប្រាប់យើង គាត់នៅតែមានកំហឹងជ្រាលជ្រៅចំពោះកម្មាភិបាលខ្មែរក្រហម ជាពិសេសអ្នកដែលពាក់ព័ន្ធនឹងការចាប់ខ្លួនគាត់មកដាក់ក្នុងមន្ទីរឃុំឃាំងទួលម្រេញ។ គំនុំសងសឹកដែលស្ថិតក្នុងចិត្តគាត់ គឺមិនត្រូវបានរំលត់

ឡើយ ទោះបីជា ម៉ែន ពុត ត្រូវបានសម្លាប់កាលពីខែមករា ឆ្នាំ១៩៧៩ រួចមកហើយក៏ដោយ។ សុផល បាននិយាយថា គាត់នៅតែចង់សម្លាប់ ពុត ដោយផ្ទាល់ដៃ។ ប៉ុន្តែគាត់មិនចង់បញ្ចេញគំនុំនេះជាមួយក្រុមគ្រួសារសាច់ញាតិរបស់ ពុត ឡើយ។

បច្ចុប្បន្ននេះ សុផល នៅតែជាមនុស្សម្នាក់ដែលមានកម្លាំងពលំមាំមួនមិនខុសពីពេលដែលគាត់នៅវ័យក្មេងឡើយ។ សុផល បានជិះកង់ចាស់របស់គាត់ កាត់វាលស្រែពីផ្ទះរបស់គាត់ក្នុងភូមិក្រាំងវែង មកជួបយើងនៅភូមិអង្គ្រង ដើម្បីនិយាយរឿងរ៉ាវជីវិតរបស់គាត់។ ជាមួយនឹងកាយវិការធ្វើត្រាប់ពេលដែលគាត់ត្រូវ ពុត ធ្វើទារុណកម្ម សុផល បានរំឭកឡើងវិញយ៉ាងច្បាស់ និងហាក់នៅថ្មីៗ។ «ស្តាយណាស់ដែលអាពុត វាស្លាប់បាត់ កុំអីត្រូវរបស់ខ្ញុំហើយ» នេះជាការលើកឡើងរបស់ សុផល ក្នុងពេលធ្វើសម្ភាសន៍។ អ្នកភូមិពីរបីនាក់ដែលអង្គុយនៅជិតៗ សុផល បានបញ្ចេញយោបល់តិចតួចដែរពីភាពឃោរឃៅរបស់ ពុត ដែលពាក្យសម្តីទាំងអស់នេះអាចបញ្ជាក់បានថា អ្វីដែល សុផល កំពុងរៀបរាប់ គឺជារឿងរ៉ាវពិតដែលមិនអាចលាក់បាំងបានពីសកម្មភាពសាហាវឃោរឃៅនៃកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋាននៅស្រុកកំពង់ត្របែក។

នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ សុផល ត្រូវបានដោះលែងចេញពីមន្ទីរឃុំឃាំង។ ពុត ជាអ្នកសរសេរលិខិតដោះលែងមួយច្បាប់ រួចប្រគល់ឲ្យ សុផល កាន់មកប្រគល់ឲ្យប្រធានភូមិឈ្មោះ ម៉ែន ឃឹម។ និយាយដល់ឈ្មោះនេះ សុផល បានសំដែងឲ្យដឹងពីការផ្ទុះកំហឹងសារជាថ្មីម្តងទៀត។ គាត់និយាយដូច្នេះថា៖ «អា ម៉ែន ឃឹម គឺមនុស្សតែម្នាក់គត់ដែលបានរាយការណ៍ពីទោសកំហុសឆ្គងរបស់ខ្ញុំប្រាប់ទៅកងសន្តិសុខស្រុកឲ្យមកចាប់ខ្លួនខ្ញុំយកទៅកាលពីឆ្នាំ១៩៧៨»។ សុផល បានរំឭកទៀតថា គាត់ពិតជាមានចិត្តចង់សងសឹក ម៉ែន ឃឹម ម្នាក់ទៀត ព្រោះ ឃឹម គឺជាដើមចមនៃការចាប់ខ្លួនគាត់។ សុផល និយាយបន្តថា៖ «ពេលដែលខ្ញុំយកសំបុត្រ អាពុត ទៅប្រគល់ឲ្យវា ខ្ញុំពិតជាចង់សម្លាប់ អាឃឹម ចោលក្នុងពេលនោះ តែខ្ញុំទប់ចិត្តទាន់។ មកដល់ផ្ទះ ខ្ញុំបានសំលៀងកាំបិតផ្គាក់រួចហើយ ប្រុងនឹងដើរចេញទៅកាន់ផ្ទះវា។ តែម្តាយឪពុកខ្ញុំឃាត់ខ្ញុំមិនឲ្យទៅទេ ព្រោះគាត់ប្រាប់ថា គ្រួសារយើងអាចស្លាប់ទាំងអស់គ្នាដោយសារតែខ្ញុំ។ អ៊ីចឹងហើយ! ខ្ញុំចេះតែទ្រាំទាំងលំបាកទ្រាំរហូតដល់ពេលបែកឆ្នាំ១៩៧៩»។

ភ្លាមៗក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ និងក្នុងពេលដែលស្រុកភូមិកំពុងត្រូវបានរៀបចំឡើងវិញ សុផល បានស្វែងរក ឃឹម និង ពុត។ ប៉ុន្តែគាត់មិនបានជួបអ្នកទាំងពីរដូចបំណងឡើយ។ ឃឹម បានរត់ភៀសខ្លួនទៅរស់នៅកន្លែងផ្សេងបាត់តាំងពីមានការជ្រួលច្របល់នៅក្នុងភូមិនាចុងឆ្នាំ១៩៧៨ ហើយបាត់ដំណឹងសូន្យឈឹងរហូតមកដល់សព្វថ្ងៃ។ ចំណែក ពុត ត្រូវបានបាញ់សម្លាប់ចោលនៅក្នុងទឹកទន្លេមេគង្គ ក្នុងពេលដែល ពុត បានលោតចេញពីទូកចម្លងទាំងដៃជាប់ចំណងចូលទៅក្នុងទឹកទន្លេក្នុងគោលបំណងសម្លាប់ខ្លួន។

រយៈពេលជាង៤២ឆ្នាំ នៃការដួលរលំរបបខ្មែរក្រហមបានកន្លងផុតទៅ គំនុំសងសឹងរបស់ សុផល នៅតែស្ថិតក្នុងចិត្តគំនិតរបស់គាត់ជានិច្ច។ ស្លាកស្នាមដែលបន្សល់ទុកពីការធ្វើទារុណកម្មរបស់ ពុត នៅតែអាចមើលឃើញយ៉ាងច្បាស់ ហើយស្លាកស្នាមទាំងនេះបានរំឭកគាត់ជារៀងរហូតពីទង្វើរបស់ ពុត និង ឃឹម មកលើរូបគាត់។ សុផល បានរំឭកពីការចងចាំរបស់គាត់ប្រាប់យើងដោយក្តីសោមនស្ស ហើយការចងក្រងខ្សែជីវិតរបស់គាត់សម្រាប់ការអប់រំ ក៏ត្រូវបានធ្វើឡើងព្រមគ្នា និងត្រូវបានបង្ហើបប្រាប់គាត់ឲ្យដឹងជាមុនដែរ។ សាច់រឿងជីវិតរបស់ សុផល គឺជាមេរៀនបន្ថែមមួយទៀតសម្រាប់ក្មេងៗជំនាន់ក្រោយ ក្នុងការពិចារណាឲ្យស៊ីជម្រៅពី «គំនុំសងសឹក និងការផ្សះផ្សាដែលមិនអាចខ្វះបាន»។ តើក្មេងៗជំនាន់ក្រោយដែលបានដឹងរឿងរ៉ាវជីវិតរបស់ សុផល គិតយ៉ាងដូចម្តេចចំពោះគំនុំសងសឹកដែលមិនអាចរំលត់បានបែបនេះ?

# ហិន អ៊ិក ៖ រត់គេចពីការតាមចាប់របស់ខ្មែរក្រហម

**ង៉ាន់ វីន**

ខ្ញុំឈ្មោះ ហិន អ៊ិក អាយុ៧៩ឆ្នាំ កើតនៅភូមិលីញ៉ា ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ ឪពុករបស់ខ្ញុំឈ្មោះ ពេជ្រ ហិន (ស្លាប់) និងម្តាយឈ្មោះ នូ ង៉ែត (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន៧ នាក់ ប្រុស៤នាក់ និងស្រី៣នាក់។ នៅអាយុ ២១ឆ្នាំ ខ្ញុំបានរៀបការប្រពន្ធដែលមានឈ្មោះ អ៊ុក សៀង អាយុ៧៧ឆ្នាំ រស់នៅភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅខាងប្រពន្ធ ហើយយើងមានកូនចំនួន៧ នាក់ (ប្រុស៣នាក់ និងស្រី៤នាក់) ចំណែកកូនម្នាក់បានស្លាប់។

តាំងពីកុមារ ខ្ញុំរស់នៅក្នុងវត្ត និងធ្វើជាកូនសិស្សព្រះសង្ឃនៅវត្តអង្គជុំមានលក្ខណ៍។ ខ្ញុំរៀនត្រឹមថ្នាក់ទី២នៅសាលាវត្តគុស ស្ថិតក្នុងភូមិត្រពាំងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំ បួសរៀននៅវត្តអង្គជុំមានលក្ខណ៍ចំនួន៣វស្សា រហូតដល់អាយុ២១ឆ្នាំទើបសឹក និងមករៀបការប្រពន្ធ។ ពេលនោះនៅក្នុងភូមិរបស់ខ្ញុំមិនមានព្រឹត្តិការណ៍ចលាចលទេ ខ្ញុំនិងប្រពន្ធរស់នៅដោយសុខសាន្តដូចក្រុមគ្រួសារដទៃទៀតដែរ។ នៅឆ្នាំ១៩៧០ មានការធ្វើបាតុកម្មប្រឆាំងនឹង លន់ នល់ ដែលទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាច នៅម្តុំផ្សារអង្គតាសោម។

នៅឆ្នាំ១៩៧២ ខ្ញុំជាមួយបងប្អូន៣នាក់ទៀតបានចូលព្រៃម៉ាគីតស៊ូជាមួយ សម្តេចព្រះនរោត្តម សីហនុ ដើម្បីប្រយុទ្ធប្រឆាំងជាមួយកងទ័ពរបស់ លន់ នល់។ បន្ទាប់ពីរបប លន់ នល់ ត្រូវបានផ្តួលរំលំ ខ្ញុំបាត់បង់បងប្អូន៣នាក់ ដែលធ្វើជាកងទ័ពខ្មែរក្រហមប្រយុទ្ធជាមួយ ទាហាន លន់ នល់។



ង៉ាន់ វីន (ខាងស្តាំ) និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ ប្រគល់កញ្ចប់អនុស្សាវរីយ៍ជូន ហិន អ៊ិក អាយុ៧៩ឆ្នាំ រស់នៅភូមិលីញ៉ា ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ខែតុលា ឆ្នាំ២០២១។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមស្រាវជ្រាវរកប្រវត្តិរូបអ្នកដែលបានធ្វើទាហានតស៊ូជាមួយក្រុមរបស់សម្តេចព្រះ នរោត្តម សីហនុ យកទៅសម្លាប់ចោល។ ខ្ញុំបានរត់គេចខ្លួនរហូតដល់ខាងលិចអង្គតាសោម ប៉ុន្តែខ្មែរក្រហមស្ទាក់ចាប់បាន។ សំណាងល្អខ្ញុំមិនត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ទេ។ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅធ្វើការជួសជុលផ្លូវបាក់បែកនៅឃុំតានី ក្នុងស្រុកអង្គរជ័យ ខេត្តកំពត។ បន្ទាប់ពីធ្វើការជួសជុលផ្លូវបានមួយឆ្នាំ ខ្មែរក្រហមបានដកខ្ញុំ

និងអ្នកជួសជុលផ្លូវជាមួយខ្ញុំចំនួន៨នាក់ទៀតទៅកាន់ម៉ាស៊ីនអារឈើ។ យើងធ្វើដំណើរដោយថ្មើរជើងពីឃុំតានី ទៅដល់ភ្នំលាក់បន្តប់។ ខ្ញុំភិតភ័យព្រោះខ្លាចខ្មែរក្រហមបញ្ជូនខ្ញុំ និងអ្នកផ្សេងទៀតទៅវាយសម្លាប់ចោល។ ក្នុងអំឡុងពេលធ្វើដំណើរមកធ្វើការនៅរោងម៉ាស៊ីនអារឈើ ខ្ញុំនាំកូនៗរបស់ខ្ញុំទៅជាមួយដែរ។ កន្លែងកាន់ម៉ាស៊ីអារឈើនោះនៅបូរផង់ ស្ថិតនៅជិតផ្សារត្រពាំងអណ្តើក ក្នុងភូមិទួលខ្វឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្មែរក្រហមយកឈើមកឲ្យខ្ញុំអារដើម្បីធ្វើជារោង ធ្វើជាក្តា និងធ្វើជាផ្ទះល្វែង។ អ្នកកាន់ម៉ាស៊ីនអារឈើជាមួយខ្ញុំមានចំនួន៩នាក់។ អ្នកទាំងនោះគឺសុទ្ធតែអ្នកធ្លាប់ធ្វើទាហានក្នុងរបប លន់ នល់។ បន្ទាប់មកខ្មែរក្រហមចាត់តាំងខ្ញុំឲ្យសាងសង់អាងទឹកដើម្បីយកទឹកស្រោចចម្ការម្រេច នៅខាងជើងបូរផង់ជាមួយក្រុមសហករណ៍ផ្សេងទៀតដែលរស់នៅទីនោះស្រាប់។ ខ្មែរក្រហមបានអនុញ្ញាតឲ្យខ្ញុំនាំកូនៗរបស់ខ្ញុំមករស់នៅជាមួយដែរ។ អ្នកកាន់ម៉ាស៊ីនអារឈើក្រុមការងាររបស់ខ្ញុំខ្លះនៅកន្លែងអារឈើដដែល និងខ្លះទៀតបានបែកគ្នាទៅធ្វើការងារដែលខ្មែរក្រហមចាត់ឲ្យធ្វើ។ សម្រាប់ការហូបចុកសម្រាប់ខ្ញុំ គឺហូបតែបបររួមគ្នាជាមួយក្រុមសហករណ៍ផ្សេងទៀត។ ខ្ញុំហូបមិនបានឆ្អែត និងមិនមានកម្លាំងគ្រប់គ្រាន់ធ្វើការទេ។ ខ្ញុំបានលួចដកដំឡូងតិចតួចយកមកហូប ប៉ុន្តែត្រូវឈ្លបតាមទាន់។ ឈ្លបមិនបានចាប់ខ្ញុំវាយធ្វើបាបទេ ដោយសារនឿយហត់ខ្ញុំបានលួចសម្រាក។ ទីតាំងការដ្ឋានដែលខ្ញុំស្គាល់មានពីរកន្លែង គឺមួយនៅបូរផង់ និងមួយទៀតនៅចម្ការម្រេចម្តុំផ្សារត្រពាំងអណ្តើក។ ការដ្ឋានរបស់ខ្ញុំធ្វើការមិនមានកន្លែងធ្វើទារុណកម្ម និងមន្ទីរឃុំឃាំងទេ។ ខ្ញុំបានឃើញឈ្លបបញ្ជូនមនុស្សចេញពីទីកន្លែងធ្វើការទៅបាត់ៗ តែមិនដឹងថាបញ្ជូនមនុស្សទាំងអស់នោះទៅទីកន្លែងណាទេ។ ចំណែកការសម្លាប់មនុស្សខ្ញុំមិនដែលឃើញទេ។ ខ្ញុំគ្រាន់តែដឹងថាខ្មែរក្រហមបញ្ជូនមនុស្សទៅបាត់ៗ និងគ្មានដំណឹងអ្វីទាល់តែសោះ។

នៅចុងឆ្នាំ១៩៧៨ ដល់ដើមឆ្នាំ១៩៧៩ ខ្ញុំឃើញកងទ័ពវៀតណាមវាយប្រយុទ្ធជាមួយខ្មែរក្រហម។ ខ្ញុំនាំកូនៗរត់ចេញពីសហករណ៍។ ខ្ញុំធ្វើដំណើររហូតមកដល់ខេត្តពោធិ៍សាត់ និងបាត់ដំបង។ ខ្ញុំនិងអ្នករួមដំណើរផ្សេងទៀត សង្កេតឃើញសភាពការស្ងប់ស្ងាត់ ក៏នាំកូនៗ និងក្រុមគ្រួសារដើរត្រឡប់មកបូរផង់ ស្ថិតនៅជិតផ្សារត្រពាំងអណ្តើក ក្នុងភូមិទួលខ្វឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ វិញ។ នៅតាមផ្លូវ ខ្ញុំជួបកងទ័ពក្មេងៗ។ កងទ័ពទាំងនោះស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ។ កងទ័ពទាំងនោះទទួលខ្ញុំនិងក្រុមរបស់ខ្ញុំ និងផ្តល់អាហារឲ្យហូបចុកគ្រប់គ្រាន់។ កងទ័ពក្មេងៗទាំងអស់នោះបាននាំខ្ញុំឆ្លងតាមផ្លូវជាតិលេខ៤ ដើម្បីមកស្រុកជួបជុំគ្រួសាររបស់ខ្ញុំវិញ។

ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅក្រោយឆ្នាំ១៩៧៩ ខ្ញុំបានបាត់បង់សមាជិកបងប្អូនធ្វើជាទាហាននៅក្នុងរបប លន់ នល់ ចំនួន៣នាក់ គឺម្នាក់បានស្លាប់ និងពីរនាក់ទៀតបានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំមិនបានទទួលដំណឹងពីការបាត់ខ្លួនរបស់បងប្អូនខ្ញុំទេ។ ក្រោយឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅសុខសាន្ត និងប្រកបរបរធ្វើស្រែចម្ការ។



ហិន អ៊ក នៅខាងមុខផ្ទះរបស់គាត់នៅភូមិលីញ៉ា ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ (ង៉ាន់ វ៉ន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម៖

## ប្រជាជននាំយកអដ្ឋិធាតុសាច់ញាតិដែលបានស្លាប់មកតម្កល់ទុកនៅចេតីយ៍ដែលទើបនឹងសាងសង់រួច

*ផេង ពង្សរ៉ាស៊ី*



"ពិធីក្រុងពលី ឬក្រុងពាលី" ដើម្បីសុំម្ចាស់ទឹកម្ចាស់ដីក្នុងការប្រារព្ធធ្វើកម្មវិធីប្រកបដោយសេចក្តីសុខសប្បាយ និងគ្មានឧបសគ្គរារាំង។ ព្រះសង្ឃសូត្រមន្តបង្សុកូលដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធអ្នកដែលបានបែកឋានទៅ ជាពិសេសអ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ បន្ទាប់មកប្រជាជននៅក្នុងឃុំចាម និងពុទ្ធបរិស័ទដែលបានមកចូលរួមនាំគ្នាធ្វើពិធីរាប់បាត្រឧទ្ទិសកុសលជូនញាតិសន្តានរបស់ខ្លួនដែលបានបែកឋានទៅ។ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ដោយមានការឯកភាពពីអាជ្ញាធរមូលដ្ឋានក្នុងឃុំចាម និងពីនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំកម្មវិធីសម្ពោធដាក់ឲ្យប្រើប្រាស់សំណង់ចេតីយ៍ និងផ្ទាំងពាក្យស្លោករំឭកអំពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម នៅលើទីតាំង «ទួលធាតុ» ស្ថិតនៅក្នុងភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ កម្មវិធីនេះបានរៀបចំរួមគ្នា





វាំងអាជ្ញាធរមូលដ្ឋាន ប្រជាជនក្នុងភូមិ និងមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង ធ្វើពិធីសម្ពោធ សូត្រមន្តបង្សុកូលឧទ្ទិសកុសលដល់សាច់ញាតិដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមទៅតាមទំនៀមទម្លាប់ ប្រពៃណី និង សាសនារបស់ខ្មែរ។ ស្ថិតនៅចំកណ្តាលវាលស្រែខៀវស្រងាត់ ចេតិយ៍ពណ៌ប្រផេះ នៅលើទួលធាតុបានបង្ហាញរូបរាងកាន់តែច្បាស់ បន្ទាប់ពីទីតាំងនេះត្រូវបានថែរក្សា និងបោសសម្អាត។ ស្ថិតនៅចម្ងាយប្រមាណ២០ម៉ែត្រពីផ្លូវលំក្នុងភូមិ ប្រជាជនអាចមើលឃើញយ៉ាងច្បាស់នូវផ្ទាំងពាក្យស្លោករំឭកអំពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម និងសំណង់ចេតិយ៍ដ៏ថ្មីសន្ធាងមួយនៅលើទីទួល។ ដើមត្នោតប្រាំដើម ដុះនៅលើទីទួលនេះដែលអាចផ្តល់ជាម្លប់សម្រាប់អ្នកភូមិដែលមកជួបជុំ ព្រមទាំងមានកៅអី និងតុធ្វើពីឥដ្ឋ និងស៊ីម៉ង់ត៍ចំនួនពីរសម្រាប់អង្គុយនៅក្បែរដើមត្នោតទាំងនេះ។ សួនច្បារចំនួនពីរទៀត ត្រូវបានសាងសង់ឡើងដើម្បីដាំផ្កាលម្អ និងមានដើមផ្កាត្របែកព្រៃចំនួន៨ដើមដុះនៅជុំវិញទីតាំងទួលនោះ។

បន្តពីកម្មវិធីសាសនា លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍បានជួបសំណេះសំណាលជាមួយអាជ្ញាធរ និងអ្នកភូមិក្នុងកម្មវិធីសម្ពោធនេះ ដោយបានលើកឡើងពីចំណុចសំខាន់ៗមួយចំនួន ដូចជា ការធ្វើសេចក្តីរាយការណ៍ត្រួសៗអំពីសកម្មភាពការងារសាងសង់ចេតិយ៍ និងផ្ទាំងពាក្យស្លោក ការថ្លែងអំណរគុណដល់ម្ចាស់ជំនួយគឺទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដែលបានឧបត្ថម្ភក្នុងការសាងសង់ចេតិយ៍ និងផ្ទាំងពាក្យស្លោក, ការប្រកាសអំពីការបង្កើត «សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ជាផ្លូវការ និងយុទ្ធសាស្ត្រក្នុងការអនុវត្តសកម្មភាពមួយចំនួនដើម្បីជាគំនិតក្នុងដំណើរការសមាគមនេះជាលើកដំបូងនៅក្នុងមូលដ្ឋាន។ លោក ដេង ពង្សរ៉ាស៊ី បានឲ្យដឹងថា លោក មុំ វ៉ែន ដែលបច្ចុប្បន្នគឺជា



"ពិធីក្រុងពលី ឬក្រុងពាលី" ដើម្បីសុំម្ចាស់ទឹកម្ចាស់ដីក្នុងការប្រារព្ធធ្វើកម្មវិធីប្រកបដោយសេចក្តីសុខសប្បាយ និងគ្មានឧបសគ្គរារាំង។ ព្រះសង្ឃសូត្រមន្តបង្សុកូលដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធអ្នកដែលបានចែកឋានទៅ ជាពិសេសអ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ បន្ទាប់មក ប្រជាជននៅក្នុងឃុំចាម និងពុទ្ធបរិស័ទដែលបានមកចូលរួមនាំគ្នាធ្វើពិធីរាប់បាត្រឧទ្ទិសកុសលជូនញាតិសន្តានរបស់ខ្លួនដែលបានចែកឋានទៅ។ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



មេឃុំចាម គឺជាប្រធានសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ហើយមេភូមិទាំងអស់ក្នុងឃុំចាម គឺជាសមាជិករបស់សមាគមនេះ។ ក្នុងសេចក្តីថ្លែងការណ៍ដដែល ដេង ពង្សរ៉ាស៊ី បានលើកឡើងដែរពីតួនាទី និងភារកិច្ចរបស់សមាគមក្នុងការសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុកក្នុងការបង្កើតវេទិកាសាធារណៈមួយចំនួនទាក់ទងនឹងការផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលបានសិទ្ធិគ្រប់គ្រាន់ក្នុងការនិយាយដោយចំហរពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហម ក៏ដូចជាការបញ្ចេញមតិយោបល់របស់ខ្លួនចំពោះភាពយុត្តិធម៌ដែលគួរទទួលបានបន្ទាប់ពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបញ្ចប់ ទៅកាន់ក្មេងៗជំនាន់ក្រោយ ដើម្បីការចងចាំនិងការផ្សះផ្សា។ លើសពីនេះទៀត សមាជិករបស់សមាគមទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យធ្វើកិច្ចការស្រាវជ្រាវពីឈ្មោះអ្នកដែលបានស្លាប់ និងបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមនៅតាមគ្រួសារនីមួយៗនៅក្នុងភូមិរបស់ខ្លួន ដើម្បីបង្ហាញឲ្យឃើញពីឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហមចំពោះប្រជាជនកម្ពុជា។ មុននឹងបញ្ចប់កម្មវិធីសម្ពោធជាផ្លូវការនេះ លោកមេឃុំចាម និងជាប្រធានសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បាននិយាយពីចំណាប់អារម្មណ៍របស់គាត់ចំពោះការប្រគល់ចេតិយ៍ និងផ្ទាំងពាក្យស្លោកដល់អាជ្ញាធរ និងប្រជាជនក្នុងភូមិ ក៏ដូចជា ចំណាប់អារម្មណ៍ចំពោះកិច្ចការងារនៅក្នុងសមាគម ព្រមទាំងបានប្រាប់ពីការប្តេជ្ញាចិត្តក្នុងការថែរក្សា និងការពារសំណង់ទាំងពីរនេះឲ្យនៅឋិតថេរជានិរន្តន៍។ លើសពីនេះទៀត ប្រធានសមាគម មុំ វ៉ែន បានថ្លែងអំណរគុណដល់លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងម្ចាស់ជំនួយ ដែលបានផ្តល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំរបស់គាត់នូវចេតិយ៍ដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបាន។ លោកប្រធានសមាគម បានថ្លែងប្រាប់អ្នកចូលរួមទាំងអស់ពីប្រវត្តិរបស់គាត់

ក្នុងរបបខ្មែរក្រហមដែលគាត់បានឆ្លងកាត់ ដោយបានលើកឡើងពីជីវិតជាប់ក្នុងមន្ទីរឃុំឃាំងទួលស្រែញ ដែលការលើកឡើងនេះធ្វើឲ្យគាត់នឹកឃើញឡើងវិញពីភាពភ័យរន្ធត់រហូតដល់គាត់ស្រក់ទឹកភ្នែកនិងយំខ្សឹកខ្សួលនៅចំពោះមុខចំណោមអ្នកចូលរួមទាំងអស់ៗ គាត់បានបង្ហាញពីបទពិសោធន៍ឆ្លងកាត់ការលំបាកលំបិនក្នុងសម័យខ្មែរក្រហម។ បន្ទាប់ពីប្រសាសន៍របស់ប្រធានសមាគមបញ្ចប់ សមាជិករបស់សមាគមម្នាក់ដែលសព្វថ្ងៃគាត់បម្រើការជាមេភូមិរោង ឈ្មោះ សំ យាង អាយុ៦៨ឆ្នាំ បានឡើងធ្វើការចាប់អារម្មណ៍ថា គាត់សប្បាយចិត្តជាពន់ពេកដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រគល់សំណង់ចេតិយ៍ និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំដល់ភូមិរបស់គាត់ៗ គាត់ក៏ធ្លាប់ជាអ្នកទោសខ្មែរក្រហមម្នាក់ដែលជាប់នៅក្នុងមន្ទីរសន្តិសុខទួលស្រែញដែរ។ គាត់ជាប់ឃុំនៅទីនោះអស់រយៈពេល៤៤៥ថ្ងៃ គិតចាប់តាំងពីឆ្នាំ១៩៧៤មក។ គាត់នៅតែនឹកឃើញពីទង្វើរបស់កម្មាភិបាលខ្មែរក្រហមដែលជាអ្នកភូមិជាមួយគ្នា ដែលបានធ្វើទារុណកម្មមកលើរូបគាត់ដោយវាយគាត់ជាមួយនឹងដែកក្រៀវរទេះ និងចងព្យួរឡើងលើដើម្បីសួរចម្លើយ។ ក្រៅពីប្រធាននិងសមាជិកសមាគម នៅមានអ្នករស់រានមានជីវិតជាច្រើននាក់ផ្សេងទៀតដែលធ្លាប់មានប្រវត្តិជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខទួលស្រែញ។ បើតាមលោក ដេង ពង្សរ៉ាស៊ី បានលើកឡើងថា ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខរបស់ខ្លួនចំនួន១៩៧នៅទូទាំងប្រទេសកម្ពុជា ហើយទួលស្រែញគឺជាមន្ទីរសន្តិសុខតំបន់២៤របស់ខ្មែរក្រហមដែលបានឃុំឃាំងអ្នកទោសរាប់ពាន់នាក់មកពីជុំវិញតំបន់២៤។

មិនខុសពីលោកប្រធានសមាគមឡើយ សំយាង បានសន្យានៅចំពោះមុខអ្នកចូលរួមទាំងអស់ថា គាត់នឹងដឹកនាំប្រជាជនក្នុងភូមិចូលរួមថែរក្សា និងការពារសំណង់ទាំងពីរនេះឲ្យស្ថិតស្ថិរ ព្រមទាំងសន្យាថានឹងចុះធ្វើកិច្ចការស្រាវជ្រាវពីឈ្មោះអ្នកស្លាប់ និងបាត់ខ្លួនក្នុងរបបខ្មែរក្រហមនៅក្នុងភូមិដែលគាត់កំពុងគ្រប់គ្រងគឺ ភូមិរោង។ កម្មវិធីសម្ពោធបានបញ្ចប់នៅត្រឹមម៉ោងប្រមាណ១១កន្លះថ្ងៃដដែល បន្ទាប់ពីមានការពិភាក្សាគ្នាបន្ថែមពីយុទ្ធសាស្ត្រនៃការថែរក្សា និងការពារសំណង់ចេតិយ៍ និងភាពងាយស្រួលក្នុងការចូលមកកាន់ទីតាំងទួលធាតុ ដែលសព្វថ្ងៃគឺជាទីតាំងសាធារណៈដែលហ៊ុំព័ទ្ធដោយដីស្រែមានម្ចាស់គ្រប់គ្រងមួយចំនួន។ តាមការឲ្យដឹងពីប្រជាជនក្នុងភូមិ និងមេភូមិរោងថា ម្ចាស់ដីស្រែដែលកំពុងរស់នៅក្បែរនោះបានចូលរួមបរិច្ចាកផ្នែកខ្លះនៃដីស្រែកម្មសិទ្ធិរបស់គាត់ សម្រាប់ធ្វើផ្លូវចូលទៅកាន់ទីតាំងទួលធាតុ។ ដោយហេតុថា ការបរិច្ចាកចំណែកដីស្រែនេះនៅមានទំហំតូចពេក អ្នកភូមិដែលបានចូលរួមនៅក្នុងពិធីសម្ពោធ បានឯកភាពគ្នាបរិច្ចាកថវិកាផ្ទាល់ខ្លួនដើម្បីទិញដីស្រែនេះពង្រីកផ្លូវចូលឲ្យកាន់តែធំទូលាយ។ នៅក្នុងឱកាសនោះ អ្នកចូលរួមទាំងអស់បានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយបំពេញបង្គ្រប់ថ្លៃទិញដីនេះ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលយកដំណើរនេះដើម្បីពិភាក្សាគ្នាបន្តទៀត។ ទោះបីយ៉ាងណាលោក ដេង ពង្សរ៉ាស៊ី បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងបំពាក់អំពូលភ្លើងសូឡាចំនួន៨គ្រាប់ភ្ជាប់ជាមួយដើងអំពូល និងធ្វើស្លាកសញ្ញាបង្ហាញផ្លូវចំនួនបីផ្ទាំងដាក់នៅតាមផ្លូវចូលទៅកាន់ទីតាំងទួលចេតិយ៍នេះ។



# វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ឡុង ដានី, រី លក្ខិណា, គាត ស្រីឡែន

នៅចន្លោះពីថ្ងៃទី២៣ ដល់២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះសម្ភាសន៍ប្រជាជនចំនួន ៨គ្រួសារ រស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាមរយៈគម្រោងវេទិកាប្រវត្តិសាស្ត្រគ្រួសារដែលជាសកម្មភាពបន្តពីខែតុលា ឆ្នាំ២០២១។

ភូមិសាទុំ គឺជាភូមិមួយស្ថិតនៅជាប់ព្រំដែនកម្ពុជា-វៀតណាម និងជាអតីតសមរភូមិប្រយុទ្ធរវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុងនៅអំឡុងទសវត្សរ៍ចុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០។ ប្រជាជនក្នុងភូមិសាទុំបានឲ្យដឹងថានៅចុងឆ្នាំ ១៩៦០ កងទ័ពវៀតកុងបានសាងសង់បន្ទាយ និងមន្ទីរពេទ្យធំមួយកន្លែងស្ថិតនៅចម្ងាយប្រមាណ ៨គីឡូម៉ែត្រ ប៉ែកខាងជើងភូមិសាទុំ។ បន្ទាយ និងមន្ទីរពេទ្យនោះស្ថិតនៅក្នុងព្រៃក្បាលដាំជ្រៃ ព្រៃកញ្ជន់ ក្បែរត្រពាំងទឹកមួយ។ នៅពេលនោះមានកងទ័ពវៀតកុងត្រូវរបួសនៅតាមសមរភូមិជាច្រើនត្រូវបានដឹកមកព្យាបាលនៅក្នុងមន្ទីរពេទ្យនេះ។ នៅអំឡុងពេលនោះ ក៏មានប្រជាជនក្នុងភូមិសាទុំមួយចំនួនបានទៅសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរបស់វៀតកុងនោះដែរ។ ប្រជាជនក្នុងភូមិសាទុំដែលមានអាយុលើសពី៦០ឆ្នាំភាគច្រើនបានស្គាល់បន្ទាយ និងមន្ទីរពេទ្យរបស់កងទ័ពវៀតកុងយ៉ាងច្បាស់ ពីព្រោះប្រជាជនទាំងនោះធ្លាប់បានទៅលេងឬយកបន្លែបង្ការទៅលក់ឲ្យកងទ័ពវៀតកុងនៅក្នុងបរិវេណមន្ទីរពេទ្យ។ ប្រជាជនក្នុងភូមិសាទុំបានឲ្យដឹងទៀតថា នៅក្នុងឆ្នាំ១៩៦៩ ឬឆ្នាំ១៩៧០ យន្តហោះទម្លាក់គ្រាប់បែក ប៥២ របស់ទាហានសហរដ្ឋអាមេរិកបានមកទម្លាក់គ្រាប់បែកលើបន្ទាយ និងមន្ទីរពេទ្យដែលធ្វើឲ្យកងទ័ពវៀតកុងជាច្រើនបានស្លាប់ និងរបួស។ ចំណែកកងទ័ពដែលនៅសេសសល់បានរត់គេចខ្លួនចេញពីបន្ទាយ និងមន្ទីរពេទ្យអស់តែម្តង។ នៅអំឡុងឆ្នាំ ១៩៨៥ ឬ ឆ្នាំ ១៩៨៦ កងទ័ពវៀតណាម បានចុះមកពិនិត្យទីតាំងបន្ទាយ និងមន្ទីរពេទ្យក្នុងភូមិសាទុំ ហើយបានគាស់យកសាកសពកងទ័ពវៀតកុងដែលកប់នៅក្បែរបន្ទាយ និងមន្ទីរពេទ្យនាំយកទៅប្រទេសវៀតណាមវិញ។ ខាងក្រោមគឺរឿងរ៉ាវសង្ខេបរបស់ប្រជាជនដែលបានរៀបរាប់ប្រាប់ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ៖



ឡុង ដានី ខាងឆ្វេង និង យាន ស៊ាន់។
(រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យាន ស៊ាន់ ភេទប្រុស អាយុ៤៩ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ៅ យាន និងម្តាយឈ្មោះ ស្លុត កែ។ ខ្ញុំមានបងប្អូនបង្កើតចំនួន ១០នាក់ គឺ ស្រី ៣នាក់ និងប្រុស ៧នាក់។ ខ្ញុំធ្វើជាមេភូមិសាទុំ ចាប់តាំងពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។ ឪពុករបស់ខ្ញុំបាននិយាយថា នៅឆ្នាំ១៩៦៩

ម្តាយមីងរបស់ខ្ញុំត្រូវគ្រាប់ផ្លោងស្លាប់។ គ្រាប់ផ្លោងនោះបានបាញ់ចេញពីព្រំដែនវៀតណាមសំដៅមកភូមិសាទុំ នៅខណៈពេលនោះម្តាយរបស់ខ្ញុំក៏ត្រូវរបួស និងត្រូវយកទៅព្យាបាលនៅមន្ទីរពេទ្យរបស់វៀតកុងនៅក្នុងក្បាលព្រៃដាំជ្រៃ ដែលមានចម្ងាយប្រមាណជា ៣គីឡូម៉ែត្រ ប៉ែកខាងជើងភូមិសាទុំ។ អ្នកភូមិរបស់ខ្ញុំកាលពីមុនសង់ផ្ទះតូចៗរស់នៅប្រមូលផ្តុំគ្នារបៀបជាកុលសម្ព័ន្ធ។ ចំណែកមុខរបររបស់អ្នកភូមិ គឺអាស្រ័យផលលើព្រៃឈើ គឺរកជ័រទឹក និងជ័រចុង។ ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ខ្ញុំនិងក្មេងៗដទៃទៀតនៅក្នុងភូមិបានរត់លេងក្នុងព្រៃ និងបានឃើញគ្រាប់មិនទាន់ផ្ទុះជាច្រើន។ ខ្ញុំនឹងក្មេងៗ បានដុតគ្រាប់ទាំងនោះឲ្យផ្ទុះ ហើយពេលត្រឡប់មកផ្ទះវិញត្រូវឪពុកខ្ញុំស្តីបន្ទោស ពីព្រោះគាត់ខ្លាចមានគ្រោះថ្នាក់ដែលបណ្តាលឲ្យរងរបួសឬស្លាប់។ កាលពីប៉ុន្មានឆ្នាំមុននេះ ខ្ញុំ និងគណៈកម្មាធិការភូមិបានសម្រេចអភិរក្សវាលមួយកន្លែងមានឈ្មោះថា វាលខ្លោល គឺជាទីតាំងប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានឃើញ។ ទីវាលនោះគឺជាកន្លែងដែលកងទ័ពសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកបេ៥២ ហើយនៅមានសេសសល់រណ្តៅ គ្រាប់បេ ៥២ ជាច្រើនកន្លែង។ យើងបានឯកភាពគ្នាថាមិនអនុញ្ញាតឲ្យប្រជាជនកាប់ឆ្ការ ឬឈូសលុបទីតាំងរណ្តៅគ្រាប់បែកបេ៥២នេះទេ គឺទុកសម្រាប់ឲ្យក្មេងជំនាន់ក្រោយបានស្គាល់។

នៅអំឡុងឆ្នាំ១៩៨៥ ឬឆ្នាំ១៩៨៦ កងទ័ពវៀតណាមបានចុះមកបោះទីតាំងបន្ទាយ និងមន្ទីរពេទ្យក្នុងភូមិសាទុំ ដោយគាស់យកសាកសពកងទ័ពវៀតកុងដែលបានកប់នៅក្បែរបន្ទាយ និងមន្ទីរពេទ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។




ឯម ឆន កំពុងផ្តល់បទសម្ភាសន៍មកកាន់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ (វីលក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឯម ឆន ឬ ម៉ី ឆន ភេទប្រុស អាយុ៦១ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិ សាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ ឪពុកខ្ញុំឈ្មោះ ម៉ី និងម្តាយឈ្មោះ យ៉ុំ។ ខ្ញុំមានកូនចំនួន ៥នាក់ គឺប្រុសចំនួន ៤នាក់ ស្រីចំនួន ១នាក់។ កាលពីតូចខ្ញុំរៀនបានត្រឹមថ្នាក់ទី ២ ដោយសារតែមានការទម្លាក់គ្រាប់បែកញឹកញាប់ និងការបាញ់ផ្លោងរវាងទាហានសហរដ្ឋអាមេរិកនិងកងទ័ពវៀតកុង។ នៅចុងឆ្នាំ១៩៦០ កងទ័ពវៀតកុងបានមកបោះទីតាំងនៅតាមព្រំដែនកម្ពុជាវៀតណាម និងចូលមកក្នុងទឹកដីប្រទេសកម្ពុជាសាងសង់បន្ទាយ ព្រមទាំងមន្ទីរពេទ្យនៅក្នុងព្រៃ ដូចជា ព្រៃក្បាលដាំជ្រៃ និងព្រៃកញ្ឆន់ជាដើម។ កងទ័ពវៀតកុងបានប្រមូលទិញអង្ករ គោ ក្របី ជ្រូក និងបន្លែបង្ការពីប្រជាជនកម្ពុជាសម្រាប់ជាស្បៀងដល់កងទ័ពរបស់ខ្លួន ។ មន្ទីរពេទ្យរបស់វៀតកុងដែលសាងសង់នៅក្នុងព្រៃកញ្ឆន់ គឺជីកទៅក្រោមដីដើម្បីធ្វើជាកន្លែងវះកាត់ ហើយខាងលើដីប្រក់តង់ សម្រាប់ឲ្យអ្នកជំងឺសម្រាក។ អ្នកជំងឺភាគច្រើនជាកងទ័ពវៀតកុងដែលត្រូវរបួស និងប្រជាជនដែលត្រូវរបួសដោយសារគ្រាប់ផ្លោងរបស់សហរដ្ឋអាមេរិក និងទាហានធីវគី។ នៅពេលមានការទម្លាក់គ្រាប់បែកបេ ៥២ កាន់តែច្រើននៅក្នុងព្រៃក្បែរភូមិសាទុំ ប្រជាជនបានភៀសខ្លួនចេញពីភូមិមកស្នាក់នៅភូមិដូងដែលជាភូមិមួយមានចម្ងាយប្រហែល ១០គីឡូម៉ែត្រប៉ែកខាងលិចភូមិសាទុំ។ នៅក្នុងឆ្នាំ១៩៧៤ ពេលសភាពការស្ងប់ស្ងាត់ លែងមានការទម្លាក់គ្រាប់បែក និងយន្តហោះក្បែរភូមិ ទើបប្រជាជនមករស់នៅ

ក្នុងភូមិសាទុំវិញ។ ប្រជាជនបានបន្តប្រកបរបរដាំស្រូវសម្រាប់ចិញ្ចឹមជីវិត។ នៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រងក្នុងភូមិរបស់ខ្ញុំក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យចូលក្នុងកងចល័ត ធ្វើស្រែ លើកភ្លឺស្រែ លើកទំនប់ និងជីកប្រឡាយ។

នៅដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំទៅវែកដីធ្វើទំនប់នៅបឹងក្រចាប់ ស្ថិតនៅក្នុងស្រុកត្បូងឃ្មុំ ក្បែរស្ពានមាត់ខ្វង់ជាមួយយុវជនប្រហែល ៣០នាក់ផ្សេងទៀតនៅក្នុងភូមិ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ខ្មែរក្រហមបានជ្រើសខ្ញុំឲ្យទៅធ្វើទាហាននៅខេត្តព្រៃវែង។ ខ្ញុំបានហាត់រៀនយុទ្ធសាស្ត្រយោធានៅសាលាស ២០៣ ក្នុងខេត្តព្រៃវែងរយៈពេល៦ខែ។ បន្ទាប់មកខ្ញុំបានបន្តស្នាក់នៅខេត្តព្រៃវែងរយៈពេល ៦ខែទៀត។ ប៉ុន្តែខ្ញុំមិនបានចូលសមរភូមិប្រយុទ្ធទេ ដោយខ្ញុំត្រូវបានជ្រើសឲ្យចូលធ្វើកម្មករជួសជុលសម្ភារយុទ្ធភ័ណ្ឌចាស់ៗ ។ នៅក្នុងមួយក្រុមរបស់ខ្ញុំមានសមាជិកចន្លោះពី ២០ ទៅ ៣០នាក់។ សម្ភារដែលជួសជុលរួមមាន កាំភ្លើង និងសម្ភារសម្រាប់បម្រើដល់ការប្រយុទ្ធ។ អង្គភាពរបស់ខ្ញុំមានប្រធានឈ្មោះ ហេង។ ក្រោយព្រឹត្តការណ៍ចោទប្រកាន់ភូមិភាគបូព៌ាក្បត់ កងទ័ពមកពីភូមិភាគនិរតីបានជម្លៀសខ្ញុំ និងកម្មករផ្សេងៗទៀត ទៅព្រែកពោធិ៍ ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ នៅព្រែកពោធិ៍ខ្ញុំនិងសមាជិកដទៃទៀតត្រូវបានចាត់តាំងឲ្យធ្វើស្រែរយៈពេលមួយឆ្នាំ ទើបកងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជា។ នៅពេលខ្មែរក្រហមដួលរលំ ខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែមិនបានជួបជាមួយឪពុកម្តាយទេ ព្រោះឪពុកម្តាយខ្ញុំត្រូវខ្មែរក្រហមជម្លៀសឲ្យទៅខេត្តក្រចេះ។ រយៈពេលកន្លះខែ ទើបឪពុកម្តាយខ្ញុំត្រឡប់មកដល់ស្រុកកំណើតវិញ។ ខ្ញុំរៀបការនៅឆ្នាំ ១៩៨៨ និងបានរស់នៅភូមិសាទុំរហូតដល់សព្វថ្ងៃ។


ផ្ទះរបស់ ឯម ឆន ខែវិច្ឆិកា ឆ្នាំ២០២១ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)


តូច អ៊ិន នៅផ្ទះរបស់គាត់។
(ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ តូច អ៊ិន អាយុ៩១ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិស្រម៉រ ឃុំទឹកជ្រៅ ស្រុកដំបែរ ខេត្តកំពង់ចាម។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានតែបងប្រុសម្នាក់។ កាលខ្ញុំនៅក្មេង ខ្ញុំមិនបានរៀនសូត្រទេ ដោយសារនៅក្នុងភូមិកំណើតរបស់ខ្ញុំមិនមានសាលារៀន។ ខ្ញុំនៅផ្ទះធ្វើស្រែចម្ការជាមួយឪពុកម្តាយ។ ក្រោយមកខ្ញុំចេញពីផ្ទះធ្វើការជាអ្នករត់តុកាហ្វេ និងវាយសារ៉ាស្បែកជើងនៅសួងក្នុងស្រុកត្បូងឃ្មុំ។ ក្រោយមកខ្ញុំបានចូលធ្វើទាហានជាមួយបារាំងនៅសួងបានរយៈពេល៥ឆ្នាំ និងខ្ញុំរៀបការជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ សួន

(ស្លាប់)។ ក្រោយមកខ្ញុំផ្លាស់មករស់នៅក្នុងភូមិមួង ឃុំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម និងបានរៀបការប្រពន្ធទី ២ទៀត។ នៅមួងខ្ញុំ និងក្រុមគ្រួសារបានប្រកបរបរធ្វើស្រែចម្ការដូចអ្នកភូមិដទៃទៀតដែរ។ នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំ និងក្រុមគ្រួសារបានផ្លាស់មករស់នៅក្នុងភូមិសាទុំ ដោយសារនៅភូមិមួង មានចលនាខ្មែរក្រហមចូលមកអុកឡុកយាយីប្រជាជនរស់នៅក្នុងភូមិ និងតាមចាប់ខ្ញុំ។ ពេលខ្មែរក្រហមចូលកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យភ្ជួរស្រែ និងធ្វើស្រែចម្ការ។ នៅភូមិសាទុំខ្ញុំហូបមិនគ្រប់គ្រាន់ឡើយ គឺមួយថ្ងៃខ្ញុំហូបពីរពេលប៉ុណ្ណោះ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀសខ្ញុំនិងប្រពន្ធកូនទៅរស់នៅភូមិព្រែកតាហុប ឃុំជំនីក ស្រុកក្រូចឆ្មារ។ នៅទីនោះខ្មែរក្រហមចាត់តាំងឲ្យខ្ញុំឃ្វាលក្របី និងភ្ជួរស្រែ។ ថ្ងៃមួយខ្ញុំបានដេរក្របីថា «អារីកមីចម្រើន»។ បន្ទាប់មកក៏មានអ្នកទៅរាយការណ៍ប្រាប់ប្រធានកងតូច និងមានឈ្លបពីរនាក់ កាន់កាំភ្លើង៣ដើមសួររកខ្ញុំ។ ខណៈពេលនោះខ្ញុំកំពុងតែជម្រះស្មៅ កងឈ្លបបាននាំខ្ញុំទៅកាន់សាលាស្រុកក្រូចឆ្មារ។ នៅពេលនោះខ្ញុំបានជួបគណៈស្រុកក្រូចឆ្មារដែលខ្ញុំធ្លាប់បានជួបកាលពីពេលមុនៗ។ គណៈស្រុកបានសួរឈ្លបថា មានរឿងអីបានជាចាប់គាត់? កងឈ្លបរាយការណ៍ប្រាប់គណៈស្រុកតាមដំណើររឿងរួច គណៈស្រុកឆ្លើយថាខ្ញុំតែងតែនិយាយតែអ៊ីចឹង និងបញ្ជាឲ្យកងឈ្លបដោះលែងខ្ញុំត្រឡប់មកវិញ។ ពេលខ្ញុំរស់នៅស្រុកក្រូចឆ្មារ គឺត្រូវក្រោកម៉ោង៤ភ្លឺ ទៅភ្ជួរស្រែ ហើយនៅម៉ោង១០ សម្រាកព្រោះមេឃក្តៅក្របីដើរមិនរួច។ រហូតដល់ម៉ោង ២ ឬ៣ រសៀលទើបខ្ញុំចុះភ្ជួរបន្តទៀត។ ខ្ញុំរស់នៅក្រូចឆ្មារបានមួយរយៈក៏ត្រឡប់មកនៅឃុំជាំតាម៉ៅ។ ប៉ុន្មានថ្ងៃក្រោយមកខ្មែរក្រហមបានជម្លៀសខ្ញុំបន្តទៅនៅស្រុកស្នួល ខេត្តក្រចេះ ដែលជាកន្លែងលំបាកវេទនា ហើយប្រជាជនជាច្រើននាក់បានស្លាប់ដោយអត់អាហារ។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបន្តជម្លៀសខ្ញុំទៅនៅភូមិភាគកណ្តាល ដោយធ្វើដំណើរតាមកាណូតពីខេត្តក្រចេះទៅស្រុកស្ទឹងត្រង់ និងបន្តទៅរស់នៅក្នុងស្រុកចំការលើ។ ក្រោយពេលខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំនិងក្រុមគ្រួសារបានត្រឡប់មកនៅភូមិសាទុំ ដោយប្រកបរបរកាប់ដីធ្វើស្រែ និងដាំដំណាំ។

---



សៀវ ម៉ៅ កំពុងរៀបរាប់អំពីជីវិតឆ្លងកាត់របបខ្មែរក្រហមប្រាប់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សៀវ ម៉ៅ ភេទស្រី អាយុ៦៩ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ម្តាយរបស់ខ្ញុំឈ្មោះ សាន់ និងឪពុកឈ្មោះ ស៊ីវ។ ខ្ញុំមានបងប្អូនចំនួន៧នាក់ គឺស្រីចំនួន៤ និងប្រុសចំនួន៣។ ប្តីរបស់ខ្ញុំឈ្មោះ ឃោករស់ ហើយយើងមានកូនចំនួន១៣នាក់ គឺស្រី១០នាក់ និងប្រុសចំនួន៣នាក់។ កាលពីខ្ញុំនៅក្មេងខ្ញុំមិនបានរៀនសូត្រទេ ដោយសារមិនទាន់មានសាលារៀននៅក្នុងភូមិ។ ដូច្នេះខ្ញុំត្រូវនៅផ្ទះជួយធ្វើកិច្ចការផ្ទះ និងជួយធ្វើស្រែចម្ការឪពុកម្តាយ។ កាលនោះក្នុងភូមិមានកងទ័ពវៀតកុងចូលមកក្នុងព្រៃក្បែរភូមិសាទុំដើម្បីទិញអង្ករ និងបន្លែបង្ការពីអ្នកភូមិ។ ពេលមានទ័ពវៀតកុងចូលក្នុងភូមិ ក៏មានយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកដើម្បីដេញកងទ័ពវៀតកុង។ នៅឆ្នាំ១៩៦៨ ខ្ញុំនិងអ្នកភូមិដទៃទៀតបានរត់គៀសខ្លួនទៅភូមិត្រមូង។ ទៅដល់ទីនោះខ្ញុំនិងគ្រួសារធ្វើ

ស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ នៅឆ្នាំ១៩៧០ ខ្ញុំបានរៀបការជាមួយនឹងប្ដីរបស់ខ្ញុំដែលបានរត់មកពីភូមិសាទុំជាមួយគ្នា។ ខ្ញុំរៀបការមិនបានប៉ុន្មានផង ក៏មានទាហានអាមេរិកទៅដល់ត្រមូងទៀត។ បន្ទាប់មកខ្ញុំ និងក្រុមគ្រួសារបានរត់ភៀសខ្លួនទៅកន្លែងផ្សេងទៀត។ នៅឆ្នាំ១៩៧៣ ខ្ញុំ និងគ្រួសារត្រឡប់មកនៅភូមិសាទុំវិញ។ នៅពេលនោះខ្ញុំ និងគ្រួសារត្រូវបានចាត់តាំងឲ្យធ្វើស្រែចម្ការប្រវាស់ដៃជាមួយអ្នកភូមិផ្សេងទៀត។ បន្ទាប់ពីធ្វើប្រវាស់ដៃបានមួយរយៈ ខ្មែរក្រហមបានចាត់តាំងប្រជាជននៅក្នុងភូមិឲ្យធ្វើការងាររួម និងហូបរួមនៅក្នុងសហករណ៍។

នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងអ្នកភូមិទាំងអស់ឲ្យទៅរស់នៅភូមិបឹង ឃុំស្រែរនាម ស្រុកស្នួល ខេត្តក្រចេះ។ នៅទីនោះពិបាកវេទនាខ្លាំងណាស់ ដោយសារខ្មែរក្រហមចោទប្រជាជនជម្លៀសពីភូមិភាគបូព៌ាថា ក្បាលយួនខ្លួនខ្មែរ។ ខ្មែរក្រហមបានបង្ខំប្រជាជនជម្លៀសទាំងនោះឲ្យធ្វើការងារធ្ងន់ៗ ដូចជា កាប់គល់ឈើ ធ្វើស្រែ និងហូបតែទឹកបបររាវៗដែលជាហេតុនាំឲ្យប្រជាជនស្លាប់ជាច្រើននាក់។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងអ្នកភូមិដទៃទៀតទៅស្រុកចំការលើ ដោយធ្វើដំណើរតាមកាណូតពីខេត្តក្រចេះមកឈប់នៅស្រុកស្ទឹងត្រង់។ បន្ទាប់មកខ្ញុំជិះឡានពីស្ទឹងត្រង់ ទៅស្រុកចំការលើបន្តទៀត។ បន្ទាប់ពីកងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំនិងក្រុមគ្រួសារបានធ្វើដំណើរពីស្រុកចំការលើមកស្រុកមេមត់វិញ។ ពេលត្រឡប់មកវិញ ខ្ញុំមិនទាន់ចូលភូមិកំណើតទេ ព្រោះខ្លាចជាន់មីន ។ ខ្ញុំរង់ចាំរហូតដល់អ្នកស្រុកដុតភូមិដើម្បីបំបែកមីនអស់ ទើបខ្ញុំចូលទៅភូមិ។ បន្ទាប់ពីមកដល់ភូមិខ្ញុំកាប់ចម្ការ ដាំដំណាំ និងដាំកៅស៊ូសម្រាប់ចិញ្ចឹមជីវិត។



ពៅ ប៊ុច នៅផ្ទះរបស់គាត់។
( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ខ្ញុំឈ្មោះ ពៅ ប៊ុច អាយុ៨៥ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិថ្មតាដោក ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ពៅ ប្រុក និង ម្ដាយឈ្មោះ ចឹក។ ខ្ញុំមានបងប្អូនបង្កើតចំនួន៣នាក់ គឺប្រុសចំនួន១នាក់ និងស្រីចំនួន២នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ សួនមុំ យើងមានកូនចំនួន៧ នាក់ គឺស្រី៦ និងប្រុស១។ កាលពីខ្ញុំនៅក្មេងៗឪពុកម្ដាយបានផ្លាស់មករស់នៅភូមិសាទុំ បន្ទាប់មកខ្ញុំទៅរស់នៅជាមួយគ្រួសារឪពុកធំនៅ ទីរួមស្រុកមេមត់ និងបានចូលរៀននៅសាលាវត្តមេមត់ក្នុងទីរួមស្រុកមេមត់។ បន្ទាប់ពីឈប់រៀន ខ្ញុំបានចូលធ្វើទាហានជើងក្រហមរបស់បារាំងនៅជប់ ស្រុកត្បូងឃ្មុំ។ បន្ទាប់ពីឈប់ធ្វើទាហានជើងក្រហម ខ្ញុំបានទៅធ្វើកម្មករនៅផ្ទះចិននៅ ទន្លេបិទបានរយៈពេលមួយឆ្នាំ។ ថៅកែចិននោះបញ្ជូនខ្ញុំឲ្យទៅរៀនជួសជុល និងបើកបរ ឡាននៅក្រុងកំពង់ចាម។ បន្ទាប់ពីរៀនចេះចប់ហើយ ខ្ញុំសុំអនុញ្ញាតថៅកែចិនមកលេងផ្ទះ ព្រោះនឹកផ្ទះ ប៉ុន្តែថៅកែចិនមិនអនុញ្ញាត ខ្ញុំក៏រត់ត្រឡប់មកផ្ទះវិញតែម្ដង។ ក្នុងសម័យនោះនៅក្នុងភូមិសាទុំ សម្បូរសត្វខ្លាណាស់។ នៅពេលយប់ឡើង ខ្លាចូលមកខាំអូសជ្រូកយកទៅស៊ី ជាហេតុនាំឲ្យអ្នកភូមិមានការខ្លាចរអា និងនាំកូនចៅស្នាក់នៅតែក្នុងផ្ទះនៅពេលយប់ គឺមិនហ៊ានចេញទៅក្រៅឡើយ។ នៅទសវត្សរ៍ឆ្នាំ១៩៦០ ខ្ញុំធ្លាប់រកស៊ីលក់អង្ករឲ្យកងទ័ពវៀតកុង ដែលចូលមកក្នុងទឹកដីកម្ពុជា

ក្បែរភូមិសាទុំ។ កងទ័ពវៀតកុងបានទិញអង្ករ ទិញបន្លែ គោ ក្របី និងផ្លែ ពីអ្នកភូមិ។ កងទ័ពវៀតកុងបានសង់បន្ទាយ មន្ទីរពេទ្យជាច្រើនកន្លែងនៅក្នុងព្រៃក្បែរភូមិសាទុំ។ បន្ទាប់មកមានទាហានសហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែកជាច្រើន ជាហេតុធ្វើឲ្យប្រជាជនក្នុងភូមិភៀសខ្លួនទៅរស់នៅភូមិផ្សេងៗទៀត។ នៅឆ្នាំ១៩៧៤ ប្រជាជនក្នុងភូមិសាទុំបានត្រឡប់មករស់នៅក្នុងភូមិវិញ ហើយខ្មែរក្រហមបានចាប់ផ្តើមប្រមូលប្រជាជនឲ្យធ្វើស្រែចម្ការប្រវាស់ដៃ។ បន្ទាប់ពីខ្មែរក្រហមចូលកាន់អំណាចនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំឲ្យអ្នកភូមិប្រមូលរបស់របរដាក់រួមនៅក្នុងសហករណ៍ និងត្រូវធ្វើការងាររួម និងហូបរួម។ នៅពេលនោះខ្មែរក្រហមបានចាត់តាំងខ្ញុំធ្វើស្រែចម្ការ និងដកស្ទូង។ ខ្ញុំបានធ្វើស្រែនៅក្នុងភូមិបានជាង១ឆ្នាំ ខ្មែរក្រហមជម្លៀសខ្ញុំ និងប្រជាជនក្នុងភូមិសាទុំទាំងអស់ទៅរស់នៅក្នុងស្រុកស្នួល ខេត្តក្រចេះ ។ នៅទីនោះមានការអត់ឃ្លានខ្លាំង គឺខ្មែរក្រហមចាត់តាំងឲ្យខ្ញុំ និងប្រជាជនជម្លៀសធ្វើស្រែចម្ការ និងហូបតែទឹកបបររាវៗ។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងអ្នកភូមិបន្តទៅថ្មក្រែ ខេត្តក្រចេះ និងឡើងជិះកាណូតទៅស្រុកស្ទឹងត្រង់។ បន្ទាប់មកខ្ញុំជិះឡានបន្តទៅស្រុកចំការលើ ស្ថិតនៅក្នុងភូមិភាគកណ្តាល។ ខ្ញុំរស់នៅចំការលើបានជាងមួយខែកងទ័ពវៀតណាមបានចូលមកដល់ប្រទេសកម្ពុជា។ ខ្ញុំត្រឡប់ទៅមេមត់ ដោយដើររហូតដល់ស្រុកកំណើតខ្ញុំ។



ឃ្លោក រស់ (រី លក្ខិណា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឃ្លោក រស់ អាយុ៧៥ឆ្នាំ។ ខ្ញុំមានឪពុកឈ្មោះ ស្រេម ឃ្លោក និង ម្តាយឈ្មោះ ទូច និង មានបងប្អូនចំនួន៥នាក់។ ខ្ញុំមានកូនចំនួន៨នាក់ គឺប្រុសចំនួន៣នាក់ និងស្រីចំនួន៥នាក់។ សម័យនោះ ចាស់ៗនៅក្នុងភូមិដែលចេះអាន ចេះសរសេរ មកបង្រៀនក្មេងនៅតាមផ្ទះ។ ខ្ញុំរៀនបានរយៈពេលប្រហែល១ទៅ២ខែក៏ឈប់រៀន។ ខ្ញុំមិនទាន់ចេះអាន និងចេះសរសេរអក្សរច្បាស់លាស់ទេ។ នៅចុងឆ្នាំ១៩៦០ មានយន្តហោះសហរដ្ឋអាមេរិកមកទម្លាក់តាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។ នៅឆ្នាំ១៩៦៦ មានទ័ពវៀតកុងបោះបន្ទាយនៅជុំវិញភូមិ គឺនៅព្រៃខ្លោល ព្រៃរលាក និងព្រៃជញ្ជាត់ដៃ។ នាសម័យនោះប្រជាជនជីកលេណដ្ឋានលាក់ខ្លួនពេលគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែក។ បន្ទាប់មកប្រជាជនរស់នៅភូមិសាទុំ បានភៀសខ្លួនមកនៅភូមិដូង ឃុំជាំក្រវៀន ស្រុកមេមត់។ នៅឆ្នាំ១៩៧០ ប្រជាជនមួយចំនួនបានបន្តភៀសខ្លួនទៅរស់នៅភូមិក្បែរៗទីរួមស្រុកមេមត់។ ខ្ញុំ និងក្រុមគ្រួសារក៏បានភៀសខ្លួនទៅរស់នៅភូមិត្រមូងក្បែរទីរួមស្រុកមេមត់ដែរ។ នៅឆ្នាំ១៩៧០ ខ្ញុំបានរៀបការប្រពន្ធ ហើយរស់នៅ និងធ្វើស្រែចម្ការនៅឃុំរូង។

នៅឆ្នាំ១៩៧៣ ប្រជាជនបានត្រឡប់មករស់នៅស្រុកកំណើតនៅភូមិសាទុំវិញ ដោយពេលនោះមានប្រជាជនប្រមាណពី៣០ទៅ៤០គ្រួសារប៉ុណ្ណោះ។ កងកម្លាំងរណសិរ្សរួបរួមជាតិកម្ពុជា បានរៀបចំ ប្រជាជនឲ្យធ្វើការងារប្រវាស់ដៃគ្នាវិញ។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ ប្រជាជនត្រូវបានបង្ខំឲ្យចូលសហករណ៍និងត្រូវទៅធ្វើការងារស្រែចម្ការ។ នៅពេលដល់ម៉ោងហូបបាយប្រធានកងវាយជួងជាសញ្ញាឲ្យយើងទាំងអស់គ្នាទៅ ហូបបាយនៅរោងបាយសហករណ៍។ បន្ទាប់ពីហូបបាយពេលថ្ងៃ

ត្រង់រួចយើងត្រូវចេញទៅវាលស្រែដឹកប្រឡាយ ដោយមានអ្នកមកពីភូមិផ្សេងមកបង្រៀនធ្វើការងារលើកភ្លឺស្រែ និងជីកប្រឡាយ។ ខ្ញុំធ្វើការងារចាប់ពីម៉ោង៧ ព្រឹករហូតដល់ម៉ោង១១:០០ ថ្ងៃ បន្ទាប់មកយើងសម្រាកហូបបាយថ្ងៃត្រង់។ នៅវេលាម៉ោង ១:០០ ម៉ោង ២:០០ រសៀល ខ្ញុំត្រូវចូលធ្វើការវិញរហូតដល់ម៉ោង ៦:០០ ល្ងាចទើបខ្មែរក្រហមវាយជួងឲ្យយើងទៅហូបបបរ និងសម្រាក។ នៅរដូវប្រមូលកាត់យើងត្រូវធ្វើការងារបន្ថែម គឺបែនស្រូវនៅពេលយប់។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាត់តាំងខ្ញុំទៅលើកទំនប់បឹងចាប់រយៈពេលមួយឆ្នាំទើបត្រឡប់មកវិញ។ បន្ទាប់មកខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើទំនប់បឹងក្រចាប់ជាលើកទី២ទៀត រយៈពេលពីរទៅបីខែទៀត។ នៅចុងឆ្នាំ១៩៧៧ ខ្ញុំ និង ប្រពន្ធកូនត្រូវខ្មែរក្រហមជម្លៀសទៅភូមិតាអឹម ឃុំដាំតាម៉ៅ។ នៅទីនោះខ្មែរក្រហមឲ្យខ្ញុំហូបតែពោត និងទឹកបបរតែប៉ុណ្ណោះ។ ពេលនោះ មនុស្សប្រុសឆាប់អស់កម្លាំងជាងមនុស្សស្រី ហើយពេលខ្លះដួលនៅនឹងកន្លែង។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមជម្លៀសខ្ញុំតាមកាណូតពីខេត្តក្រចេះមកស្រុកស្ទឹងត្រង់ និងបន្តជិះឡានមករស់នៅភូមិអូរក្រវ៉ាន់ ឃុំចម្ការអណ្តូង ស្រុកចំការលើ។ ខ្ញុំនៅទីនោះបានប្រមាណរយៈពេល១ខែ ទើបកងទ័ពវៀតណាមចូលមកដល់ទើបខ្ញុំត្រឡប់មកផ្ទះវិញ។ នៅពេលដែលខ្ញុំត្រឡប់មកផ្ទះ ខ្ញុំបានទៅសុំគ្រាប់ស្រូវពូជពីប្រជាជនវៀតណាមយកមកដាំដុះសម្រាប់ចិញ្ចឹមជីវិត។



ស៊ីវ ចាន់ (គាត ស្រីខ្លួន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ីវ ចាន់ ភេទស្រី អាយុ៧២ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ ស៊ីវ និងម្តាយឈ្មោះ សាន់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់ ស្រីចំនួន៤នាក់ និងប្រុសចំនួន៣នាក់។ សព្វថ្ងៃបងប្អូនរបស់ខ្ញុំនៅរានមានជីវិតចំនួន៤នាក់។ ប្តីរបស់ខ្ញុំឈ្មោះ ព្រីក ឈៀង ហើយយើងមានកូនចំនួន៤នាក់ ស្រីចំនួន២នាក់ និងប្រុសចំនួន២នាក់។ កូនរបស់ខ្ញុំស្លាប់អស់ចំនួន៣នាក់ នៅក្នុងជំនាន់ខ្មែរក្រហមព្រោះអត់អាហារហូប។

កាលពីក្មេងៗខ្ញុំមិនបានរៀនសូត្រទេ ព្រោះតែក្នុងភូមិរបស់ខ្ញុំគ្មានសាលារៀន។ បើចង់ទៅរៀនខ្ញុំត្រូវដើរចម្ងាយ១០គីឡូម៉ែត្រ។ ដោយសារតែជីវភាពខ្វះខាត និងមានបងប្អូនច្រើន ខ្ញុំត្រូវជួយធ្វើចម្ការដាំស្រូវម្តាយឪពុក។ ពេលដែលឪពុកម្តាយខ្ញុំប្រមូលផល សណ្តែក ល្ង ស្រូវ រួចយើងត្រូវដឹកតាមរទេះយកទៅដូរអំបិល ប្រហុក នៅផ្សារមេមត់។ ពេលទៅផ្សារមេមត់ម្តងៗ ខ្ញុំត្រូវដេកផ្លូវរយៈពេល ២ យប់ទើបត្រឡប់មកវិញ។ ពេលដែលទាហានសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកច្រើននៅក្នុងភូមិរបស់ខ្ញុំ ដើម្បីដេញកងទ័ពវៀតកុង ប្រជាជនក្នុងភូមិក៏ភៀសខ្លួនទៅនៅភូមិប្រិយ ឃុំដាំក្រវៀនរយៈពេលប្រហែល៣ឆ្នាំ ទើបមករស់នៅក្នុងភូមិសាទុំវិញ។ ពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រង ខ្មែរក្រហមឲ្យខ្ញុំទៅកាប់ដីដាំពោត។ ថ្ងៃមួយសហករណ៍មិនយកបាយទៅឲ្យអ្នកកាប់ពោត ដូច្នេះខ្ញុំនិងអ្នកកាប់ពោតបាននាំគ្នាលួចពោតហូប ហើយកប់ក្នុងដី ប៉ុន្តែមានអ្នកមកឃើញសម្បកពោត ក៏រាយការណ៍ទៅកងឈ្លប និងគណៈឃុំដាំក្រវៀនឈ្មោះ ចំរ៉ុង។ ឈ្លបប្រុងនឹងបាញ់សម្លាប់ខ្ញុំចោល ប៉ុន្តែប្រធានភូមិឈ្មោះ តាខ្ចិច បានអង្វរថា

កុំអាលសម្លាប់ ចាំពេលដែលខ្ញុំប្រព្រឹត្តខុសម្តងទៀត ចាំសម្លាប់ចោល។ ខ្ញុំត្រូវកងឈ្លបទាត់ម្នាក់មួយជើង ហើយចាប់ពីពេលនោះ ខ្ញុំមិនហ៊ានលួចទៀតទេ។ រយៈពេលមួយឆ្នាំក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅខេត្តក្រចេះ។ នៅទីនោះ ឈ្មោះសូត្រ គឺជាជនជាតិស្ទៀង បានឲ្យខ្ញុំកាស់គល់ឈើ ដើម្បីរានដីធ្វើចម្ការ។ ខ្ញុំធ្វើការនៅក្នុងភូមិបានរយៈពេល៨ខែ កូនៗរបស់ខ្ញុំ៣នាក់បានស្លាប់ព្រោះតែមិនមានអាហារហូបគ្រប់គ្រាន់។ នៅពេលនោះមានកងទ័ពវៀតណាមចូលមក ខ្មែរក្រហមក៏ជម្លៀសខ្ញុំមកថ្មគ្រែ ហើយឆ្លងកាណូតមកកំពង់ចាមវិញ។ ខ្ញុំជិះឡានមកដល់ចំការលើ ទើបកងទ័ពវៀតណាមមកទាន់។ កងទ័ពវៀតណាមបានឲ្យខ្ញុំនិងអ្នកភូមិត្រឡប់មករស់នៅស្រុកកំណើតវិញ។ ពេលមកដល់ស្រុកកំណើតខ្ញុំបានដើរស៊ីឈ្នួលវៀតណាម និងកាប់ឫស្សីដើម្បីលក់ឲ្យវៀតណាម។ ខ្ញុំបានដើររើសដែក ក៏ដូចជាសម្បកគ្រាប់របស់ទាហានសហរដ្ឋអាមេរិកលក់ទៅឲ្យឈ្មួញវៀតណាម។ រយៈពេល៣ឆ្នាំក្រោយមក ខ្ញុំបានបែកបាក់ជាមួយប្តីរបស់ខ្ញុំ ហើយខ្ញុំរស់នៅជាមួយកូនរហូតដល់សព្វថ្ងៃ។





ត្បាល់បុកគ្រឿងរបស់ប្រជាជននៅឃុំជាំតាម៉ៅ។ ខែវិច្ឆិកា ឆ្នាំ២០២១ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ទ្រូ ដែលជាឧបករណ៍នេសាទរបស់ប្រជាជននៅឃុំជាំតាម៉ៅ។ ខែវិច្ឆិកា ឆ្នាំ២០២១ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីែ ឡូន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទិដ្ឋភាពវាលស្រែនៅខែវិច្ឆិកា ឆ្នាំ២០២១។
(រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!



























# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ាវ៉ដ្ឋ មេត្តា

(តពីលេខមុន)

### ៩.១.៥. ការដាក់ក្នុងមន្ទីរឃុំឃាំង

**៦៨៧.** *ទាក់ទិនសំណុំរឿង០០២/០២ ដីកាដំណោះស្រាយបោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល និងតាមរយៈការប្រព្រឹត្តចំពោះជនជាតិចាម។*

**៦៨៨.** *អង្គជំនុំជម្រះបានសម្រេចពីមុនរួចមកហើយថា ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានទទួលស្គាល់ទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។ ពីដំបូង នៅក្នុងក្របខណ្ឌទំនៀមទម្លាប់នៃការហាមឃាត់ប្រឆាំងនឹងការដាក់ក្នុងមន្ទីរឃុំឃាំងតាមទំនើងចិត្ត ក្រោមច្បាប់អន្តរជាតិ ដែលបានវិវត្តពីច្បាប់សង្គ្រាម និងការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានទទួលស្គាល់ថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចាប់តាំងពីពេលដែលការហាមឃាត់នេះ ត្រូវបានបញ្ចូលទៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងនៅឆ្នាំ១៩៤៥។ ការហាមឃាត់ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានគាំទ្របន្ថែមទៀតដោយលិខិតុបករណ៍សិទ្ធិមនុស្សនៅក្នុងតំបន់អន្តរជាតិ ដែលមាននៅមុនឆ្នាំ១៩៧៥ផងដែរ។ ពាក់ព័ន្ធនឹងភាពអាចប្រមើលឃើញជាមុនថាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងអំពីការដាក់ក្នុងមន្ទីរឃុំឃាំង ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាអាជ្ញាធរគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីបានថ្លឹងថ្លែងទៅលើកត្តានុម័ត អង្គជំនុំជម្រះសន្និដ្ឋានថាជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថា ការដាក់ក្នុងមន្ទីរឃុំឃាំត្រូវបានសន្និដ្ឋានថាជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថា ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥។*

**៦៨៩.** *ធាតុផ្សំសត្យានុម័តនៃការដាក់ក្នុងមន្ទីរឃុំឃាំងរួមមាន ការដកហូតសេរីភាពរបស់បុគ្គលតាមទំនើងចិត្ត ដោយពុំមានដំណើរការតាមច្បាប់។ ការដកហូតសេរីភាពនៅពេលដំបូងនឹងក្លាយជាអំពើតាមទំនើងចិត្ត ប្រសិនបើគ្មានមូលដ្ឋានគតិយុត្តិដើម្បីធ្វើយុត្តិកម្មចំពោះអំពើនេះទេនោះ។ ប្រសិនបើមានការពឹងផ្អែកលើច្បាប់ជាតិដែលជាយុត្តិកម្មនៅក្នុងបញ្ហានេះ វាត្រូវតែមានការបង្ហាញថាបទប្បញ្ញត្តិដែលពាក់ព័ន្ធមិនបានរំលោភបំពានច្បាប់អន្តរជាតិនោះឡើយ។ មូលដ្ឋានផ្លូវច្បាប់ចំពោះការដកហូតសេរីភាពពីដំបូងត្រូវតែបន្តមានគ្រប់ពេលនៃការដាក់ក្នុងមន្ទីរឃុំឃាំង។ នៅពេលដែលមូលដ្ឋានស្របច្បាប់នៃការដាក់ក្នុងមន្ទីរឃុំឃាំងអាចត្រូវបានចាត់ទុកថាជាអំពើតាមទំនើងចិត្ត។*

**៦៩០.** *មេធាវីការពារក្តីលើកឡើងថា «គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមានបំណងធ្វើការស៊ើបអង្កេតនិងឃុំខ្លួនជនជាប់សង្ស័យពីសកម្មភាពខុសច្បាប់ ដែលបង្កគ្រោះថ្នាក់ដល់សន្តិសុខរដ្ឋប្ តំរាម*



អតីតមន្ទីរសន្តិសុខនៅវត្តចំពុះក្អែក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កំហែងដល់សង្គម» ហើយថានេះ «គឺជាការត្រឹមត្រូវតាមច្បាប់និងស្របច្បាប់»។ មេធាវីការពារក្តី នួន ជា លើកឡើងថាគោលនយោបាយនេះ« ស្របទៅនឹងគោលនយោបាយពាក់ព័ន្ធនឹងវិស័យសន្តិសុខជាច្រើននៅទូទាំងពិភពលោក» ហើយថា«បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តទម្រង់សង្ស័យពីការប្រព្រឹត្តបទល្មើស» និងសម្រាប់កំណត់មូលដ្ឋានគតិយុត្តិចំពោះការចាប់ខ្លួនពួកគេ។ មេធាវីការពារក្តីអះអាងថា ការអនុវត្តគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ គួរត្រូវបានវាយតម្លៃនៅក្នុងបរិបទនៃកាលៈទេសៈពិសេសដែលមានភាពអាសន្នជាសាធារណៈ ដែលអនុញ្ញាតឲ្យមានបដិប្បញ្ញត្តិខ្លះចំពោះកាតព្វកិច្ចរបស់រដ្ឋ ដែលពាក់ព័ន្ធនឹងការចាប់ខ្លួនបុគ្គល និងការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។ មេធាវីការពារក្តីអះអាងថា មាន«ដំណើរការលម្អិតនៃការតាមដានស៊ើបអង្កេត និងសួរចម្លើយប្រជាជន» ហើយថាការសន្និដ្ឋានសមហេតុផលមួយពីភស្តុតាងគឺថា ប.ក.ក. ពិតជាបានព្យាយាមដោយស្មោះត្រង់ ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលមានពិរុទ្ធភាពនៃសកម្មភាពខុសច្បាប់។ ភាគីដេញដោលមិនបានដាក់សារណាពាក់ព័ន្ធនឹងចំណុចនេះនោះទេ។

**៦៩១.** បញ្ហាសំខាន់ដែលអង្គជំនុំជម្រះត្រូវវាយតម្លៃគឺថា តើការដកហូតសេរីភាពមានមូលដ្ឋានគតិយុត្តិឬជាអំពើតាមទំនើងចិត្ត ដោយសារអំពើនេះត្រូវបានធ្វើឡើងឬប្រព្រឹត្តដោយគ្មានដំណើរការតាមច្បាប់ត្រឹមត្រូវដែរឬទេ។

**៦៩២.** ការដកហូតសេរីភាពរបស់បុគ្គលជាអំពើតាមទំនើងចិត្ត ប្រសិនបើអំពើនោះត្រូវបានធ្វើឡើងដោយពុំមានដំណើរការតាមច្បាប់ត្រឹមត្រូវ។ ក្នុងការវាយតម្លៃបែបនេះ អង្គជំនុំជម្រះពិចារណាឃើញថា អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប គឺមានសារសំខាន់ដោយ

សារតែអនុសញ្ញានេះមានរៀបរាប់ពីករណីផ្សេងៗ ដែលក្នុងនោះការដកហូតសេរីភាព« ស្របទៅនឹងនីតិវិធីចែងក្នុងច្បាប់» មិនមែនជាការរំលោភទៅនឹងសិទ្ធិមានសេរីភាពនិងសន្តិសុខនោះទេ។ ហេតុដូច្នេះហើយ ការដកហូតសេរីភាពមិនមែនជាអំពើតាមទំនើងចិត្ត ប្រសិនបើវាកើតចេញពី ( ក ) ការឃុំខ្លួនជនណាម្នាក់ដោយស្របច្បាប់ក្រោយពេលតុលាការមានសមត្ថកិច្ចបានផ្តន្ទាទោសរួចហើយ ( ខ ) ការចាប់ខ្លួនឬឃុំខ្លួនជនណាម្នាក់ដោយស្របច្បាប់ចំពោះការមិនអនុវត្តតាមដីកាបង្គាប់តាមផ្លូវច្បាប់តុលាការឬដើម្បីធានាដល់ការអនុវត្តកាតព្វកិច្ចនានាដែលមានចែងក្នុងច្បាប់ ឬ ( គ ) ការចាប់ខ្លួនឬឃុំខ្លួនជនណាម្នាក់ដោយស្របច្បាប់ ដែលមានគោលបំណងនាំខ្លួនជននោះមកកាន់អាជ្ញាធរមានសមត្ថកិច្ចតាមច្បាប់ ដោយមានការសង្ស័យសមហេតុសមផលថា ជននោះបានប្រព្រឹត្តបទល្មើសឬនៅពេលមានការយល់ឃើញថា ជាការចាំបាច់ដែលត្រូវទប់ស្កាត់មិនឲ្យជននោះប្រព្រឹត្តបទល្មើសឬគេចខ្លួនក្រោយពេលបានប្រព្រឹត្តបទល្មើស។ ក្នុងការវាយតម្លៃថាតើការដកហូតសេរីភាពនេះវា«ស្របច្បាប់ទៅនឹងនីតិវិធីដែលមានចែងក្នុងច្បាប់» ដែរឬយ៉ាងណា ដូច្នេះហើយ អង្គជំនុំជម្រះនឹងមិនត្រឹមតែពិចារណាថា តើវាស្របទៅនឹងច្បាប់ជាតិឬយ៉ាងណានោះទេ ប៉ុន្តែពិចារណាផងដែរថា តើការឃុំខ្លួននេះបានគោរពដល់គោលការណ៍ជាសារវ័ន្តនិងការការពារតាមច្បាប់អន្តរជាតិដែរឬទេ។

**៦៩៣.** ក្នុងករណីនេះ ការដាក់ក្នុងមន្ទីរឃុំឃាំងដែលបានធ្វើយុត្តិកម្មពីដំបូង អាចជាអំពើតាមទំនើងចិត្ត ប្រសិនបើការដកហូតសេរីភាពលើរូបកាយត្រូវបានធ្វើឡើងដោយ «បំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិជាសារវ័ន្តផ្នែកនីតិវិធី» តាមច្បាប់អន្តរជាតិ។ ក្នុងការវាយតម្លៃថាតើការឃុំខ្លួនត្រូវបានធ្វើឡើងដោយពុំមានដំណើរការតាមច្បាប់ឬយ៉ាងណាអង្គជំនុំជម្រះ



អតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហមនៅវត្តចំពុះក្អែក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អាចពិចារណាទៅលើការធានាជាមូលដ្ឋានផ្នែកនីតិវិធីដែលមានចែងនៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប។ ការធានាជាមូលដ្ឋានផ្នែកនីតិវិធីទាំងនេះ រួមមានសិទ្ធិក្នុងការទទួលបានការនាំខ្លួនឲ្យបានទាន់ពេលវេលានៅចំពោះមុខចៅក្រមឬមន្ត្រីដែលទទួលការអនុវត្តឲ្យអនុវត្តសិទ្ធិអំណាចតុលាការ សិទ្ធិទទួលការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប និងសិទ្ធិក្នុងការដំណើរការនីតិវិធី ដើម្បីសម្រេចទៅលើភាពស្របច្បាប់នៃការឃុំខ្លួននោះ។

**៦៩៤.** លើសពីនេះទៀត ក្នុងការវាយតម្លៃថាតើការដកហូតសេរីភាពត្រូវបានប្រព្រឹត្តដោយពុំមានដំណើរការតាមច្បាប់ឬយ៉ាងណានោះ វាគឺជាការសំខាន់ដែលត្រូវពិចារណាទៅលើការការពារផ្នែកនីតិវិធីដែលមាននៅក្នុងមាត្រា៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។ ទោះបីចំណុចនេះឆ្លើយតបទៅហ្នឹងការដកហូតសិទ្ធិរបស់ប្រជាជនស៊ីវិលក៏ដោយ មានការសន្និដ្ឋានថា នៅពេលដែលការការពារផ្នែកនីតិវិធីដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ IV មិនត្រូវបានអនុវត្តតាមករណីនេះអាចជាការពាក់ព័ន្ធក្នុងការធ្វើការវាយតម្លៃ ថាតើមានការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬយ៉ាងណា។ ការការពារនានាដែលមានចែងក្នុងមាត្រា ៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV រួមមានសិទ្ធិទទួលបានការពិចារណាជាថ្មីចំពោះការឃុំខ្លួនដោយបានការពិចារណាជាទៀងទាត់ចំពោះការឃុំខ្លួននេះ។

**៦៩៥.** អង្គជំនុំជម្រះនិងពិចារណាទៅលើលក្ខណៈវិនិច្ឆ័យទាំងនេះក្នុងការវាយតម្លៃថា តើនីតិវិធីនិងការអនុវត្តដែលកម្ពុជាប្រជាធិបតេយ្យបានប្រកាន់យកពាក់ព័ន្ធនឹងការឃុំខ្លួនបុគ្គលនៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗដែលបានចោទប្រកាន់ ធ្វើឲ្យមានការដកហូតសេរីភាពនៃដំណើរការតាមច្បាប់ដែរឬយ៉ាងណា។ ចំពោះចំណុចដែលមេធាវីការពារក្តី នួន ជា អះអាងថា មានមូលដ្ឋានគតិយុត្តិថ្នាក់ជាតិសម្រាប់ការដកហូតសេរីភាព អង្គជំនុំជម្រះនឹងវាយតម្លៃថា តើចំណុចនេះមានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជាឬទេ។ ដូចបានលើកឡើងខាងលើ ប្រសិនបើសំអាងទៅលើច្បាប់កម្ពុជា ដើម្បីធ្វើជាយុត្តិកម្ម ចំពោះការដកហូតសេរីភាព ហេតុដូច្នេះ បទប្បញ្ញត្តិទាំងនេះមិនត្រូវរំលោភបំពានទៅលើច្បាប់អន្តរជាតិនោះឡើយ។ ក្នុងការវាយតម្លៃទៅលើចំណុចនេះ វាជាការសំខាន់ដែលថា «ច្បាប់ជាតិផ្ទាល់មិនត្រូវជាច្បាប់តាមទំនើងចិត្តទេ» ហើយការអនុវត្តច្បាប់នេះទៀតសោតវាមិនមែនជាអំពើតាមទំនើងចិត្តនោះដែរ។

**៦៩៦.** មេធាវីការពារក្តី នួន ជា អះអាងថា តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងកាលៈទេសៈជាក់លាក់ រដ្ឋអាចធ្វើបដិប្បញ្ញត្តិកាតព្វកិច្ចរបស់ខ្លួនមួយចំនួនដែលពាក់ព័ន្ធនឹងការចាប់ខ្លួនបុគ្គលនិងការធានាការជំនុំជម្រះដោយយុត្តិធម៌ក្នុងពេលមានភាពអាសន្នជាសាធារណៈ។ ភាគីដេ្យងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងចំណុចនេះនោះទេ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលនិងសិទ្ធិនយោបាយពិតជាបានចែងដោយអនុញ្ញាតឲ្យធ្វើបដិប្បញ្ញត្តិកាតព្វកិច្ចមួយចំនួនប៉ុន្តែធ្វើបានតែក្នុងកាលៈទេសៈតិចតួចដែលត្រូវបានកំណត់យ៉ាងតឹងតែងប៉ុណ្ណោះ។ អនុលោមតាមមាត្រា៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បដិប្បញ្ញត្តិអាចធ្វើបានត្រឹមតែ «ក្នុងករណីមានភាពអាសន្នសាធារណៈពិសេសដែលគំរាមកំហែងដល់អត្ថិភាពជាតិ» ក្នុងលក្ខខណ្ឌដែលស្ថានភាពនេះត្រូវបានប្រកាសជាផ្លូវការតែប៉ុណ្ណោះ។ លើសពីនេះទៀតបដិប្បញ្ញត្តិត្រូវបាន អនុញ្ញាតតែ«ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ» ហើយក្នុងលក្ខខណ្ឌថា វិធានការទាំងនេះមិនមានវិសមតិភាពជាមួយនឹងកាតព្វកិច្ចរបស់ពួកគេតាមច្បាប់ឡើយ។ ស្រដៀងគ្នានេះដងដែរអនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប ក៏បានអនុញ្ញាតឲ្យរដ្ឋជាភាគី ធ្វើបដិប្បញ្ញត្តិកាតព្វកិច្ចមួយចំនួន «ក្នុងករណីប្រទេសមានសង្គ្រាមឬមានអាសន្នជាពិសេស ដែលគំរាមកំហែងដល់អត្ថិភាពជាតិ» ត្រឹមតែ«ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ» ហើយក្នុងលក្ខខណ្ឌថាវិធានការទាំងនេះមិនមានវិសមភាពជាមួយនឹងកាតព្

កិច្ចរបស់ពួកគេតាមច្បាប់អន្តរជាតិ ឡើយ។ លើសពីនេះទៀត រដ្ឋ«ដែលប្រើប្រាស់សិទ្ធិបដិប្បញ្ញត្តិ» ត្រូវបានតម្រូវឲ្យ «ផ្តល់ព័ត៌មានជាបន្តបន្ទាប់ដល់រដ្ឋភាគីឯទៀត[នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ]» នូវ «បទប្បញ្ញត្តិនិងមូលហេតុដែលខ្លួនបានធ្វើបដិប្បញ្ញត្តិនេះ»។ អង្គជំនុំជម្រះនឹងពិចារណាលើការណែនាំនេះនៅក្នុងការវាយតម្លៃថាតើប្រសិនបើផ្អែកលើអង្គហេតុនៃរឿងក្តីនេះ បដិប្បញ្ញត្តិនានាពាក់ព័ន្ធនឹងសិទ្ធិប្រឆាំងនឹងការឃុំខ្លួនតាមទំនើងចិត្តមានភាពស្របច្បាប់និងស្របទៅនឹងកាតព្វកិច្ចតាមច្បាប់អន្តរជាតិ ក្នុងអំឡុងពេលពាក់ព័ន្ធដែរឬទេ។

**៦៩៧.** ធាតុផ្សំសត្យានុម័តនៃការដាក់ក្នុងមន្ទីរឃុំឃាំង តម្រូវថាចារីមានចេតនាដកហូតសេរីភាពបុគ្គលតាមទំនើងចិត្ត ឬចារីបានប្រព្រឹត្តដោយដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឲ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល។

**៦៩៨.** មេធាវីការពារក្តី នួន ជា អះអាងថា នៅក្នុងការវាយតម្លៃថា តើការចាប់ខ្លួនជាអំពើតាមទំនើងចិត្តឬយ៉ាងណានោះ អង្គជំនុំជម្រះត្រូវពិចារណាទៅលើភាពសមហេតុផលនៃការចាប់ខ្លួនមន្ត្រីណាមួយដែលសង្ស័យថាកាលៈទេសៈផ្អែកអង្គហេតុតម្រូវឲ្យមានការចាប់ខ្លួន។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា មូលដ្ឋានអង្គហេតុចំពោះការសង្ស័យដែលសមហេតុផលមិនចាំបាច់ត្រូវឈានដល់កម្រិតមួយដែលត្រូវធ្វើការចោទប្រកាន់ជាផ្លូវការនោះទេ ហើយថា អ្វីដែលអាចចាត់ទុកថាសមហេតុផលនោះគឺអាស្រ័យលើកាលៈទេសៈពិសេស «ស្ថានភាពនៅមុននិងក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ»។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអះអាងថា« ការសង្ស័យ» ដែលថាជនណាម្នាក់អាចពាក់ព័ន្ធក្នុងអំពើក្បត់ជាតិ គឺពុំទាន់គ្រប់គ្រាន់ជាមូលដ្ឋានគតិយុត្តិដើម្បីផ្តល់យុត្តិកម្មដល់ការឃុំឃាំងបុគ្គលនានា ដោយគ្មានដំណើរការត្រឹមត្រូវ ដោយគ្មានបទចោទប្រកាន់ដោយគ្មានការពិនិត្យភ័ស្តុតាងតាមផ្លូវតុលាការ ដោយគ្មានមេធាវីការពារក្តី និងដោយគ្មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌» នោះឡើយ។ ភាគីដទៃទៀតមិនបានធ្វើសារណាពាក់ព័ន្ធនឹងចំណុចនេះទេ។ អង្គជំនុំជម្រះសន្និដ្ឋានថា ទោះបីជាកម្មាភិបាលដែលធ្វើការចាប់ខ្លួនមានការសង្ស័យ សមហេតុផលពីកាលៈទេសៈដែលតម្រូវឲ្យចាប់ខ្លួនក៏ដោយ ប៉ុន្តែកម្មាភិបាលរូបនោះមិនអាចឲ្យរួចផុតពីការទទួលខុសត្រូវបានដែរ ប្រសិនបើបុគ្គលនោះត្រូវបានឃុំខ្លួនដោយពុំបានធ្វើតាមដំណើរការច្បាប់។

## ៩.១.៦. ការធ្វើទារុណកម្ម

**៦៩៩.** ទាក់ទិនសំណុំរឿង០០២/០២ ដីកាដំណោះស្រាយបោទប្រកាន់ជនជាប់ចោទពីខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើទារុណកម្ម នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល និងតាមរយៈការប្រព្រឹត្តចំពោះជនជាតិចាម។

**៧០០.** អង្គជំនុំជម្រះបានសម្រេចពីមុនរួចមកហើយថា ការធ្វើទារុណកម្មត្រូវបានទទួលស្គាល់ជាខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥។ គ្មានទឡ្ហីករណ៍ថ្មីណាមួយត្រូវបានភាគីលើកឡើងនៅក្នុងរឿងក្តីនេះដែលតម្រូវឲ្យអង្គជំនុំជម្រះពិចារណាលើបញ្ហានេះបន្ថែមនោះឡើយ។ ពាក់ព័ន្ធនឹងភាពអាចប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងថាការធ្វើទារុណកម្ម គឺជាខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះបានពិចារណាទៅលើក្របខណ្ឌច្បាប់ទំនៀមទម្លាប់ ភាពធ្ងន់ធ្ងរនៃខក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទ ក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា។ លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅ «ការទទួលស្គាល់យ៉ាងទូលំទូលាយដោយបណ្តាសហគមន៍ប្រជាជាតិនានាអំពីភាពធ្ងន់ធ្ងរនៃអំពើទារុណកម្ម» នៅក្នុងការសន្និដ្ឋានថា ការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌចំពោះអំពើទារុណកម្មអាចប្រមើលឃើញត្រឹមឆ្នាំ១៩៧៥។

បន្ទាប់ពីបានថ្លឹងថ្លែងទៅលើកត្តាទាំងនេះ ដោយសត្យានុម័តអង្គជំនុំជម្រះសន្និដ្ឋានថាជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថាការធ្វើទារុណកម្មត្រូវបានផ្ដន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥។

**៧០១.** និយមន័យនៃទារុណកម្មដែលមានចែងនៅក្នុងសេចក្ដីប្រកាស ឆ្នាំ១៩៧៥ ស្ដីពីទារុណកម្មគឺជាការប្រកាសបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ តាមនិយមន័យនេះ ធាតុផ្សំនៃទារុណកម្មរួមមាន៖

(១) អំពើណាមួយដែលបណ្ដាលឲ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរផ្នែករាងកាយ ឬស្មារតី (ធាតុផ្សំសត្យានុម័ត)

(២) ដែលប្រព្រឹត្តឡើងដោយចេតនាទៅលើបុគ្គលណាមួយ (ធាតុផ្សំអត្តនោម័តិ)

(៣) ដោយមន្ត្រីសាធារណៈ ឬដោយការញុះញង់មន្ត្រីសាធារណៈ

(៤) ក្នុងគោលបំណងដើម្បីទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ។

**៧០២.** សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការហាមឃាត់ប្រឆាំងនឹងទារុណកម្មគឺជា វិធានអាអាជ្ញាបញ្ញ (Jus cogeus) ហេតុដូច្នេះ ការធ្វើបដិប្បញ្ញត្តិមិនត្រូវបានអនុញ្ញាត ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយរួមទាំងក្នុងកាលៈទេសៈប្រទេសមានអាសន្នឬមានបញ្ហាសន្តិសុខជាតិផងដែរ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។ អង្គជំនុំជម្រះបានតម្កល់ការយល់ឃើញកាលពីមុនរបស់ខ្លួនដែលថា ការហាមឃាត់ចំពោះការធ្វើទារុណកម្ម ទទួលបាននូវឋានៈជា វិធានអាជ្ញាបញ្ញ ឬជាគោលការណ៍ ដែលបដិប្បញ្ញត្តិមិនត្រូវបានអនុញ្ញាតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ តុលាការយុត្តិធម៌អន្តរជាតិក៏បានទទួលស្គាល់ផងដែរថាការហាមឃាត់ចំពោះទារុណកម្មគឺជាវិធានអាជ្ញាបញ្ញ (Jus cogeus) ដែលបាន « ផ្អែកលើមូលដ្ឋាននៃការអនុវត្តជាលក្ខណៈអន្តរជាតិយ៉ាងទូលំទូលាយ និង ការបង្ហាញពីឆន្ទៈទទួលយកជាច្បាប់របស់រដ្ឋ(Opinio juris)»។ នៅក្នុងការឈានដល់ការសន្និដ្ឋាននោះ តុលាការយុត្តិធម៌អន្តរជាតិបានសំអាងលើលិខិតុបករណ៍អន្តរជាតិដូចជា សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស អនុសញ្ញាទីក្រុងហ្សឺណែវ និងកតិកាសញ្ញាអន្តរជាតិ ប្រកាសជា តិស្ដីពីសិទ្ធិពល



រណ្ដៅសាកសពរបស់ជនរងគ្រោះពីរបបខ្មែរក្រហមនៅវត្តចំពុះក្អែក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រដ្ឋនិងសិទ្ធិនយោបាយដែលត្រូវបានរៀបចំចប់សព្វគ្រប់នៅមុនឆ្នាំ១៩៧៥។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា នៅត្រឹមឆ្នាំ១៩៧៥ ការហាមឃាត់ចំពោះទារុណកម្មគឺជាវិធានការបញ្ញ (jus cogens) ដែលមិនអាចធ្វើបដិប្បញ្ញត្តិបានឡើយ ទោះបីជាមានហេតុផលណាមួយក៏ដោយ។

**៧០៣.** *នៅពេលវាយតម្លៃទៅលើការរងទុក្ខ ឬការឈឺចាប់ អង្គជំនុំជម្រះនេះ និងតុលាការមិនអចិន្ត្រៃយ៍ផ្សេងទៀតបានពិចារណាលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត ដូចជាភាពធ្ងន់ធ្ងរនៃព្យសនកម្មដែលបានបង្កឡើង និងលក្ខណៈនៃព្យសនកម្ម គោលបំណង និងភាពស៊ីចង្វាក់នៃអំពើដែលត្រូវបានប្រព្រឹត្ត ព្រមទាំងលក្ខណៈវិនិច្ឆ័យអត្តនោម័ត រួមមាន លក្ខខណ្ឌរូបរាងឬរាងកាយឬផ្លូវចិត្តរបស់ជនរងគ្រោះ ផលប៉ះពាល់នៃការប្រព្រឹត្ត និងនៅក្នុងករណីខ្លះ កត្តានានាដូចជាអាយុរបស់ជនរងគ្រោះភេទ ស្ថានភាពសុខភាព និងតួនាទីក្នុងនាមជាថ្នាក់ក្រោម។*

**៧០៤.** *អង្គជំនុំជម្រះកត់សម្គាល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិមិនបានកំណត់លក្ខខណ្ឌជាក់លាក់អំពីការរងទុក្ខឬការឈឺចាប់ដែលត្រូវសម្រាប់បង្ហាញអំពីឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មឡើយ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកំណត់សម្គាល់ថា «អំពើមួយចំនួនមានលក្ខណៈជាក់ស្តែងមែនទែនដែលធ្វើឲ្យ [អំពើទាំងនោះ] មានលក្ខណៈជាការធ្វើទារុណកម្ម»។ ដោយសំអាងលើការងាររបស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ចំពោះការធ្វើទារុណកម្ម សាលក្រមនៃរឿងក្តី Delalic និងជនជាប់ចោទផ្សេងទៀតបានផ្តល់នូវ « បញ្ជីរាយឈ្មោះលម្អិតទោះជាមិនបានពេញលេញក្តី អំពើទាំងឡាយដែលពាក់ព័ន្ធនឹងការបង្កឲ្យមានការរងទុក្ខធ្ងន់ធ្ងរដែលមានលក្ខណៈគ្រប់គ្រាន់បង្កើតបានជាបទទារុណកម្ម» រួមមាន៖*

*ការវាយដំ ការដកក្រចក ការដកធ្មេញ ។ល។ ការយកភ្លើងដុត ការឆក់ខ្សែភ្លើង ការចងព្យួរ ការធ្វើឲ្យថប់ដង្ហើម ការដាក់ឲ្យត្រូវពន្លឺ ឬសំឡេងខ្លាំងហួសហេតុ ការបំពារបំពានផ្លូវភេទ ការឲ្យប្រើប្រាស់ឱសថនៅក្នុងមន្ទីរឃុំឃាំងឬមន្ទីរពេទ្យវិកលចរិត ការបដិសេធមិនឲ្យសម្រាក ឬដេករយៈពេលយូរ មិនឲ្យចំណីអាហាររយៈពេលយូរ គ្មានអនាម័យគ្រប់គ្រាន់រយៈពេលយូរ មិនឲ្យមានជំនួយផ្នែកពេទ្យរយៈពេលយូរ ការដាក់ឲ្យនៅឆ្ងាយពីគេ និងការដកហូតសេរីភាពខាងផ្លូវអារម្មណ៍ទាំងស្រុង ការរក្សាទុកក្នុងភាពមិនច្បាស់លាស់ចំពោះទីកន្លែង និងពេលវេលា ការគំរាមធ្វើទារុណកម្ម ឬសម្លាប់សាច់ញាតិ ការបោះបង់ចោល និងការធ្វើត្រាប់ពីការសម្លាប់។*

**៧០៥.** *អំពើនានាដែលមិនឈានដល់កម្រិតធ្ងន់ធ្ងរនៃការប្រព្រឹត្តបទភេទនេះទេ អាចជាបទល្មើសផ្សេងទៀត។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត និង ការបំពារបំពានយ៉ាងធ្ងន់ធ្ងរតាមរយៈការធ្វើបានដោយមនុស្សធម៌ ព្រមទាំងការប្រព្រឹត្តដ៏ឃោរឃៅដែលអំពើទាំងអស់នេះមានធាតុផ្សំគតិយុត្តដូចគ្នា តម្រូវឲ្យការប្រព្រឹត្តនោះបង្កឲ្យមានការរងទុក្ខផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ដែលមិនមែនជាការរងទុក្ខផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ដែលថាលក្ខខណ្ឌតម្រូវនៃការធ្វើទារុណកម្មនោះឡើយ។ អំពើនានាដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងថា មានភាពធ្ងន់ធ្ងរមិនគ្រប់គ្រាន់នៅក្នុងកាលៈទេសៈជាក់លាក់ណាមួយ ដើម្បីចាត់ទុកថាជាការធ្វើទារុណកម្មនោះ រួមមានការសួរចម្លើយ ការប្រមាថតិចតួចលើបូរណភាពរាងកាយរបស់ជនរងគ្រោះ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការបង្អត់អាហារ។*

**៧០៦.** *សហព្រះរាជអាជ្ញាសន្និដ្ឋានថា គោលបំណងទាំងឡាយដែលមានចែងនៅក្នុងសេចក្តីប្រកាសឆ្នាំ១៩៧៥ ស្តីពីទារុណកម្ម គឺជាគោលបំណងតំណាងមិនមែនជាគោលបំណងទាំងអស់នោះទេ។ ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នត្ថិភាពនៃការចែងឲ្យបានច្បាស់លាស់នៅក្នុងសេចក្តីប្រកាសនោះ មិនបានដកចេញនូវការរកឃើញអំពើទារុណកម្មដោយផ្អែកលើការរើសអើងឡើយ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។*

*អង្គជំនុំជម្រះយល់ឃើញថាឃ្លា «សម្រាប់គោលបំណងបែបនេះ» នៅក្នុងមាត្រា១ នៃសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីទារុណកម្ម បញ្ជាក់យ៉ាងច្បាស់គោលបំណងបែបនេះ» នៅក្នុងមាត្រា១ នៃសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីទារុណកម្ម បញ្ជាក់យ៉ាងច្បាស់លាស់ថា ចំណុចផ្សេងៗដែលបានរៀបរាប់នោះគ្រាន់តែជាតំណាង មិនមែនជាការរៀបរាប់គ្រប់ចំណុចទាំងអស់នោះទេ។ ទោះបីជាយ៉ាងណា ករណីនេះមិនបានបង្ហាញថា ការរើសអើងត្រូវបានទទួលស្គាល់ថាជាគោលបំណងនៃទារុណកម្មដែលត្រូវបានហាមឃាត់ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅត្រឹមឆ្នាំ១៩៧៩ នោះទេ។ ទើបតែមកដល់ពេលមានអនុសញ្ញាប្រឆាំងនឹងទារុណកម្មឆ្នាំ១៩៨៤ នោះទេទើប «ការរើសអើងនោះក្នុងប្រភេទណាក៏ដោយ» ត្រូវបានចែងកំណត់ថា ជាគោលបំណងណាមួយ ក្នុងគោលបំណងនៃទារុណកម្មដែលត្រូវបានហាមឃាត់។*

៧០៧. *អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់យ៉ាងច្បាស់ថា សេចក្តីប្រកាសឆ្នាំ១៩៧៥ ស្តីពីទារុណកម្មដែលជាការឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិមានលក្ខណៈរឹតត្បិតជាង ហើយមិនបានបញ្ចូល «ការរើសអើង ទោះក្នុងប្រភេទណាក៏ដោយ» នៅក្នុងបញ្ជីរៀបរាប់ពីគោលបំណងដែលបានហាមឃាត់នោះ។ សហព្រះរាជអាជ្ញាមិនបានបង្ហាញពីយុត្តសាស្ត្រ បទប្បញ្ញត្តិគតិយុត្តិការអនុវត្តរបស់រដ្ឋ និង/ឬការបង្ហាញពីឆន្ទៈទទួលយកជាច្បាប់របស់រដ្ឋ (opinion juris) ដែលថានៅមុនឆ្នាំ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានប្រមើលទុកថា ការរើសអើងអាចជាគោលបំណងមួយនៃគោលបំណងផ្សេងទៀតនៃទារុណកម្មដែលត្រូវហាមឃាត់នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសេចក្តីសន្និដ្ឋាននេះរបស់សហព្រះរាជអាជ្ញា។*

៧០៨. *អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីប្រកាសឆ្នាំ១៩៧៥ ស្តីពីទារុណកម្មមិនបានបញ្ចូលឲ្យបានច្បាស់នូវ« អំពើអកម្ម» ដែលបណ្តាលឲ្យមានទុក្ខសោក ការឈឺចាប់ធ្ងន់ធ្ងរនោះទេ។ អង្គជំនុំជម្រះបានទទួលស្គាល់កាលពីមុនរួចហើយ ចំពោះគោលការណ៍ទូទៅដែលត្រូវបានអនុវត្តយ៉ាងស៊ីចង្វាក់គ្នាដោយតុលាការមិនអចិន្ត្រៃយ៍ផ្សេងៗថា «បទឧក្រិដ្ឋមួយអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលអាចនាំឲ្យមានពិរុទ្ធភាព ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ»។ ទោះបីជាសេចក្តីសង្កេតនេះត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា គោលការណ៍ទូទៅដែលថា ចាំបាច់ត្រូវមានកាតព្វកិច្ចក្នុងការចាត់វិធានការអនុវត្តចំពោះអំពើអកម្មចំពោះអកម្មទាំងអស់ដែលអាចនាំឲ្យមានពិរុទ្ធ-ភាព រួមទាំងគោលបំណងនៃការធ្វើទារុណកម្មផងដែរ។ ផ្អែកលើគោលការណ៍នេះ អង្គជំនុំជម្រះយល់ឃើញថា ដរាបណាមានកាតព្វកិច្ចក្នុងការចាត់វិធានការ អំពើអកម្មដែលបានធ្វើឡើងដោយចេតនា និងបណ្តាលឲ្យមានការឈឺចាប់ធ្ងន់ធ្ងរ ត្រូវបានចាត់ទុកថាជាទារុណកម្ម ដោយសារធាតុផ្សំផ្សេងទៀតនៃបទល្មើសនេះត្រូវបានបំពេញ។*

៧០៩. *ដោយសារវាជាបញ្ហាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងលក្ខខណ្ឌដែលថា ទារុណកម្មត្រូវតែប្រព្រឹត្តឡើងដោយ ឬក្រោមការញុះញង់ពីមន្ត្រីសាធារណៈ ហើយសហព្រះរាជអាជ្ញាបានលើកឡើងថា តុលាការ* ICTY *និង* ICTR *ក៏បានច្រានចោលលក្ខខណ្ឌនេះយ៉ាងត្រឹមត្រូវផងដែរ។ ជាមួយគ្នានោះដែរ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បញ្ហានេះមិនពាក់ព័ន្ធនឹងការជំនុំជម្រះនេះទេ «ដោយសារអំពើទារុណកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលឬកងទ័ពថ្នាក់ក្រោមនៃរបបនោះ»។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនិងបញ្ហានេះនោះទេ។ មានបញ្ជាក់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មានលក្ខខណ្ឌតម្រូវថា ទារុណកម្មត្រូវបានប្រព្រឹត្តឡើងឬក្រោមការញុះញង់ពីមន្ត្រីសាធារណៈដើម្បីអាចចាត់ទុកថា ជាបទឧក្រិដ្ឋមួយបាន។ សហព្រះរាជអាជ្ញាយុត្តិសាស្ត្រនៅមុនឆ្នាំ១៩៧៥ បទប្បញ្ញត្តិគតិយុត្តិ ការអនុវត្តរបស់រដ្ឋ និង/ឬការបង្ហាញពីឆន្ទៈទទួលយកជាច្បាប់របស់រដ្ឋ (opinion juris) ដែលអាចបង្ហាញឲ្យឃើញពីកំហុសរបស់អង្គជំនុំជម្រះតុលាការ*

កំពូល នៅក្នុងការវិភាគលើច្បាប់ទំនៀមទម្លាប់អន្តរ-ជាតិនោះទេ។ ហេតុដូច្នេះអង្គជំនុំជម្រះប្រានបោល សេចក្តីសន្និដ្ឋានលើអង្គច្បាប់របស់សហព្រះរាជអាជ្ញា ត្រង់ចំណុចនេះ។

### ៩.១.៧. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា

**៧១០.** ទាក់ទិនសំណុំរឿង០០២/០២ ដីកាដំណោះស្រាយបោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ ដោយសំអាងលើមូលហេតុដូចខាងក្រោម៖

(ក) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ (ដោយកម្រិតត្រឹមការប្រព្រឹត្តចំពោះជនជាតិចាម) នៅសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់១មករា និងការដ្ឋានសាងសង់ប្រលានយន្តហោះ យោធាកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

(ខ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា នៅក្នុងអំឡុងពេលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ (ដោយកម្រិតត្រឹមការប្រព្រឹត្តចំពោះជនជាតិចាម) នៅសហករណ៍ត្រាំកក់( ដោយកម្រិតត្រឹមការប្រព្រឹត្តចំពោះពុទ្ធសាសនិក) ការដ្ឋានការងារទំនប់១មករា (ដោយកម្រិតត្រឹមការប្រព្រឹត្តទៅលើជនជាតិចាម) និងពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើជនជាតិចាម។ និង

(គ) ការធ្វើទុក្ខមុកម្នេញដោយមូលហេតុពូជសាសន៍ទៅលើជនជាតិវៀតណាម នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង។

**តនៅលេខក្រោយ**

អតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហមនៅវត្តចំពុះក្អែក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# អនុប្រធានអង្គការសហប្រជាជាតិ ពិភាក្សា

## អំពីសន្តិភាព សិទ្ធិមនុស្ស និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងនៅក្នុងប្រទេសដទៃទៀតជាមួយនឹងលោក ឆាំង យុ

*សុភ័ក្រ្ត ភាណា*



លោក ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក (នៅកណ្តាល) លោកស្រី ផលលីន ថេមីស៊ីស តំណាងអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា (ខាងឆ្វេង) និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (ខាងស្តាំ) នៅឯបណ្ណាល័យសម្តេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។ (សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាពនិងកិច្ចការនយោបាយប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក, លោក ខូឌី ហ្វ្រេីហ្គេីរ មន្ត្រីផ្នែកនយោបាយ, និងលោកស្រី ផលលីន ថេមីស៊ីស តំណាងអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា និងប្រតិភូកិត្តិយសបានពិភាក្សាអំពីសន្តិភាពសិទ្ធិមនុស្សនិងការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងនៅក្នុងប្រទេសដទៃទៀតជាមួយនឹងលោក ឆាំង យុ នៅឯបណ្ណាល័យសម្តេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកនៃវិទ្យាស្ថានស្លឹករឹត បានទទួលស្វាគមន៍ប្រតិភូកិត្តិយសយ៉ាងកក់ក្តៅ។

*ភ្ញៀវកិត្តិយសបានចារចំណារអនុស្សាវរីយ៍ ដែលមានខ្លឹមសារដូចខាងក្រោម៖*

“...**សូមអរគុណដែលថែរក្សាការចងចាំឱ្យនៅរស់រវើក។...**” - *ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ា ្វិក*

“ ***ការចងក្រងឯកសារគឺជាសកម្មភាពនយោបាយ។” ខ្ញុំបានរៀនសូត្រអំពីចំណុចនេះ និងមេរៀនជាច្រើនទៀតពីដំណើរទស្សនកិច្ចខ្លីមួយក្នុងថ្ងៃនេះ មកកាន់បណ្ណាល័យសម្តេចម៉ែ។ នេះពិតជាកិត្តិយសនិងសេចក្តីសោមនស្សរីករាយជាពន្លឹក ដែលទទួលបានការយល់ដឹងអំពីសារសំខាន់នៃប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា ដែលបានអភិរក្សក្នុងបណ្ណសារជាទម្រង់លាយលក្ខណ៍អក្សរ ការរៀបរាប់ដោយផ្ទាល់មាត់ និងរូបភាព និងព្រមទាំងត្រូវបានប្រមែប្រមូលចងក្រងដោយស្និតស្នាញនិងប្រសើរ។ យ៉ាងណាក្តី ប្រវត្តិសាស្ត្រមិនស្ថិតតែនៅក្នុងអតីតកាលនោះទេ។ ប្រវត្តិសាស្ត្រកំណត់នូវអនាគត។ ហើយពិតជាចាំបាច់ណាស់ ដែលយើងត្រូវសិក្សាអំពីប្រវត្តិសាស្ត្រ ដើម្បីលូតលាស់ក្នុងបច្ចុប្បន្នកាល។ ដោយសេចក្តីដឹងគុណ។”***

*ផលលីន ថេមីស៊ីស តំណាងអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា*

*មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតបណ្ណាល័យសម្តេចម៉ែឡើង ដោយមានការគាំទ្រពីស្ថានទូតសហរដ្ឋអាមេរិក និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ក្នុងគោលបំណងថ្វាយព្រះកិត្តិយសជូន សម្តេចព្រះមហាក្សត្រីយ៍ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនិនាថ សីហនុ ដែលបានលះបង់ពេញមួយព្រះជីវិតរបស់ទ្រង់ចំពោះប្រទេសកម្ពុជា, ចំពោះសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ, និងចំពោះប្រជាជនកម្ពុជា។*



*ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក (ខាងឆ្វេង) និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (ខាងស្តាំ) នៅឯបណ្ណាល័យសម្តេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លោក ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក (ខាងស្តាំ) និង លោកស្រី ផលលីន ថេមីស៊ីស តំណាងអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា ( ខាងឆ្វេង) នៅឯបណ្ណាល័យសម្តេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។ ( សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*





លោក ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយ ប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក (នៅកណ្ដាល) លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា (ខាងស្ដាំ) និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (ខាងឆ្វេង) នៅឯបណ្ណាល័យសម្ដេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយ ប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក (ខាងឆ្វេង) និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (ខាងស្ដាំ) នៅឯបណ្ណាល័យសម្ដេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ខាឡេត ឃីអារី អនុប្រធានអង្គការសហប្រជាជាតិ ទទួលបន្ទុកនាយកដ្ឋានកសាងសន្តិភាព និងកិច្ចការនយោបាយ ប្រចាំនៅតំបន់មជ្ឈិមបូព៌ា, អាស៊ី និងប៉ាស៊ីហ្វិក(ខាងស្ដាំ) និង លោកស្រី ផលលីន ថេមីស៊ីស តំណាងអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា (ខាងឆ្វេង) នៅឯបណ្ណាល័យសម្ដេចម៉ែ នាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។ (សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិឃាដ»

## ១. មីគ្នោត មេគោរអង្គការ (ត)

### សភាវគតិមីគ្នោតនាំឲ្យខ្ញុំឃើញវណ្ណៈមរណៈគ្រួសារ (ត)

កាលនោះកម្ពស់ខ្ញុំនិងកម្ពស់មីគ្នោតគឺប្រហែលគ្នា ខ្ញុំយកដៃទៅអង្អែលកន្លែងស្នាមដែលខ្ញុំវាយ ហើយចង់និយាយប្រាប់វាថាឲ្យខ្ញុំសុំទោសផង កុំខឹងនឹងខ្ញុំអី ខ្ញុំក៏មានការសោកស្ដាយដែរ រួចក៏ដឹកវាទៅផ្ទះ។

នៅតាមផ្លូវ គ្រប់រូបភាពដែលខ្ញុំបានឃើញមុននេះនៅតែមកតាមលងក្នុងអារម្មណ៍ខ្ញុំរហូត។ ខ្ញុំមានចិត្តតក់ស្លុតយ៉ាងខ្លាំងនៅពេលបានឃើញវណ្ណៈពួកខោអាវខ្មៅដឹកនោះ។ ដឹកគោបណ្ដើរគិតបណ្ដើរ តែមីគ្នោតវាតែងតែយកអណ្ដាតមកលិឍលើក្បាលរបស់ខ្ញុំ ហាក់ដូចជាចង់ប្រាប់នូវរឿងអ្វីមួយ។

ខ្ញុំជាមនុស្សវាជាសត្វមែនតែប្រៀបដូចជាមិត្តភក្ដិនឹងគ្នា ព្រោះមេកងនារីកុមារឲ្យខ្ញុំមើលថែរក្សាវា។មិនថាថ្ងៃឬយប់ ខ្ញុំតែងតែដឹកវាឲ្យស៊ីស្មៅឲ្យឆ្អែត បើមើលគោមិនឲ្យស៊ីស្មៅឆ្អែតឬមើលថែមិនដិតដល់នោះ មេកងកុមារនឹងដាក់ពិន័យលើខ្ញុំជាមិនខានដែលអង្គការគេគិតថា "សូវឲ្យប្រជាជនដាច់បាយ តែមិនឲ្យគោដាច់ស្មៅឡើយ" និងតែងតែលាងទឹក ហើយពេលយប់បំពក់ភ្លើងដេញមូស ប្រហែលវាគិតថាខ្ញុំជាមិត្តល្អ ហើយមិនចង់ឲ្យខ្ញុំបែកពីវាព្រោះមានអនុស្សាវរីយ៍ និងមនោសញ្ចេតនាល្អៗនឹងគ្នាច្រើន។

យប់នោះខ្ញុំដេកមិនលក់ទេ ចេះតែរសាប់រសល់ស្រមៃឃើញសំណល់រូបភាពវណ្ណៈសម្លាប់មនុស្សនៅនឹងភ្នែក។ ខ្ញុំប្រែខ្លួនចុះឡើងៗ ហើយខំបើកភ្នែកសម្លឹងមើល លោកពុក អ្នកម្ដាយ បងស្រី និងប្អូនៗ ទាំងស្រងូតស្រងាត់ក្នុងចិត្ត ព្រោះគិតថា តើវាសនាគ្រួសារខ្ញុំអាចឆ្លងផុតគ្រោះព្យុះកម្មវេរាដ៏កាចសាហាវមួយនេះបានដែរឬទេ?




រូបភាពបច្ចុប្បន្នឆ្នាំ ២០១៩៖ កន្លែងដែលខ្ញុំបានឃើញកងឈ្លបខ្មែរក្រហមដឹកវណ្ណៈពេលខ្ញុំមករកមីគ្នោត នៅក្នុងទួលស្វាំង។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

# ២. ជីវិតក្នុងជំរំក្អែកខ្មៅបដិវត្តន៍

## បង្គងបែកបាក់ក្នុងឋានបដិវត្តន៍

### ជ្រោះទឹកភ្នែកខ្លោចផ្សា

ពិតប្រាកដណាស់ស្អែកឡើងម្តាយឪពុកខ្ញុំបាននិយាយមកកាន់ខ្ញុំ និងបងស្រី ថា តោះកូន! យើងរៀបចំអីវ៉ាន់ទៅរស់នៅទួលស្លាំង (ទួលស្លាប់) ព្រោះមេកងកម្មាភិបាលសហចាត់តាំងឲ្យគ្រួសារយើងទៅរស់នៅលើទួលនោះ។

គ្រាន់តែឮពាក្យនេះភ្លាម ខ្ញុំស្ទើរតែអស់ព្រលឹងព្រលះពីក្នុងខ្លួន ក្នុងចិត្តស្រែករកតែពុទ្ធោៗជាប់រហូត។

ការបារម្ភ ការព្រួយ ការគិតកន្លងមកឥឡូវមកដល់ហើយ កម្មកំណាចអ្វីបានជាធ្លាក់មកលើគ្រួសារខ្ញុំ។ ទឹកភ្នែកខ្ញុំចាប់ផ្តើមហូរឥតឈប់ ហើយបានលុតជង្គង់និយាយទៅកាន់លោកឪពុកម្តាយទាំងយំថា ពុក ម៉ែ គេមិនមែនឲ្យយើងទៅរស់នៅទួលស្លាំងទេ គឺ គេប្រាកដជាសម្លាប់គ្រួសារយើងនៅ ទីនោះហើយ ព្រោះកូនបានឃើញគេជីករណ្តៅទុកជាស្រេចនៅពេលកូនទៅចាំគោ ហើយថែមទាំងឮវាសួរគ្នាវាទៀតថា តើរណ្តៅនេះដាក់បានគោប៉ុន្មានក្បាលទៀតផង។

ឮដូច្នេះ ឪពុកខ្ញុំមានទឹកភ្នែករលីងរលោង តែគាត់ខំជូតចេញ ហើយអង្អែលក្បាលខ្ញុំទាំងប្រឹងញញឹមពេបដោយពោលថា "មិនអីទេកូន សម័យនេះមនុស្សមិនសម្លាប់មនុស្សទេ។" ខ្ញុំដឹងថាគាត់និយាយនេះជាការលួងចិត្តខ្ញុំប៉ុណ្ណោះ។

ពុកម៉ែខ្ញុំគាត់បានសម្រេចចិត្តរួចហើយថា យើងមិនអាចគេចវេះពីភ្នែកអង្គការបានឡើយ គាត់នឹងយកខ្ញុំនិងប្អូនប្រុសពៅ ភ្លោះវិសុទ្ធ និងវិសាលទៅជាមួយ ហើយលាក់ទុកបងស្រីជានិងប្អូនប្រុសវ៉ាបន្ទាប់ខ្ញុំឲ្យនៅជាមួយជីដូនជីតា។

ខ្ញុំស្រែកទ្រហោយំ ខំប្រកែកនឹងឪពុកម្តាយ ដោយទាញដៃគាត់ ហើយស្រែកប្រាប់គាត់ថា "ពុកកុំទៅអីៗៗៗ គេនឹងសម្លាប់យើងហើយៗ។" នៅមុខជីដូនជីតាខ្ញុំផង ខ្ញុំសម្លឹងទៅមើលមុខអ្នកមានគុណទាំងពីរ ទាំងស្រវាំងភ្នែកដែលគាត់កំពុងហូរទឹកភ្នែកចេញមកមិនដឹងខ្លួន។

ដោយមានចិត្តអាណិតដល់កូន គាត់បាននិយាយជាមួយម្តាយ និងបងស្រី ថា "អាណិតកូនវង្សមិនបាច់យកវាទៅជាមួយទេ ព្រោះកូនបានឃើញគេជីករណ្តៅសម្រាប់នៅចំពោះមុខពិតជាមានការតក់ស្លុតរន្ធត់ក្នុងចិត្តខ្លាំងណាស់។ ដូច្នេះយើងលាក់ទុកវាឲ្យនៅជាមួយគ្នាទាំងបីនាក់ចុះ"។

ម្តាយក៏ងក់ក្បាលជាមួយទឹកភ្នែកនិងអារម្មណ៍ខ្សឹកខ្សួលសម្លឹងមកមើលខ្ញុំ ហើយពោលមកកាន់ខ្ញុំថា "មិនអីទេ។ ពុកម៉ែមិនទៅរស់នៅលើទួលនោះទេ។" រួចគាត់ក៏ដឹកដៃខ្ញុំទៅដេកនៅក្នុងអង្រឹងកំប្លោក តែខ្ញុំនៅតែយំអណ្តឹត-អណ្តកក្នុងចិត្ត។ គាត់ចេះតែលួចមើលមកខ្ញុំដោយស្មានតែខ្ញុំដេកលក់ តែការពិតមិនដូច្នេះទេ ខ្ញុំនៅតែលួចមើលសកម្មភាពរបស់គាត់បន្តទៅទៀត។

គាត់ទាំងពីរបានងាកមកនិយាយជាមួយជីដូនជីតាខ្ញុំម្តង ដោយអង្គុយបត់ជើងសំពះ។ ពេលនោះ ម្តាយខ្ញុំបានពោលទៅកាន់ជីដូនជីតាខ្ញុំថា "ពុកម៉ែ កូនសុំលាពុកម៉ែទៅរស់នៅលើទួលស្លាំងហើយ សូមពុកម៉ែជួយមើលថែកូនៗរបស់ខ្ញុំផង បើខ្ញុំត្រូវគេសម្លាប់ ហើយបើឃើញមេកង ឬកងឈ្លបមកសួររកកូនៗខ្ញុំ សូមពុកម៉ែឲ្យពួកគេគេចពួននៅកន្លែងណាមួយ ហើយប្រាប់ពួកកងឈ្លបទាំងនោះថា កូនៗនិងចៅៗខ្ញុំត្រូវអង្គការបដិវត្តន៍ឲ្យទៅរស់នៅលើទួលស្លាំងអស់ហើយ។"

ពួកកម្មាភិបាលបដិវត្តន៍បានដឹងច្បាស់អំពីអតីតភាពលោកពុក។ លោកពុកខ្ញុំគាត់ជាគ្រូបង្រៀន ហើយក៏ជាសមាជិកឆ្លើយឆ្លងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ ពួកវាកម្ចាត់ចោលឲ្យអស់នូវអ្នកចេះដឹង ព្រោះគិតថាជាពួកសក្តិភូមិប្រតិកិរិយាសុទ្ធតែជាខ្លាំង។

ព្រោះអើយ គ្រាន់តែជាអ្នកបង្ហាត់បង្រៀនកូនខ្មែរឲ្យបានចេះដឹងក៏ក្លាយជាខ្មាំងដែរ។ លោកពុកមិនអាចលាក់ប្រវត្តិរូបបានទេព្រោះទៅរស់នៅក្នុងភូមិស្រុកកំណើតដែលមានអ្នកធ្លាប់ស្គាល់ច្រើន បើបានលាក់លៀមនឹងត្រូវវេទនាវុណកម្មខ្លាំងជាងនេះទៀត ព្រោះមិនស្មោះត្រង់នឹងអង្គការបដិ-វត្តន៍។ ប្រាប់ត្រង់ក៏ស្លាប់ កុហកក៏ស្លាប់ តើធ្វើម៉េចទៅទើបល្អ?

សភាពការណ៍ក្នុងសម័យនោះមិនខុសពីពាក្យស្លោកបុរាណបានចារមកថា ចុះទឹកក្រពើ ឡើងលើខ្លា ចូលព្រៃបន្លា។ គេចទៅណាក៏មិនរួច ដូច្នេះហើយមានតែរង់ចាំការស្លាប់តែមួយមុខប៉ុណ្ណោះ។ មនុស្សសាហាវថ្មើមខ្មៅយង់ឃ្នង ពិតជាមិនប្រណីដល់គ្រួសារខ្ញុំឡើយ។

# បន្តងបែកបាក់ក្នុងឋានបដិវត្តន៍

### លិខិតបណ្ដាំទឹកភ្នែកម្ដាយចុងក្រោយចារដោយកូនស្រី

ពេលនោះខ្ញុំសង្កេតឃើញអ្នកទាំងប្អូននិងបងស្រីខ្ញុំទ្រហោយំដោយក្ដីសង្វេគឥតឧបមា ស្ទើរតែដួលទៅទាំងដំហរ។

គាត់បានអង្គុយក្រាបសំពះទទួលនូវធម៌ជយន្តោ ខ្សឹបៗបីចប់ និងទឹកមន្តប្រោសព្រំរំដោះគ្រោះ ពីជីដូនជីតារបស់ខ្ញុំដោយភ្នែកក្រ ឡាប់ចុះក្រ ឡាប់ឡើង មើលទៅក្រោមផ្ទះខ្លាចក្រែងកងឈ្លបមកឃើញ គឺគេប្រាកដជាចោទថា គ្រួសារមិនស្អាតស្អំ មិនស្មោះត្រង់នឹងបដិវត្តន៍ នៅប្រើកម្មែលវប្បធម៌សាសនាចាស់គំរិលដែលគេហាមឃាត់ ហើយគេអាចចោទប្រកាន់យើងភ្លាមៗ និងអាចសម្លាប់ចោលមួយពូជនៅនឹងកន្លែងដែលមានភស្តុតាងស្រាប់។



ទិដ្ឋភាព៖ តាយាយឲ្យធម៌ជយន្តោទៅកាន់ឪពុកម្ដាយខ្ញុំ និងប្អូនភ្លោះមុនពេលគាត់លាចាកចេញ។ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

រំពេចនោះស្រាប់តែឃើញបងស៊ឹមដែលជាកូនប្រសាធំហុង បងស្រីឪពុកខ្ញុំរស់នៅភូមិយោគ ស្ពៀកខោខ្លីចង្កេះក្រវាត់ក្រមាមានពាក់ឆៀងខ្សែគោ ស្អឹងនិងកឡោបីបាចទឹក ក្នុងទឹកមុខភ័យខ្លាចមកជួបម្ដាយខ្ញុំ។ ឃើញដូច្នោះម្ដាយក៏ស្ទុះទៅយកកញ្ចប់មួយហុចទៅឲ្យគាត់ ហើយនិយាយថា "នេះនែ៎! ក្មួយយករបស់នេះទៅឲ្យម្ដាយឯងនៅឯភូមិយោគ រក្សាទុកចុះ"។

ប្រសិនបើពូមីង និងប្អូនរបស់ក្មួយឯង ត្រូវគេសម្លាប់ចោល ក្មួយប្រាប់ម្ដាយឯងចែករបស់ទាំងនេះទៅឲ្យបងប្អូនយើងប្រើចុះ។ ប៉ុន្តែបើប្អូនៗឯងនៅរស់ចូរក្មួយប្រគល់ឲ្យប្អូនវិញផងណាក្មួយណ៎ា ហើយជួយមើលប្អូនៗផង។ អ្នកទាំងប្រាំនាក់ពោរពេញដោយទំនួញទួញសោក យំក្ដុកក្ដួលឥតឧបមា។ បន្ទាប់មកបងស៊ឹម ដាក់ក្នុងរមូរក្រមាចងចង្កេះ រួចជម្រាបលាឪពុកម្ដាយហើយចេញទៅយ៉ាងលឿន។

រួចរាល់ម្ដាយខ្ញុំនិយាយទៅកាន់បងស្រីថា "ចិន្ដា កូនមាសម្ដាយ ចូរកូនសរសេរបណ្ដាំម្ដាយទុកណា៎!"។ ពេលនោះបងស្រីទៅយកក្រដាសសៀវភៅមួយសន្លឹកពណ៌ស៊ីម៉ងត៍មូរជាមួយខ្មៅ

ដៃប្រវែងពីរថ្នាំងដៃនៅកន្ទៀតសសរផ្ទះមកសរសេរតាមម្ដាយនិយាយ។ សរសេរបណ្ដើរ ស្រក់ទឹកភ្នែកបណ្ដើរ នៃអក្ខរាចារដោយទឹកភ្នែក ខំប្រឹងក្នុងទឹកចិត្តមុតស្រួចទាំងកាន់ខ្មៅដៃញ័រទទ្រើត យំអណ្ដឹតអណ្ដក។

"ចិន្តាកូនស្រីម៉ែ! ប្រសិនបើមិនឃើញម្ដាយត្រឡប់មកវិញទេនោះ ប្រាកដជាគេសម្លាប់ឪពុកម្ដាយ និងប្អូនៗនៅទីទួលនោះហើយ។ នៅពេលស្រុកសាន្តត្រាណធំហុងឯងនឹងប្រគល់កញ្ចប់នោះមកកូនវិញ ហើយកូនកុំភ្លេចឲ្យរបស់មួយគូនៅនឹងកូននេះ ទៅឲ្យមីហ៊ុមកូនស្រីបងស៊ីមឯងចុះ"។

បណ្ដាំម្ដាយខ្ញុំផ្ដាំទៅបងស្រីមិនទាន់ចប់ផងផុតសំឡេងស្រែកពីក្រៅផ្ទះអន្ទងមកថា "សមមិត្ត ឡុង សមមិត្តនារីឆេងយឺតយូរក្រចេញទៅទួលស្លាំងម៉្លេះ?ឥឡូវមេកងកម្មាភិបាលថ្នាក់លើឲ្យខ្ញុំមកតាម"។

ម្ដាយខ្ញុំបើកទ្វារចេញមកក្រៅ ឃើញមនុស្សពីរនាក់ចូលមកដល់ក្នុងផ្ទះបង់កក្រមា គឺពូហាត និងពូវ៉ាន់ជាអនុគណៈមុខព្រួញរោងបាយ និងនីរសារកងឈ្លបភូមិនៅរង់ចាំខាងក្រៅផ្ទះ។ ម្ដាយខ្ញុំបានប្រាប់ទៅពួកគេថា "សមមិត្ត ខ្ញុំទៅឥឡូវហើយ រៀបចំអីវ៉ាន់សិន"។

ពួកគេតបមកទាំងសម្ដីម៉ឺងម៉ាត់ "ខ្ញុំនឹងចាំសមមិត្តឯងនៅខាងជើងភូមិកុំយូរពេក... ឮទេ?" ម្ដាយតបទៅពួកគេថា "ចាស៎ សមមិត្ត"។ បន្ទាប់មកពុកម៉ែខ្ញុំរូតរះជម្រាបលាតាយាយ ទាំងទឹកភ្នែកហូររហាមមានតែពាក្យបីម៉ាត់គត់ថា "កូនលាហើយ!"។

គួរឲ្យប្រហោងពោះណាស់ ពេលដែលបង ស៊ីម ចេញផុតបានបន្តិច។ អនុគណៈមុខព្រួញ និងកងឈ្លបមកដល់ផ្ទះ តាមហៅឪពុកម្ដាយខ្ញុំ។ នេះជាសំណាងណាស់ បើសិនជាពួកគេមកទាន់អាចចោទប្រកាន់ថា យើងជាខ្មាំងលួចមានទំនាក់ទំនងគ្នានោះ ប្រាកដជាគេសម្លាប់ចោលទាំងអស់មិនខាន។




រូបភាពបច្ចុប្បន្នឆ្នាំ២០២០៖ មរតកលិខិតបណ្ដាំម្ដាយចារដោយបងស្រីចិន្តា ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៨។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

## ខ្សែចងចាំខ្សែជីវិតអស្ដង្គត, បណ្ដាំលាស្លាប់ យំរឹងទឹកភ្នែក

បងស្រីខ្ញុំយំរួចឱបលោកពុកហើយ ហុចក្រមាមួយទៅឲ្យគាត់ ដោយនិយាយថា "ពុក នេះក្រមាដែលកូនឆ្វាក់ឈ្មោះកូននៅត្រង់ជាយ ទុកឲ្យពុកប្រើប្រាស់ ព្រោះពុកទៅឆ្ងាយ"។ ពុកតបវិញថា កូនស្រីសម្លាញ់មាសឪពុកកូនទុកប្រើចុះ តែបងស្រីខ្ញុំបន្ថែមថាពុកយកទៅៗ ពេលពុកនឹកកូន ពុកមើលជាយក្រមាដឹងថាកូននៅជិតលោកពុកហើយ។ រួចលោកពុកទទួលយកមើលមុខបងស្រីក៏យំដែរ ហើយក៏ដឹកដៃប្អូនភ្លោះ វិសុទ្ធ និង វិសាល ចេញទៅ។

ម្ដាយខ្ញុំទូលអង្ករមួយកញ្ចើតូចចំណែកឪពុកស្ពាយខោអាវវេចនឹងក្រមា។ ម្ដាយខ្ញុំបានងាកមកឱបអង្អែលក្បាលបងស្រីខ្ញុំដោយក្ដីអាណិតស្រណោះស្រណោក និងនិយាយថា "នែកូនចិន្ដាម៉ែទៅហើយ មើលថែទាំប្អូនទាំងពីរផងៗ កុំភ្លេចប្រាប់បងវុឌ្ឍឯងផងថា ម៉ែទៅរស់នៅលើទួលស្វាំងហើយ។" (ពេលនោះបងវុឌ្ឍខ្ញុំជាក្រុមកងចល័តធ្វើការកន្លែងផ្សេង គេហៅថាសមរភូមិមុខទួលស្នាយខួចឃុំកញ្ចំ)។ ពាក្យសម្ដីបីម៉ាត់របស់ម្ដាយនិយាយមកកាន់កូន "ម៉ែទៅហើយ!" ពិតជាធ្វើឲ្យខ្ញុំមុជឈ្លក់ដល់ជម្រៅបាតទុក្ខសោកនៃគ្រួសារបាត់បង់។

ឮសម្ដីម្ដាយពោលដូច្នេះ ចិត្តខ្ញុំរឹតតែក្ដុកក្ដួល ហើយបានងើបពីអង្រឹងស្ទុះទៅទាញដៃឪពុក ដោយស្រែកយំថា "ពុកម៉ែកុំទៅអីៗ" ពេលនោះពុកបានស្ទុះមកលុតជង្គង់ឱបខ្ញុំ ហើយពោលពាក្យថា "បើពុកម៉ែមិនទៅទេ អង្គការបដិវត្តន៍នឹងមកសម្លាប់យើងទាំងអស់គ្នានៅទីនេះហើយ។ កូនមានឮគេស្រែកហៅអម្បាញ់មិញទេ? គេមិនសម្លាប់ពុកទេព្រោះពុកជាគ្រូបង្រៀន"។ ពុកគាត់និយាយ ខ្ញុំដឹងថា នេះគ្រាន់តែជាពាក្យបន្ទន់អារម្មណ៍សោកសៅរបស់ខ្ញុំប៉ុណ្ណោះ។ មើលមកខ្ញុំដូចជាធូរអារម្មណ៍បន្តិច គាត់បានពោលតិចៗ ដោយជូតទឹកភ្នែកបណ្ដើរថា៖

"កូនឈប់យំទៅ ពេលពុកបែកពីកូនកូនកុំនឹកពុកម៉ែអី ហើយកូនត្រូវចេះស្រឡាញ់បងប្អូន កុំឈ្លោះប្រកែកគ្នាណា។ បើគេសម្លាប់ពុក សូមកូនកុំសងសឹកនឹងគេអី ព្រោះនេះជាកម្មពុកដែលបន្សល់ទុកពីជាតិមុនៗ បើ កូនសងសឹក កូននឹងមានកម្មទៅជាតិក្រោយមិនចេះចប់។ ដូច្នេះបញ្ចប់វាត្រឹមពុកចុះ កុំឲ្យមានកម្មវេរាបន្តដល់កូនដល់ចៅទៀត។ ម្យ៉ាងទៀត ពុកមិនចង់ឃើញកូនខ្មែរជំនាន់ក្រោយកាប់សម្លាប់ គុំគួនបន្តនូវអាកប្បកិរិយាវេសអើង លាបពណ៌គ្នាប្រើអាវុធជាដំណោះស្រាយជម្លោះ បាត់បង់អស់នូវកិត្យានុភាព ដែលធ្លាប់មានពីសម័យអង្គរ រក្សានូវវប្បធម៌ចាញ់ជាព្រះ ឈ្នះជាមារ ចំពោះខ្មែរគ្នាឯង។"

"កូនអើយ! តាំងពីពុកដឹងក្ដីឃើញតែការវេចបង្វេចរត់ភៀសសឹកគេចចេញពីភ្លើងសង្គ្រាមខ្មែរគ្នាឯងគ្មានលស់ពេល។"

កូនៗរស់នៅចេះកសាងកេរ្ដិ៍ឈ្មោះឲ្យល្អពីរោះ ជាពូជពង្សដ៏ឧត្ដម សម្រាប់ជាគំរូដល់កូនចៅជំនាន់ក្រោយៗទៀត។

សម្ដីនេះគាត់តែងតែពោលប្រាប់កូនៗជារឿយៗ។ ពាក្យទាំងនេះហើយដែលធ្វើឲ្យអារម្មណ៍ខ្ញុំកាន់តែក្ដុកក្ដួលគ្មានពេលស្រាកស្រាន្ដរហូតមកដល់ពេលនេះ នៅតែនឹកឃើញ ហើយយំរងំក្នុងចិត្ត គិតទៅ ទឹកចិត្តឪពុកម្ដាយមិនមែនគិតគូរកូនក្នុងជាតិនេះទេ គឺមើលជាតិ ក្រោយរបស់កូនទៀត។ ពេលពុកពោលបណ្ដាំលាស្លាប់ចប់ គាត់ក៏ប្រាប់បងស្រីខ្ញុំ "នែចិន្ដាកូននាំប្អូនទៅដេកចុះ!"។



ទិដ្ឋភាព៖ បងស្រីហុចក្រមាប៉ាក់ជាយ ដែលមានឈ្មោះ"ចិន្ដា" ។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

បន្ទាប់មកបងស្រីក៏ដឹកដៃខ្ញុំមកក្នុងផ្ទះ ដោយពោលពាក្យលាយឡំនឹងទឹកភ្នែកថា "ប្អូនកុំយំអី យើងមានបងប្អូនបីនាក់ និងយាយតានៅជាមួយដែរតើ!"។

ពាក្យសម្តីបណ្តាំទុក្ខរយពាន់នេះគ្មានន័យសម្រាប់ខ្ញុំទៀតទេ។ ខ្ញុំយំរីងខ្សោះទឹកភ្នែក ដង្ហើមឡើងដង្ហក់ ខំឈរទប់ខ្លួនកាន់ដៃបងស្រី ស្ទើរមិនជាប់ សម្លឹងមើលពុកម៉ែធ្វើដំណើរឆ្ពោះទៅរកទីអវសានជីវិត។

ពេលនោះខ្ញុំ និងបងស្រីសល់តែសម្បកកាយ គ្មានព្រលឹងព្រលះក្នុងខ្លួនទាំងអាល័យ នឹកអាណិតប្អូនភ្លោះវិសុទ្ធ និង វិសាល កាន់ដៃគ្នាដើរបណ្តើរប្រឡែងគ្នាបណ្តើរ ព្រោះគ្នានៅក្មេងខ្ចីមិនទាន់ដឹងក្តី ថាចង្កូមពេជ្ឈឃាដដៃដៅកំពុងរង់ចាំនៅឯមាត់រណ្តៅមរណៈលើទួលពិឃាដនៅសល់ពេលមិនយូរប៉ុន្មាននោះ។

ដើរចេញបានបន្តិច លោកពុក និងអ្នកម៉ែងាកមកមើលកូនៗ រួចយកដៃជូតភ្នែកចង់បញ្ឆក់ចេញពីភក្តីសំណាញ់ជីវិតថា ពួកគាត់ក៏កំពុងតែយំយ៉ាងកក្រើករបើកដួងចិត្តសោកសង្រេងនឹកអាល័យអាឡោះស្រណោះអាណិតកូនតូចៗខ្លាំងណាស់។ សុខចិត្តជីវិតស្លាប់ដើម្បីរក្សាកូនឲ្យគង់វង្ស ទោះជាព្រហ្មលិខិតកាចសាហាវឥតមេត្តាយ៉ាងណាក៏ដោយ។

តាយាយ បងស្រី និងខ្ញុំមានទឹកភ្នែកហូរសស្រាក់ចេញមកជូនដំណើរលោកឪពុកអ្នកម្តាយនិងប្អូនភ្លោះ។ កូនពិតជាគ្មានលទ្ធភាពជួយពុកម៉ែ មានតែលួចបន់ស្រន់ក្នុងពោះឱ! ព្រះជាម្ចាស់និងវត្ថុស័ក្តិសិទ្ធិក្នុងលោក មេត្តាជួយថែរក្សាឪពុកម្តាយ និងប្អូនៗខ្ញុំផង។



ទិដ្ឋភាព៖ ខ្ញុំស្ទុះទៅទាញដៃលោកឪពុកដោយពោលថា ពុកកុំទៅអីៗ គេនឹងសម្លាប់ពុកម៉ែ និងប្អូនភ្លោះនៅទីនោះហើយ ព្រោះកូនឃើញគេជីករណ្តៅទុកជាស្រេច។ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)



ទិដ្ឋភាព៖ យំលេបទឹកភ្នែកជូនដំណើរឪពុកម្តាយ និងប្អូនភ្លោះទៅកាន់ទួលស្វាំងពិឃាដ។ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

ខ្ញុំឈរសម្លឹងមើលពីរនាក់បងស្រីរហូតដល់ផុតកន្ទុយភ្នែក ដោយខ្លួនញ័រទទ្រើតនឹកអាឡោះរយលានអាល័យ នឹងគ្មានថ្ងៃបានជួបគ្នាវិញក្នុងលោកិយនេះ។

ទឹកភ្នែកឈាមរាប់ពាន់តំណក់ស្រក់លើរនាបឫស្សី ក្នុងផ្ទៃផ្ទះដ៏តូចមួយគ្របដណ្តប់ដោយស្លឹកកណ្តបផ្ទុះធ្លាយលាយឡំនឹងសំឡេងយំទួញសោកម្នាក់ៗក្នុងពោះ ទាំងជីដូនជីតាបងស្រី ប្រៀបដូចមនុស្សរស់មិនរស់ស្លាប់មិនស្លាប់។ ជាទណ្ឌកម្មជីវិតដ៏កំណាចរុញប្រានទ្រនំវាសនាឲ្យដួលរលំដូចខ្លែងដាច់ខ្សែ កែប្រែព្រហ្មលិខិតឥតមេត្តានូវសន្ធាស្រវាត្រដរខ្យល់នៅក្នុងភពដ៏កន្ទល់នេះ។

# ជម្រៅចិត្តឪពុកម្ដាយ

## ជីវិតថ្មី

ចំណែកប្អូនប្រុសវ៉ាបន្ទាប់ខ្ញុំ មិនបានដឹងរឿងដំក្រៀមក្រំនេះទេ ព្រោះមេកងកុមារឲ្យប្អូនទៅចាំគោនៅឯវាលទួលតាបញ្ញ។ តែមិនដូច្នោះទេ ប្អូនខ្ញុំក៏បានដឹងរឿងនេះដែរ ព្រោះមិត្តកុមារដែលបានឃើញឪពុកម្ដាយខ្ញុំធ្វើដំណើរទៅទួលស្វាំង ក៏ស្រែកប្រាប់ប្អូនខ្ញុំរបៀបនិយាយសើចចំអកថា "នែអាវ៉ាអាអ្នកថ្មី ពុកម៉ែឯងអង្គការឲ្យទៅនៅទួលស្វាំងហើយ ម្ដេចឯងមិនទៅ?"។ ឮដូច្នោះភ្លាមប្អូនខ្ញុំធ្លាក់ខ្សែចំណង និងស្នឹងគោចេញពីដៃដោយមិនដឹងខ្លួនរួចស្ទុះរត់កាត់វាលស្រែពោរពេញដោយភក់សំដៅទៅកាន់ទួលស្វាំងនោះ។

មកដល់ភ្លាមប្អូនខ្ញុំរុលចូលរបងទៅក្នុងទួលនោះសម្លឹងរេរាចុះឡើងក្នុងចិត្តភ័យផងអរផង។ ខំរកមើលពីដំបូកមួយទៅដំបូកមួយដូចជាមិនឃើញអ្វីសោះ គឺស្ងាត់ជ្រងំឃើញតែដើមត្នោតនិងសត្វបក្សីហើរ យំឆ្លើយឆ្លងគ្នា។ ប្អូនខ្ញុំមានអារម្មណ៍ដូចជាឆ្ងល់ហេតុអ្វីមិនឃើញអ្វីសោះអ៊ីចឹង? តើឪពុកម្ដាយ និងប្អូនខ្ញុំនៅកន្លែងណាទៅ? ខំដើររកពេញទួលគ្រប់ទីកន្លែង មិនឃើញមនុស្សណាម្នាក់ទេ។ ក្នុងចិត្តអស់សង្ឃឹម ហើយគិតថាប្រហែលជាកុមារមូលដ្ឋានទាំងនោះនិយាយភូតកុហកហើយ រួចប្អូនវ៉ាក៏ត្រឡប់ទៅផ្ទះវិញ។

ដើរមកជិតដំបូកមួយក៏ឃើញពូផាត ជាអ្នក១៧ មេសា ដូចគ្នា ដែលមានអំរែកលើស្មា ប្រពន្ធគាត់ទូលកញ្ជើពីលើក្បាល និងដឹកដៃកូនគាត់អាយុស្របាលប្អូនភ្លោះខ្ញុំ។ ប្អូនវ៉ាក៏ស្ទុះទៅកាត់មុខគាត់។ មិនទាន់សួរនាំគាត់ផង គាត់ក៏និយាយមកកាន់ប្អូនថា ក្មួយវ៉ាទៅណានឹង។ ប្អូនវ៉ាក៏ឆ្លើយថា ខ្ញុំមករកពុកម៉ែខ្ញុំនៅទីនេះ តើពូមានដឹងទេ? គាត់តបមកថា ម៉ោះក្មួយដើរតាមពូមក។ មើលទៅទឹកមុខពូផាត ហាក់ដូចជាមិនមានការភ័យព្រួយអ្វីបន្តិចសោះ។ ប្អូនវ៉ាក៏ដើរតាមក្រោយគាត់។ មិនយូរប៉ុន្មានក៏ឃើញកងឈ្លបខ្មែរក្រហមប្រហែលបួនប្រាំនាក់មានស្ពាយកាំភ្លើងអាកាអូសដី។ ពូផាតក៏ប្រាប់ទៅពួកគេថា គ្រួសារខ្ញុំត្រូវមេកង អង្គការឲ្យមកនៅទីនេះ។ ពួកកងឈ្លបទាំងនោះបានចង្អុលទៅរោងមួយធ្វើថ្មីពីដើមបុស្សីប្រក់ស្លឹកត្នោត។

ដើរបានបន្តិចស្រាប់តែឃើញមនុស្សអង្គុយក្នុងរោងនោះ ប្រហែលម្ភៃទៅសាមសិបនាក់មានទាំងក្មេងកូនង៉ែតម្ដាយកំពុងបំបៅដោះ មានស្គាល់ខ្លះគឺជាអ្នកភូមិខ្ញុំ មានគ្រួសារ ពូមុយ មីងតុប គ្រួសារគ្រូញៀន មីងញឹប គ្រូម៉េន មីងស៊ីម៉េត ពូផាត ប្រពន្ធ និងគ្រូវ៉ាង សុទ្ធសឹងអ្នក ១៧ មេសា និងជាសាស្ត្រាចារ្យ និងគ្រូបង្រៀនដដែកគ្នាពីនេះពីនោះ។ ប្អូនវ៉ា ខំសម្លឹងរកទៀត ក៏ឃើញលោកឪពុកអ្នកម្ដាយ។ ឪពុកកំពុងឱបកូនភ្លោះក្នុងក្ដីអាណិត ឯម្ដាយអង្គុយបញ្ឈរក្បាលជង្គង់នឹកគិតរឿងវែងឆ្ងាយ។ មើលទៅគាត់ទាំងពីរមានទឹកមុខស្រពោនសង្វេគ អស់សង្ឃឹមស្ទើរបោកប្រាណ។ ប្អូនវ៉ាក្រឡេកឃើញយំងោង ម្ដាយភ្ញាក់បើកភ្នែកធំៗ ស្ទុះមករកកូន រួចឱបយំ។ ប្អូននិយាយថា "ពុកម៉ែ កូនមកនៅនឹងទីនេះដែរ!" ហើយប្អូនភ្លោះទាំងពីររត់មកឱបប្អូនវ៉ា ដោយក្ដីសប្បាយ ថាបានរត់លេងជាមួយគ្នា។

ពេលនោះ ម្ដាយខ្ញុំស្រឡាំងកាំងប្រែទឹកមុខ ងាកមើលឆ្វេងមើលស្ដាំ



ទិដ្ឋភាពតំណាល៖ ប្អូនវ៉ារត់ទៅរកឪពុកម្ដាយនៅទួលស្វាំងពិឃាដ បន្ទាប់ពីកុមារមូលដ្ឋានបានប្រាប់។ (ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

យកដៃខ្ទប់មាត់និយាយខ្សឹបៗ ជាសំឡេងខ្សោយ ទាំងអួលដើមកលាយនឹងទឹកភ្នែករលីងរលោងថា "យីកូនមកទីនេះធ្វើអ្វី កូនប្រញាប់ទៅវិញទៅបងឯងទាំងពីរ និងយាយតាចាំនៅឯផ្ទះៗ" រួចគាត់យកដៃអង្អែលក្បាលហើយរុញចេញដោយប្រាប់តិចៗថា ឆាប់ទៅៗ ប្រយ័ត្នកុំឲ្យកងឈ្លបខោអាវខ្មៅឃើញ។

ឪពុកខ្ញុំ គាត់មិនមានមាត់កអ្វីទេ សម្លឹងមើលមកប្អូនខ្ញុំធ្វើភ្នែកភ្លឹសៗ ប្រៀបដូចមនុស្សស្លាប់ទៅហើយ សល់តែសម្បកកាយ និងមានតែទឹកភ្នែកហូរចេញមកពេញផ្ទៃថ្ពាល់ដោយដួងព្រលឹងវិញ្ញាណហោះហើរចេញបាត់អស់។

ប្អូនរ៉ាក៏រួតរះរត់ចេញទៅឱនងើបៗ ខ្លាចភ្នែកកងឈ្លបខោអាវខ្មៅឃើញ ទាំងភ័យរន្ធត់ៗ កំពុងរុលរបងចេញហើយឆ្លងផ្លូវរទេះ ឮសំឡេងស្រែកថា "នែពួកអាចក្រពត្តិ ហ្អែងចង់រត់ចេញពីជំរំអន្តការបដិវត្តន៍ទៅណា?" ពេលនោះប្អូនរ៉ា ក៏ដួលទៅក្នុងគុម្ពោតដើមរំចាកមួយគុម្ព ក្នុងចិត្តអស់ព្រលឹងព្រលះស្លាប់បាត់ទៅហើយ រួចក៏អើតមើលតាមប្រលោះព្រៃ ឃើញកងឈ្លបពីរនាក់ស្លៀកខោជើងវែងអូសដីកាន់គល់ឫស្សីម្នាក់មួយ ដើរតម្រង់មកយ៉ាងលឿនៗ ប្អូនរ៉ា ភ័យញ័រក្រាបខ្លួនផ្ទាល់ដី លួចសម្លឹងមិនប៉ប្រិចភ្នែក គិតថាគេសម្លាប់នៅទីនេះហើយ។

មិនយូរប៉ុន្មានស្រាប់តែឃើញមនុស្សចំណាស់ម្នាក់ ស្ទុះចេញពីដំបូកក្បែរនោះ មានតែខោរហែករយ៉េរយ៉ៃ ដៃជាប់ចំណងស្វាបសេកដោយខ្សែធាងត្នោតៗ ពេលនោះ កងឈ្លបពីរ



ទិដ្ឋភាពគំនូរ៖ ប្អូនរ៉ារត់គេចចេញពីទួលស្វាំង បន្ទាប់មកឃើញកងឈ្លបចាប់ចងឈ្លើយសឹកដែលលួចរត់ចេញពីទួលស្វាំង។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

នាក់នោះស្ទុះទៅវាយក្បាលនឹងគល់ឫស្សី ឮស្វូរក្រុះ ហើយនិយាយថា "នែអាខ្មាំងចក្រពត្តិនិយម ហ្អែងគិតថារួចខ្លួនឬ?" កងឈ្លបទាំងពីរនាក់នោះវាយមិនបន្ធូរដៃ ឮតែសំឡេងស្រែក "អូយៗកុំវាយខ្ញុំអី សមមិត្ត!" ហើយក៏បណ្តើរចូលទៅក្នុងទួលស្វាំងបាត់ទៅ។

បន្ទាប់មកប្អូនរ៉ា ក៏លូនចេញពីគុម្ពដើមរំចាក ហើយរត់ផង ដើរផង ស្ទើរទន់ជង្គង់ ប៉ុន្តែសំណាងល្អប្អូនខ្ញុំបានចេញមកដល់ខាងក្រៅទួលដោយសុវត្ថិភាព ហើយរត់យ៉ាងលឿនកាត់វាលស្រែដែលពោរពេញទៅដោយគល់ជញ្ជ្រាំងចាស់ៗលាយទឹកថ្លុកក្របី និងព្រៃដំបូកមួយៗ។

ដើរបណ្តើរ រត់បណ្តើរ ប្អូននឹកមិនអស់ចិត្ត ហេតុអ្វីអាថ៌កំបាំងម្ល៉េះ អម្បាញ់មិញដើរកាត់កន្លែងហ្នឹងមិនឃើញមានរោង និងមនុស្សណាម្នាក់សោះ ចុះហេតុអ្វីពូជាតមើលឃើញរោងនោះ? ពិតជាទួលអាថ៌កំបាំងនិងព្រឺសម្បុរមែនៗ ប្រហែលជាមានអ្នកសច្ចំមកបំបាំងរោងនិងមនុស្សមិនឲ្យប្អូនរ៉ាឃើញហើយ?។ ទីបំផុតប្អូនខ្ញុំបានមកដល់ផ្ទះ។

ពេលមកដល់ផ្ទះ ប្អូនបានរាយរាប់រឿងនេះប្រាប់ដល់យើងថា បានទៅរកពុកម៉ែនៅក្នុងទួលស្វាំង តែម៉ែបានដេញមកផ្ទះវិញ។ តាយាយ បងស្រី និងខ្ញុំឈរមើលប្អូនដោយក្តីអាណិតជាពន់ពេកៗ មើលទៅទឹកមុខមានសភាពភ័យស្លន់ស្លោរស្លេកស្លាំង និងប្រឡាក់ភក់ពេញជើង លាយស្នាមឈាមដោយមុតបន្លា សក់បះកន្ទ្រើងមានតែខោខ្លីកញ្ចាស់រហែកមុខក្រោយ គ្រប់ដណ្តប់គួរឲ្យអាណិតប្អូនខ្លោចចិត្ត។

# អាណិតប្អូនភ្លោះដាច់ទងប្រមាត់

បន្ទាប់មកប្អូនរៀបរាប់បន្តទៀតថា អាភ្លោះទាំងពីររត់យំតោងដៃខ្ញុំមកជាមួយដែរដោយស្រែកប្រាប់ម្តាយថា កូនទៅផ្ទះជាមួយបងវ៉ាហើយ។

ដើរបានបន្តិចម្តាយខ្ញុំស្ទុះទៅទាញប្អូនភ្លោះខ្ញុំដោយលួងថា បន្តិចទៀតចាំទៅជាមួយម៉ែ។ គាត់ហូរទឹកភ្នែកយំខាំមាត់ពេបទប់ក្នុងចិត្តលាក់ការពិតចំពោះកូនភ្លោះទាំងពីរស្ទើរដាច់វិញ្ញាណនូវពាក្យភូតភរនេះ និងអាណិតកូនភ្លោះដែលនៅមានជីវិតចង់រស់ មិនដឹងថា បន្តិចទៀតត្រូវគេសម្លាប់បុយ៉ាងណា?។

ម្តាយខ្ញុំមិនឲ្យប្អូនភ្លោះមកជាមួយប្អូនវ៉ា ដោយគាត់គិតថា ខ្លាចជួបកងឈ្លបខ្មែរក្រហមគេនឹងសម្លាប់ចោលទាំងអស់ ព្រោះជីវិតរបស់គាត់ដូចទឹកលើស្លឹកឈូកស្ថិតក្នុងសភាពឃ្លេងឃ្លោងនៅឡើយ។ បើយើងជាគាត់ត្រូវគិតយ៉ាងណា?។ ដូចនេះ គាត់ពិតជាវិលវល់ពិបាកគិតក្នុងរឿងនេះណាស់។ ពេលស្តាប់ចប់ពួកយើងទាំងអស់មានតែទឹកភ្នែករលីងរលោងស្តាប់អារម្មណ៍នឹកអាណិតឪពុកម្តាយ និងប្អូនភ្លោះ។

បន្ទាប់មកបងស្រីខ្ញុំស្ទុះទៅដឹកដៃប្អូនយកទៅងូតទឹកនៅពាងក្បែរនោះគាត់ដុសក្អែលឲ្យទាំងទឹកភ្នែកហូររហាម។

តំណក់ទឹកដែលស្រោចលើប្អូន ធ្វើឲ្យរងាញាប់ញ័រ ឈឺពើតផ្សានឹងស្នាមរបួសបន្ទារំចាក និងអម្ពិលទឹកដែលជាប់នៅនឹងខ្លួនមួយៗ តែប្អូនវ៉ាខាំមាត់មិនស្រែកថ្ងូរមួយអឺះទេ។

រួចរាល់ហើយ យាយតាក៏ហៅហូបបាយជុំគ្នា ដែលគាត់តែងតែលួចដាំនឹងកំសៀវទឹក ចានស្លាបព្រាកប់ក្នុងដេះផ្ទោះចង្ក្រានការពារខ្លាចក្រែងអង្គការឃើញ។ បើសិនជាចៃដន្យ ពួកគេឃើញនោះនឹងប្រាប់ពួកគេថា ដាំទឹកទុកហូប ព្រោះពេលនោះអង្គការមិនឲ្យដាំបាយបបរនៅផ្ទះទេ គឺដាំបានតែទឹក។ ចានឆ្នាំងស្លាបព្រាមិនត្រូវឲ្យមានជាដាច់ខាត។

នឹកដល់ត្រឹមនេះ នៅរដូវរំហើយមេកងកុមារអង្គការបដិវត្តន៍ឲ្យខ្ញុំទៅចាំចាបនៅវាលស្រែមិនហ៊ានចាប់ត្រីយកមកផ្ទះទេ។ ថ្ងៃមួយ មកពីចាំចាបវិញ ដែលមានតែឧបករណ៍រយាលចាបលីនឹងស្នា នៅតាមដងផ្លូវឃើញត្រីឆ្លូញនៅក្នុងចង្អូរស្រែយ៉ាងច្រើន តែខ្ញុំចាប់វាតែមួយដាក់ក្នុងរម្ងរដៃអាវកុំឲ្យគេឃើញ។

មកដល់ផ្ទះ ខ្ញុំបានហុចឲ្យឪពុកខ្ញុំហើយប្រាប់គាត់ថា សូមពុកប្រឡាក់ត្រីឲ្យខ្ញុំផង គាត់បានប្រាប់ថា កុំយកមកទៀតប្រយ័ត្នកងឈ្លបឃើញ។ រួចគាត់បោះចូលទៅក្នុងដេះផ្ទោះចង្ក្រាន។ ចំណែកបងស្រីខ្ញុំក៏ដូចគ្នាដែរ តែងតែលួចដកដំឡូងមកផ្ទះ តែឪពុកខ្ញុំបានហាម គឺថាអង្គការបដិវត្តន៍មិនឲ្យមានរបស់របរហូបចុកមាននៅក្នុងផ្ទះជាដាច់ខាត។

យាយតាទំពាបាយមួយៗ រួចសម្លឹងមើលមុខចៅទាំងបីនាក់ដោយក្តីអាណិត រកអ្វីមកប្រៀបផ្ទឹមពុំបាន ហើយពោលតិចៗថា ចៅៗហូបចុះ ហូបឲ្យឆ្អែតណា ឆាប់ទំពាលេបឲ្យលឿន ខ្លាចកងឈ្លបមកឃើញ ។

ទោះជាឃ្លានយ៉ាងណាបានត្រឹមតែទំពាគ្មានរសជាតិអ្វីទេ ព្រោះអារម្មណ៍កំពុងតែហោះហើរ វិលវល់ គ្មានកោះត្រើយគិតពីភាពសោកសៅក្នុងសង្វៀនថ្លុកឈាមជីវិតគ្រួសារបាក់បែក។ សម្រាប់ខ្ញុំ ពេលនោះ គឺអារម្មណ៍កំពុងតែគិតទៅដល់លោកពុក និងអ្នកម៉ែ ព្រមទាំងប្អូនៗ មិនដឹងថាបានសុខទុក្ខយ៉ាងណាទេ។

បងស្រីខ្ញុំលបមើលមុខខ្ញុំរួចមើលមុខប្អូនវ៉ា ហើយងាកទៅជូតទឹកភ្នែកកំពុងហូរ។ ខ្ញុំតាមមើលគាត់ និងប្អូនរៀងអួលដើមក ហើយហូរទឹកភ្នែកមកមិនដឹងខ្លួន។ ហូបបាយស្រូបទឹកភ្នែករួចរាល់ហើយ តាយាយក៏ប្រាប់បងស្រី ខ្ញុំឲ្យនាំប្អូនៗចូលដេកចុះ។ កន្ទេលកញ្ចាស់រហែកក្រាលលើរនាបឫស្សី បីនាក់បងប្អូនដេកតម្រៀបគ្នា។ យាយយកក្រមាកញ្ចាស់មួយមកដណ្តប់ឲ្យខ្ញុំ និងប្អូនប្រុសពោរពេញដោយក្តីអាណិតជាពន់ពេក។

យប់នោះដួងចន្ទ្រអាប់រស្មីមេឃងងឹតឈឹងផ្គរលាន់គ្រឹមៗលាយ ឡំនឹងផ្លេកបន្ទោរភ្លែតៗ ហាក់ដូចជាគំរាមបងប្អូនខ្ញុំទាំងបី ថាកុំឲ្យមាត់ក ត្រូវនៅឲ្យស្ងៀម។

គិតចុះឡើង ខ្ញុំនៅតែនឹកឃើញដល់រណ្តៅពិឃាដនៅទួលស្វាំង នឹកដល់មីត្នោតដែលនាំខ្ញុំទៅដល់

ទីនោះៗ ខ្ញុំលួចយំម្នាក់ឯង និងយកដៃរាវសទឹកភ្នែក ចិត្តនៅតែរន្ធត់ រួចលួចមើលទៅក្រោមផ្ទះតាមឪពុកខ្ញុំ ក្រែងមានគេដឹងឮបាក់ឃ្លានខ្លាយកការណ៍ តែមិនមានឃើញមាននរណាម្នាក់ទេ ព្រោះពួកគេគិតថា គ្រួសារខ្ញុំទៅនៅទួលស្លាំងអស់ហើយ។

ភ្លៀងធ្លាក់មកហើយ សំឡេងកូនក្អាត់យំ ដំបូលផ្ទះធ្លុះធ្លាយ ហូរទឹកភ្លៀងចូលសាចមកក្នុងផ្ទះ តែដោយអំណាចហត់នឿយ ហេវអស់កម្លាំងកំហែង និងបាក់ស្បាតផ្លូវចិត្តផងម្នាក់ៗ ងើបមិនរួច ក៏បេះតែទ្រាំសំងំដេកឱបដៃរងារញ័រញាក់គួរឲ្យស្រណោះ ក្នុងរលកជីវិតផ្លូវចិត្តបក់បោកមកឥតឈប់។

ខ្ញុំយកដៃជូតទឹកភ្នែកនឹកដល់អ្នកម៉ែ ដែលតែងតែលួងបំពេឲ្យកូនដេកនឹកដល់សម្តីលោកពុក ដែលធ្លាប់តែណែនាំស្តីប្រដៅកូនៗឲ្យសាងអំពើល្អ តែពេលនេះ ពួកកូនលែងបានជួបមុខលែងមានភាពកក់ក្តៅទៀតហើយ។ លោកពុក និងអ្នកម៉ែឃ្លាតទៅឆ្ងាយពីកូនៗលែងវិលវិញ។

ក្តីស្រមៃស្រណោះអាឡោះអាល័យនៅតែដក់ក្នុងអារម្មណ៍របស់ខ្ញុំៗ ខ្ញុំដេកមិនលក់រសាប់រសល់ ម្តងប្រែទៅឆ្វេង ម្តងប្រែទៅស្តាំ បើកភ្នែកលួចមើលតាមចន្លោះបង្អួចឃើញផ្លេកបន្ទោរៗ

ភ្លៀងផ្គររន្ទះបន្លឺរយ៉ាងខ្លាំងដូចជាភ្លើងកម្មឆាបឆ្លលនៅក្នុងដួងចិត្តដែលជាសញ្ញាចង់ប្រាប់ថា ពេលនេះជីវិតគ្រួសាររបស់ខ្ញុំ កំពុងជួបនូវព្យុះកម្មកំណាចបោកបក់ដូចនេះដែរ ដែលឪពុកម្តាយកំពុងតែរងនូវទារុណកម្មកាប់សម្លាប់ក្នុងពេលនេះហើយមើលទៅ។

ខ្ញុំលួចមើលទៅតាយាយតាមផ្លេកបន្ទោររន្ទះម្តងៗ ដូចជា គាត់មិនទាន់សម្រាន្តលង់លក់ ដោយយកដៃទះមូសនិងគងថ្ងាស នៅនឹកអាឡោះកូនស្រីពៅសម្លាញ់របស់គាត់ ដោយធ្លាប់រួមរស់ថែរក្សាគាត់ពេលកន្លងមក។

រូបភាពទាំងប៉ុន្មានបានថតទុក ផ្តុកក្នុងបេះដូងស្ទើរបែកទ្រូងៗ ខ្ញុំយកដៃទាំងទ្វេប្រណម្យដាក់លើក្បាល ពោលខ្សឹបៗក្នុងចិត្តឱ! ភ្លៀងផ្គររន្ទះ ដំនោរនិរតីអើយ! មេត្តាប្រណីដល់ជីវិតគ្រួសាររបស់ខ្ញុំផង! មិនយូរប៉ុន្មានខ្ញុំក៏លង់លក់ជន់ជោរក្នុងរាត្រីទុក្ខទឹកភ្នែករុករានពេញប្រាណ។

# ៣. វិញ្ញាណព្រលឹងក្រមាបាក់ជាយ

## ក្រមាបាក់ជាយទម្លាយអាថ៌កំបាំង

### សមមិត្តយុវនារីបដិវត្តន៍

ថ្ងៃមួយព្រឹកព្រលឹមស្រាងៗ មាន់រងាវលាន់ឮញាប់រន្ទាន់បញ្ជាក់ថាជិតភ្លឺហើយ។ មេឃចាប់ផ្តើមក្រហមព្រឿងៗនាទិសបូព៌។

ក្នុងខ្ទមជីវិតកម្សត់ យាយបានមកអង្រួនដាស់ចៅ ទាំងបីនាក់ ដោយនិយាយតិចៗថា "ចៅៗងើបឡើងភ្លឺហើយ ទៅលុបមុខលុបភក់ចេញ"។ ពួកខ្ញុំបីនាក់ភ្ញាក់ហើយរាងមីងមាំងយកដៃញីភ្នែកហាក់ដូចជានៅស្តាយដំណេក។

បងស្រីងើបដើរទៅរកពាងទឹករួចយកផ្តិលកញ្ជូសផ្ទុះធ្លាយមកដងទឹកលប់មុខរួចក៏ហុចឲ្យពួកខ្ញុំបន្តទៀត ខ្ញុំបានយកដេះមួយចុងម្រាមដៃដាក់ក្នុងមាត់ដើម្បីដុះធ្មេញ។ រួចរាល់ហើយ យាយក៏ហុចផ្លែខេមាឲ្យពួកខ្ញុំម្នាក់មួយៗ។ ផ្លែនេះគឺគាត់បានបេះបន្ទុំកាលពីល្ងាចហើយប្រាប់ថា ចៅៗទុកហូបចុះ។

បងស្រីគាត់រៀបចំខ្លួនចេញទៅធ្វើការទាំងមុខក្រៀមក្រំព្រោះគាត់ហាក់ដូចជានឹកទៅដល់លោកពុកអ្នកម្តាយ។ ចំណែកខ្ញុំក៏ចេញទៅឃ្វាលគោ និងប្អូនរ៉ាទៅធ្វើការដូចសព្វដងៗ បីនាក់បងប្អូនចេញទៅត្រសង។

ពួកយើងដើរលើទំនប់ដែលអាចមើលឃើញទួលស្លាំងៗ គ្រាន់តែឃើញភ្លាម ធ្វើឲ្យអារម្មណ៍ខ្ញុំនឹកស្រណោះទៅដល់លោកអ្នកមានគុណ និងប្អូនៗទាំងពីរខ្លាំងណាស់ៗ ក្នុងចិត្តលួចគិតសួរនាំថា តើលោកឪពុកអ្នកម្តាយ និងប្អូនភ្លោះសុខសប្បាយជាទេ? ហើយពេល

**តនៅលេខក្រោយ**

រូបក្របមុខ៖
តាអាន ត្រូវជាតារបស់ ឡុង វង្សសមិទ្ធ អ្នកនិពន្ធសៀវភៅ ទួលពិឃាដ
(សៀវភៅ ទួលពិឃាដ / ឡុង វង្សសមិទ្ធ)

រូបក្របក្រោយ៖
យាយ ហ៊ាង ត្រូវជាយាយ ឡុង វង្សសមិទ្ធ អ្នកនិពន្ធសៀវភៅ ទួលពិឃាដ
(សៀវភៅ ទួលពិឃាដ / ឡុង វង្សសមិទ្ធ)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 263, November 2021 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.